អត្ថាធិប្បាយ



# វប្បធម៌ អរិយធម៌ខ្មែរ



ហ្លួត-មេចស្ទ

សំរាប់ថ្នាក់បញ្ចប់ និងថ្នាក់ឧត្តម

ហួត រេចសួ

# អត្ថាធិប្បាយ

# វប្បធម៌ - អរិយធម៌

## ទូទៅ

ថ្នាក់ឧត្តមសិក្សា

# អត្ថបទ

# អារម្ភកថា

ផ្នែកទី ១

## ផ្តើមសិក្សាអរិយធម៌

១- សញ្ញាណអរិយធម៌
២- មែកធាងអរិយធម៌
៣- ទំនាក់ទំនងវប្បធម៌-សង្គមធម៌
៤- ទំនាក់ទំនងអរិយធម៌ខ្មែរ-បរទេស
៥- ដើមកំណើតជាតិខ្មែរ

ផ្នែកទី ២

## វប្បធម៌

១- សាសនា
២- ភាសា អក្សរសាស្ត្រ
៣- សិល្បៈ
៤- ជំនឿទំនៀមទំលាប់-ប្រពៃណី

ផ្នែកទី ៣

## សង្គមធម៌

១- នយោបាយ
២- សេដ្ឋកិច្ច
៣- សង្គមកិច្ច

# សេចក្តីបញ្ចប់

## តំលៃពិសេសនៃអរិយធម៌ខ្មែរ

### អារម្ភកថា

មនុស្សជាភាវៈវិសាមញ្ញនៃភាវៈរស់ដែលចេះប្រមើលមើលធម្មជាតិ និងត្រិះពិចារណាពីវាសនាខ្លួន ។ គឺជាភាវៈសង្គម ចេះស្តី ចេះស្តាប់ ចេះគ្រោង និងគោរពតម្រា ច្បាប់ក្បួន។ តិចនិចនិងភាសាជាមធ្យោបាយដែលមនុស្សមានវាសនាទទួលពីធម្មជាតិតែម្នាក់ឯង បណ្តាភាវៈរស់ទាំអស់អាចឱ្យភាវៈនេះលំអោនតាមមជ្ឈដ្ឋានធម្មជាតិ និងលំអិតលំអរខ្លួនឱ្យកាន់តែប្រពៃ។ តម្រាសង្គមក្នុងភពសត្វជាច្បាប់ធម្មជាតិក្រោមឥទ្ធិពលសភាវៈគតិចំនែកក្នុងភពសត្វជាច្បាប់ជួនចេញពីបរាជ័យបញ្ហាអត្តទត្តភាពជួនចេញពីប្រភពផ្សេងទៀត ហើយចេះតែលំអិតលំអន់តាមវិវត្តន៍ប្រវត្តិសាស្ត្រមនុស្សជាតិ ។
ក្នុងឋានៈជាភាវៈគំនិតប្រកបដោយអធិភាព មនុស្សត្រូវចាត់ទុកជាបំនែកតូចក្នុងលោកដ៏ធំធេងនេះ ។

លំហបញ្ហាដែលមិនគិតប្រយោជន៍ ព្រមទាំងមុខងារពិសិដ្ឋដ៏សប្បុរសនៃបដិការភាពច្រានមនុស្សចូលក្នុងប្រព័ន្ធពិភពលោក។ នៅក្នុងទីនោះមនុស្សអាចស្គាល់ភពដ៏ទៃ ដែលមានចលនាគ្រោងអង្គការព្រមទាំងមានការយោគយល់គ្នាទៅវិញទៅមក បុព្វសិទ្ធ ពិសេសដែលជាអំណោយផ្តាច់មុខរបស់ធម្មជាតិមកមនុស្សនេះ ធ្វើឱ្យមនុស្សមានសមត្ថភាពច្នៃរចនាសម្ពន្ធសង្គមតាមមជ្ឈដ្ឋាន និងធាតុអាកាសដែលខ្លួននៅ ហើយអរិយធម៌មនុស្សក៏មានកំណេកំណើតឡើង ។

ការប្រកួតប្រជែងក្នុងឆាកជីវិតតំរូវឱ្យមនុស្សចាប់ដៃគ្នារួបរួមគ្នាជាក្រុមសង្គមដើម្បីទប់ទល់ការពារសិទ្ធិរបស់ខ្លួន និងធ្វើឱ្យឥទ្ធិពលល្បីសុសសាយ ពេលនោះអរិយធម៌របស់សង្គមជាតិនិមួយៗក៏មានទំរង់ទម្រាយពិសេសផ្ទាល់ខ្លួន ហើយជនជាតិខ្លាំងពូកែអាចថ្កើន ល្បឿនអរិយធម៌របស់គេ និងជះឥទ្ធិពលទៅជនជាតិជិតខាងផងថែមទៀត។

ប្រជាជាតិយើងជាជនជាតិមួយរស់លើជ្រោយអាស៊ីអាគ្នេយ៍តាំងពីច្រើនពាន់ឆ្នាំមុនគ្រឹស្តសករាជមក បានកសាងសង្គមរបស់ខ្លួនឱ្យទៅជាជាតិមានអរិយធម៌ខ្លួនខ្ពង់ខ្ពស់ មានឈ្មោះល្បីល្បាញ។ ចាប់ពីសតវត្សទី ១ នៃគ្រឹស្តសករាជមក អរិយធម៌ខ្មែរបានប៉ះទង្គិច និងអរិយធម៌បរទេស ដែលហូរចូលមកជ្រោយសុវណ្ណភូមិមាន ឥណ្ឌា ចិន ចាម ជ្វា ជាដើម។ អរិយធម៌ខ្មែរដែលមានជំហររឹងប៉ឹងរួចទៅហើយមិនចុះញ៉មអរិយធម៌បរទេសទេ តែផ្ទុយទៅវិញបានពង្រឹងឥទ្ធិពលខ្លួនបើកចំហទ្វារទទួលអរិយធម៌បរទេសមកផ្សាំង សំរបសំរួល និងលក្ខណៈជាតិធ្វើឱ្យអរិយធម៌ជាតិកាន់តែចំរើនលូតលាស់ផងថែមទៀត។ ជាការភាន់ច្រលំមួយធំណាស់ បើគេយល់ច្រលំថាខ្មែរជាជនជាតិគ្មានអរិយធម៌ ឬអរិយធម៌ខ្មែរជាអរិយធម៌បរទេសមានឥណ្ឌាជាដើម។ ការស្គាល់អរិយធម៌ជាតិខ្លួនមិនច្បាស់ធ្វើឱ្យខ្មែរបាត់បង់មោទនៈភាព ហើយបែរជាខំភ្ជាប់ខ្មែរទៅនឹងជាតិសាសន៍ក្នុងមហាអំបូរណាទៅវិញ ខ្មែរមិនទទួលស្គាល់អរិយធម៌ជាតិខ្លួន ហើយបែរជាយកអរិយធម៌បរទេសមកគ្របដណ្តប់អរិយធម៌ខ្លួន ពីព្រោះអរិយធម៌គឺជារឹសកែវនៃជាតិនេះឯង។ ដូចនេះ ហើយបានជាជនជាតិបរទេសតែងខិតខំគាស់រំលើងអរិយធម៌ខ្មែរតាមគ្រប់មធ្យោបាយ ក្នុងគោលបំណងលេបខ្មែរយើង ។ អាស្រ័យហេតុនេះការស្គាល់និងបណ្តុះអរិយធម៌ជាតិឱ្យលូតលាស់ ជាកត្តាចាំបាច់បំផុតក្នុងបច្ចុប្បន្នកាលនេះ។ ស្គាល់អរិយធម៌ជាតិមិនច្បាស់អាចធ្វើឱ្យបាត់បង់ស្មារតីជាតិដែលជាអាវុធសំខាន់បំផុតក្នុងការប្រយុទ្ធ ដើម្បីអាយុជីវិតយើង។ ម្យ៉ាងវិញទៀត

ស្រលាញ់ជាតិតែមាត់ទទេ គឺគ្រាន់តែថាខ្លួនជាអ្នកស្រលាញ់ជាតិពុំទាន់មានន័យថា មានស្មារតីជាតិទេ មានស្មារតីជាតិពិតលុះត្រាតែស្គាល់ច្បាស់ពីអរិយធម៌ជាតិ ព្រមទាំងយកចំណេះយល់ច្បាស់នេះ មកធ្វើឱ្យជាតិចំរើនលូតលាស់ថែមទៀតផង។ សេចក្តីពុំមានន័យថា មិនឱ្យយើងសិក្សា អរិយធម៌ បរទេស តែផ្ទុយទៅវិញ ចំនេះវិជ្ជាទូលំទូលាយ ស្គាល់អរិយធម៌សកលលោកជា កត្តាមួយសំខាន់សំរាប់ អភិវឌ្ឍន៍អរិយធម៌ជាតិផងដែរ។ ក្នុងលក្ខខ័ណ្ឌយើងស្គាល់ច្បាស់ថាអ្វីជាសម្បត្តិ ជាតិ អ្វីជាបរទេសព្រមទាំងមានសមត្ថភាពទាញយកផលប្រយោជន៍ពីបរទេស មកបំរើជាតិយើងវិញ គំនិតជាតិនិយមជ្រុលរហូតដល់បំភាន់យកធាតុបរទេសមក ពន្យល់ថាជាធាតុខ្មែរក៏ពុំមែនជាកត្តាបង្កើតខ្លឹមសារជាតិដែរ។

សៀវភៅអរិយធម៌ខ្មែរផ្សាយមកនេះគឺក្នុងបំណងខាងលើនេះឯង ប៉ុន្តែ ពុំមែនមានន័យថាសៀវភៅនេះ មានខ្លឹមសារសំរាប់សិស្សយកទៅមើលយល់តាម ថាតាមទេ គឺគ្រាន់តែជាកញ្ចក់តូចមួយអាចឆ្លុះមើលទិដ្ឋភាពអរិយធម៌ខ្មែរខ្លះៗ តែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតការសិក្សាអរិយធម៌ខ្មែរពុំមែនមានសារៈសំខាន់ សំរាប់តែយកទៅប្រលងប៉ុណ្ណោះទេ តែជាកត្តាចាំបាច់ដែលខ្មែរត្រូវស្គាល់ពីរស កែវនៃជីវិតជាតិខ្លួន ដើម្បីពង្រឹងស្មារតីប្រឈមមុខតទល់នឹងឥទ្ធិពលជនជាតិ ជិតខាងយើង។

ភ្នំពេញ នៅថ្ងៃទី ១ តុលា ១៩៧៤

# ល្បិចតែងសេចក្ដី

តែងសេចក្ដីបែបអត្ថាធិប្បាយ (Discertation) ពុំមែនជាលំហាត់រូបមន្ត (Exercised Imagination)ទេ គឺជាសំណាក (Essai) រិះគិតទិតៀនពិភាក្សា ពន្យល់យ៉ាងល្អិតល្អន់អំពីបញ្ហាដែលប្រធានបានចោទសេចក្ដីថាជាការសិក្សាគំនិត សញ្ចេតនា អារម្មណ៍ សំនួន ដូចគ្នានឹងស្បង់ដែលក្រិតរូបការណ៍ (Inite materiels)

សំណាក់រិះគិតបែបនេះ ខុសពីលំហាត់ស្បង់តែត្រង់គ្រឹះ ជាគោលការណ៍នៃមតិរបស់យើងគ្មានទីបញ្ចប់ ។ ប៉ុន្តែវាចារទិតៀនក្នុងការអធិប្បាយមានលក្ខណៈដូចគ្នានឹងវាចាររបស់អ្នកភាវរកទ្រឹស្ដីស្បង់ទៅវិញ សេចក្ដីជាគំនិតអត្ថាធិប្បាយទាក់ទងគ្នាយ៉ាងសមសួន ហើយលេចចេញយ៉ាងជាក់លាក់ពីគោលការណ៍ ។ ការត្រូវសង្កេតឱ្យបានជាក់លាក់ ហើយប្រសិនបើអត្ថាធិប្បាយផ្អែកលើអត្ថបទវិញ នោះគេមិនត្រូវស្រាយគំនិតដោយភាន់ច្រលំនោះឡើយ ។

តម្រាអត្ថាធិប្បាយលេចចេញពីសេចក្ដីសង្កេតទូទៅនេះឯង ។ គ្រប់ប្រធានសេចក្ដីសុទ្ធតែមានបញ្ហា ដូចនេះត្រូវយល់បញ្ហានេះសិន មុននឹងគ្រោងសេចក្ដី ។ ជួលកាលដំណើរអត្ថាធិប្បាយមានលំនាំក្នុងប្រធានសេចក្ដីរួចទៅហើយ ដូចនេះយើងត្រូវផ្ដើមស្រាយ បញ្ហាតាមដំណើរស្មើនេះឯង ។

កាលណាយល់គ្រប់ទិដ្ឋភាពបញ្ហាប្រធាន ហើយទើបត្រូវចាប់ផ្ដើមគ្រោងគំនិត ។ គំរោងត្រូវឱ្យជាក់លាក់ និងទំនង ។ តាមធម្មតាគំរោងមាន បី ផ្នែកគឺៈ

## ១- ផ្ដើមសេចក្ដី:

-ចាប់ប្រធាននិយាយឱ្យទាក់ទង និងប្រធាន

-ចោទបញ្ហាប្រធាន

-ចែកប្រធាន

-ចែកប្រធាន : បំផុសជាសំនួរដើម្បីឃើញគោលសំរាយបញ្ជាក់គឺក្នុងសេចក្ដីផ្ដើមនេះហើយ ដែលគេត្រូវចង្អុលបង្ហាញនូវអ្វីដែលជាបញ្ហាចុចគោលសំណើរស្រាយបញ្ហា។ ធ្វើយ៉ាងនេះអ្នកអានដឹងភ្លាមថាសេចក្ដីចេញពីណាទៅណា តែគេពុំទាន់ដឹងស្រាយសេចក្ដីបញ្ជាក់អ្វីខ្លះ?

## ២- សេចក្ដីអត្ថាធិប្បាយ:

ជាសំរាយដែលត្រូវស្រាយចំនោទបញ្ហាតាមបន្ទាត់ដៅនៃចំនែកប្រធានក្នុងសេចក្ដីផ្ដើម។ គេស្រាយសេចក្ដីដោយទំនាក់ទំនង វាចារនិងច្រត់លើការណ៍ជាក់លាក់ដែលជាការសង្កេតក្នុងអត្ថបទក្ដី ក្នុងជីវភាពពិតក្ដី។ សំរាយបញ្ជាក់ត្រូវបំភ្លឺគ្រប់ចំនុចបញ្ហា និងធ្វើឱ្យអារម្មណ៏អ្នកអានជក់ជាប់ដោយតំណតំណាក់តភ្ជាប់ពីរបកគំហើញមួយទៅមួយ។

## ៣- សេចក្ដីបញ្ចប់:

ជាសេចក្ដីបំព្រួញបង្ហាញលទ្ធផលនៃសំរាយបញ្ជាក់របស់សេចក្ដីអធិប្បាយ។ ខ្លឹមសារគំនិតត្រូវចេញមុខមកស្មើសំរាយ បញ្ហាជាក់លាក់មួយជាចុងក្រោយ។ ក្នុងសេចក្ដីបញ្ចប់ យើងត្រូវធ្វើឱ្យចប់ឱ្យអ្នកអានអស់ឆ្ងល់មិនត្រូវចោទបញ្ហាថ្មីទៀតទេ។ ម្យ៉ាងទៀត អ្នកតែងសេចក្ដីត្រូវបញ្ចេញយោបល់ផ្ទាល់ខ្លួនវិនិច្ឆ័យតំលៃប្រធានដោយសេរី សេចក្ដីថាពុំមែនបញ្ចេញយោបល់ដើម្បីផ្គាប់អ្នកដទៃឬសម្របស្ថានការណ៍ក្រៅខ្លួននោះឡើយ។

ចំនែកអត្ថរូបវិញត្រូវខំផ្ចិតផ្ចង់ឱ្យមានសំរស់។ គួរនិយមប្រើពាក្យនិងឃ្លាងាយយល់ ងាយស្តាប់ ដើម្បីឱ្យអ្នកអានចាប់សេចក្តីឆាប់បាន។ គំនិតល្អត្រឹមត្រូវជាក់លាក់ អាចកប់សំរស់ខ្លួនក្នុងពាក្យ ឬឃ្លាសាំញ៉ាំ។

ជាអវសានអត្ថាធិប្បាយមានតម្រាបង្ហាញរូបខ្លះទៀត។ ប្រសិនបើយកប្រធានមកថាឡើងវិញ ត្រូវថាឱ្យសព្វគ្រប់ជៀសវាងការសង្ខេបផ្ទាល់ខ្លួនដែលអាចលំអៀងន័យសេចក្តី។

ប្លង់ត្រូវឱ្យលះ មិនត្រូវដាក់ចំណងជើង ដាក់លេខរៀង។ ដើម្បីរំលេចរាងប្លង់ គេត្រូវរំលងចោលមួយបន្ទាត់ពីសេចក្តីផ្តើមមកអធិប្បាយ និងពីសេចក្តីអធិប្បាយទៅសេចក្តីបញ្ចប់។

ចប់គោលគំនិតមួយត្រូវចុះបន្ទាត់ម្តង ក្នុងបំនងថ្ងៃគំរោងសេចក្តីនេះឯង។ សំរង់សេចក្តីដែលយកមកបញ្ចប់ ត្រូវដាក់ក្នុងសញ្ញាក្បៀស ពីរ " - "។ ទីបញ្ចប់ត្រូវ អានសេចក្តីឡើងវិញ ដើម្បីកែរូបសព្ទខណ្ឌសញ្ញា។ល។ អក្សរត្រូវឱ្យស្អាតបាត លះច្បាស់ អាចមើលបាន ព្រមទាំងសំអាតកិច្ចការជាទូទៅទៀតផង។

# ល្បែងតែងសេចក្តី

## តារាងសង្ខេបអរិយធម៌

| | | |
|---|---|---|
| | | -ជំនឿ |
| ចំណេះ | | -សាសនា |
| | | -ស្បង់ វិជ្ជា |
| វប្បធម៌ | | -ភាសា អក្សរ សញ្ញា |
| (បណ្តុះគំនិត) បន្សាយ | | -អក្សរសាស្ត្រ អក្សរសិល្ប៍ |
| | | -សិល្បៈពតិមានវិទ្យុ ទូរទស្សន៍) |
| | | -ទំនៀមប្រពៃណី |
| ប្រតិបត្តិ | | -អប់រំ |
| | | -កីឡា ល្បែង |
| អរិយធម៌ | | |
| (ការចំរើនលូតលាស់របស់សង្គម) | | -ប្រដាប់សំរាប់រស់ |
| សំភារៈ | | -ប្រដាប់បង្កើតផល |
| | | -វិជ្ជាជីវៈ សេដ្ឋកិច្ច កសិកម្ម) |
| សង្គមធម៌ | | |
| (បណ្តុះសំភារៈ) | វិធី | ឧស្សាហកម្ម ពាណិជ្ជកម្ម |
| សង្គមធម៌ | | ឧស្សាហកម្ម ពាណិជ្ជកម្ម |
| (បណ្តុះសំភារៈ) | វិធី | - នយោបាយ (របៀបគ្រប់គ្រង) |
| | | - សង្គមកិច្ច (សន្តិសុខ-សុខភាពការងារ) |
| | | - គ្រួសារ (កោសិកាសង្គម) |
| | | -វណ្ណៈសង្គម |
| | ទំរង់ | - ស្ថាប័នផ្សេងៗរបស់សង្គម |

# សេចក្ដីសង្ខេប

១- វប្បធម៌ (La cuture générale)

វប្បធម៌ទូទៅសំគាល់ចំនេះដឹងទូទៅរបស់ម្នាក់ៗ ពីវិជ្ជាក្ដី ពីជីវភាពក្ដី ពីព្រឹត្តិការណ៍ណាមួយក្ដី ។

២- វប្បធម៌អរិយធម៌

កាលណាគេប្រើពាក្យអរិយធម៌ឯកឯង គឺកំនត់ន័យថា អរិយធម៌សំគាល់ការលូតលាស់ផ្លូវចិត្ត អរិយធម៌សំគាល់ការលូតលាស់ផ្លូវសំភារៈ ។

៣- អរិយធម៌

កាលណាគេប្រើពាក្យអរិយធម៌ឯកឯង គឺកំនត់ន័យថា អរិយធម៌ក្ដោបយកទាំងវប្បធម៌ ទាំងសង្គមធម៌ ។

ផ្នែកទី១

## សញ្ញាណអរិយធម៌

**ប្រធានទី ១ :** អរិយធម៌ជាអ្វី ?

ភារៈរស់ទាំងអស់សុទ្ធតែលំអោនតាមច្បាប់វិវត្តន៍ដែលបំប្លែងបន្តិចម្ដងនូវប្រភេទក្នុងកំឡុងរាប់លានឆ្នាំ ប៉ុន្តែមានតែមនុស្សមួយគត់ដែលមានប្រវត្តិសាស្ត្ររបស់ខ្លួនព្រោះមនុស្សជាភាវៈរស់តែមួយដែលជាកើតផង ជាទទួលផង។ មនុស្សផ្ដើតភាសា ផ្ដើតប្រដាប់ប្រដារ ផ្ដើតសាសនា និងស្នាដៃសិល្បៈ ហើយផ្ដល់ទុកបេតិកភ័ណ្ឌនេះទៅឱ្យមនុស្សជំនាន់ក្រោយតាមស្រដី និងតាមសំនេរដែលពួកនេះទទួលយកមកផ្សៃផ្សំផ្ដើតបន្តទៅទៀត។ ក្នុងនេះប្រព័ន្ធតំលៃសង្គមមួយត្រូវជាប់ទាក់ទងទៅនឹងវិវត្តន៍ក្នុងកំឡុងពេលយ៉ាងយូរនៃកំនើតថ្មី និងទំនួលចាស់ជាហេតុនាំឱ្យមានលក្ខណៈប្លែកគ្នាពីសង្គមមួយទៅសង្គមមួយ។ សភាព និងតំលៃរបស់សង្គមផ្សេងៗបានផ្ដើតអរិយធម៌ផ្សេងៗគ្នាជាច្រើនក្នុងលោកយើងនេះតើអរិយធម៌ជាអ្វី? តាមជាតិសព្ទរបស់ពាក្យអរិយធម៌ ជាពាក្យផ្សំ រវាងអរិយ និងធម៌។ អរិយមានន័យថា ប្រសើរថ្លៃថ្នូរ ខ្ពង់ខ្ពស់។ ធម៌ ជាសភាវៈទម្រង់ ឬជាទ្រឹស្ដី។ រួមមកអរិយធម៌ គឺធម៌ទាំងឡាយណាដែលធ្វើឱ្យមានការរីកចំរើនលូតលាស់ប្រសើរខ្ពង់ខ្ពស់ថ្លៃថ្នូរក្នុងការរស់នៅរបស់មនុស្សក្នុងសង្គមប្រកបដោយសន្ដាបរៀបរៀបរយ សំបូរប្រដាប់ប្រើប្រាស់ ព្រមទាំងមានចំនេះ និងចំណេះស្វែងរកសុខ។ បើផ្ទួរទៅនឹងពាក្យបារាំង អរិយធម៌ត្រូវគ្នានឹងពាក្យ។

មានន័យច្រើនតាមមុខវិជ្ជា និងតាមអ្នកប្រាជ្ញ។ ក្នុងសង្គមវិជ្ជាគឺសំនុំស្ថាប័នតិចនិច ទំនៀមទំលាប់ជំនឿ ដែលកំណត់លក្ខណៈ និងសភាពនៃសង្គមណាមួយ។ ក្នុងសីលវិជ្ជាមានន័យផ្ទុយទៅវិញ គឺជាសភាពខ្ពង់ខ្ពស់នៃអរិយធម៌ដែលមានកំនត់

សំគាល់តាមភាពជឿនលឿននៃតិចនិចសង្គម សីលធម៌ និងអភិវឌ្ឍន៍គំនិតផ្ទុយពីសភាពព្រៃផ្សៃ។

សញ្ញាណទំនើបនៃអរិយធម៌បង្ហាញនូវទំនាក់ផ្តាច់មិនបានរវាងធាតុសំភារៈ និង ធាតុគំនិត។ លោកឱ្យន័យថា "អរិយធម៌ជាសំនុំសាំញ៉ាំនៃបាតុភូត សង្គមនៃធម្មជាតិកំរើកសំដែងជាលក្ខណៈសាសនា សីលធម៌ សិល្បរស តិចនិច ឬស្បង់ និងជាលក្ខណៈរួមរបស់សង្គមធំមួយ។ តាមន័យនេះ អរិយធម៌មិនមែនជាតំលៃទេ គឺគ្រាន់តែជាសភាពលក្ខណៈនៃការរស់នៅរបស់សង្គមមនុស្ស។ អរិយធម៌មានន័យទូលាយណាស់ដូចពោលបញ្ជាក់រួចមកស្រាប់។ យើងអាចបង្រួមន័យឱ្យខ្លីមកវិញ គឺថាអរិយធម៌ជា សភាពពិតនៃជីវភាពសង្គមមាន ទំនៀមទំលាប់ អង្គការច្បាប់ ចិត្តគំនិត និងគ្រឿងប្រើប្រាស់សព្វបែបយ៉ាង ឬជាតំលៃ ដែលសង្កត់ទៅលើការចំរើនលូតលាស់ទាំងគំនិតប្រាជ្ញា ទាំងសំភារៈ ផ្ទុយពីសភាពព្រៃផ្សៃ។ សេចក្តីថា អរិយធម៌ធ្វើឱ្យចំរើនឆ្ពោះទៅរកសុខៈ។ ដើម្បីសំរេចសុខៈបានដូចបំនង តើអរិយធម៌ពឹងលើកំលាំងនៃធាតុអ្វីខ្លះ?

ធាតុសំខាន់ដែលជាទំរទំរង់អរិយធម៌ គឺវប្បធម៌ និងសង្គមធម៌។ វប្បធម៌ គឺធម៌ទាំងឡាយណា ដែលធ្វើឱ្យចំនេះចេះដឹងរីកដុះដាល លូតលាស់ដោយផ្សាំ ឬភ្ញាស់ គំនិតប្រាជ្ញា ស្មារតីឱ្យរឹងប៉ឹងតាមអក្សរសាស្ត្រ តាមស្បង់ តាមអប់រំ។ បើផ្ទួរទៅនឹង ពាក្យបារាំង វប្បធម៌ ត្រូវនឹងពាក្យ។ ន័យដើមគឺការងារទាក់ទងនឹងដីដាំផ្សេងៗ។ ក្រោយមកមានន័យក្លាយបន្តិច គឺត្រលប់ជាកិច្ចការគំនិតទៅវិញ អាល្លឺម៉ង់ថា មានន័យត្រឹមតែការចំរើនលូតលាស់តាមផ្លូវចិត្តតែប៉ុណ្ណោះ។ រួចមកវប្បធម៌ជា ធម៌ដែលផ្ទុះ ឬភ្ញាស់ចំណេះចំណឹង មានជំនឿសាសនា ស្បង់ជាដើម តាមភាសាអក្សរ សាស្ត្រសិល្ប៍ សិល្បៈ និងអនុវត្តជាទំលាប់ទំនៀមប្រពៃណីអប់រំល្បែងជាអាទិ៍។

ចំណេះចំណើងពុំនៅតែឯកឯងទេ  គឺគេតែងតែយកទៅប្រតិបត្តិផ្តើត ប្រដាប់ប្រើប្រាស់រៀបចំសង្គមឱ្យមានរបៀបរបបជា  សេដ្ឋកិច្ច  សង្គមកិច្ច នយោបាយនិងធ្វើឱ្យមានទំរង់លក្ខណៈល្អប្រសើរឡើង ។  កិច្ចប្រតិបត្តិធ្វើឱ្យសង្គម មានសំភារៈប្រើប្រាស់មានរបបគ្រប់គ្រងនិងទំរង់ល្អនេះគេហៅថា  សង្គមធម៌ ។ សេចក្តីថា សង្គមធម៌ ជាធម៌ ឬជាធាតុវិធី ឬធម៌ភាពរៀបចំសង្គមមនុស្សឱ្យមាន សភាពទំរង់លក្ខណៈជឿនលឿនឡើង ។

អរិយធម៌អាចចំរើនរុងរឿង ហើយអាចចុះដុនដាបទៅវិញ ។ ក្នុងសៀវភៅ Declin de locceident លោក Oswald spengler ពោលថាអរិយធម៌ចំរើនងើប ឡើងដល់កំពូលកាលណាធាតុផ្សំអរិយធម៌នោះវិវត្តន៍ស្របគ្នាមានទំនាក់ទំនងគ្នា ប្រសើរ ហើយស្រុតចុះវិញ ឬស្លាប់តែម្តង កាលណាអរិយធម៌នេះមានទំនាស់ ផ្ទៃក្នុង មានសេចក្តីថា កាលគេឱ្យតំលៃខ្លាំងពេកទៅលើធាតុមួយហើយបោះបង់ ចោលធាតុផ្សេងទៀត ។ ភស្តុតាងច្បាស់គឺ អរិយធម៌ខ្មែរសម័យអង្គរដែលបាន ឡើងដល់កំពូលពីសតវត្សទី៩ដល់១៣ ដោយសារគ្រឹះវប្បធម៌ និងសង្គមធម៌វិវត្តន៍ ត្រូវចង្វាក់គ្នា ហើយធ្លាក់ចុះវិញនៅចុងសតវត្សទី១៣ គឺដោយសារបុព្វបុរសខ្មែរ យើងសម័យនោះឱ្យតំលៃខ្លាំងពេកទៅលើសាសនាសាងប្រាសាទតាមមហិច្ឆតា ដើម្បីបំពើងកិត្តិយសផ្ទាល់ខ្លួនខ្ជះខ្ជាយទ្រព្យ និងកំលាំងមនុស្សសំរាប់ពិធីសក្ការៈ បូជា ជាហេតុនាំឱ្យសេដ្ឋកិច្ចចុះខ្សោយ ។ សង្គមធម៌បោះជំហ៊ានមិនខានវប្បធម៌នេះ ជាកត្តាមួយ សំខាន់ធ្វើ ឱ្យអរិយធម៌អង្គរ រលំគ្រេងតែម្តង ។ ដូចនេះក្នុងការកសាង ជាតិគេត្រូវរៀបចំគ្រប់មែកធាងអរិយធម៌មានដំណើរការទៅមុខព្រមគ្នា ត្រូវ ចង្វាក់គ្នា មិនត្រូវឱ្យតំលៃទៅលើតែធាតុមួយ ហើយបោះបង់ចោលធាតុមួយទៀត ឡើយ ។

ប្រធានទី ២

## គោលគំនិត

### ក- កំលាំងអរិយធម៌ស្ថិតលើវប្បធម៌

១- វប្បធម៌ភ្ញាស់គំនិត

- អ្នកអក្សរសាស្ត្រ
- ស្បង់
- អប់រំ

២- គំនិតជាអំនាចអាច

- ប្តូរទំរង់សង្គម
- ផ្តើនកំរិតជីវភាព
- ផ្តើនចរិយាឱ្យថ្លៃថ្នូរ
- ផ្តើនច្បាប់គ្រប់គ្រងត្រឹមត្រូវ សេចក្តីថាផ្តល់សុខដល់សង្គម

៣- ដូចនេះវប្បធម៌ជាកំលាំងធ្វើឱ្យអរិយធម៌ជឿនលឿន

### ខ. កំលាំងអរិយធម៌ស្ថិតនៅលើសង្គមធម៌

១- សង្គមធម៌សំគាល់លើការលូតលាស់ផ្នែកសំភារៈសង្គម

- ប្រដាប់ប្រើប្រាស់
- តិចនិចផ្តើនផល
- វិធីរៀបចំសង្គម សេដ្ឋកិច្ច នយោបាយ សង្គមកិច្ច

២. សង្គមធម៌អាចប្តូរជីវភាព

- ជីវិតប្តូរគំនិតទស្សនៈមនុស្ស
- ប្តូរនយោបាយ សេដ្ឋកិច្ច តិចនិចផ្តើតផល ទស្សនៈចំនួល ជំនឿមនុស្សប្តូរទៅតាមនោះដែរ
- សង្គមលូតលាស់ ជំនឿសាសនាថយចុះ

៣. ដូចនេះអរិយធម៌ទៅមុខ ឬថយក្រោយស្រេចតែសង្គមធម៌

**គ- ពិភាក្សា :**

តាមពិតអរិយធម៌ទៅមុខឬថយចុះលឿន ឬមិនលឿនពុំមែនមកពីកំលាំងវប្បធម៌ ឬសង្គមធម៌តែឯកឯងទេ គឺមកពីកំលាំងរួម :

-អរិយធម៌ជឿនលឿន កាលណាវប្បធម៌បោះជំហ៊ានទៅមុខត្រូវចង្វាក់គ្នា។ សេចក្តីថាត្រូវរៀបចំគ្រប់មែកធាងឱ្យប្រទាក់ប្រទងគ្នាជាចង្វាក់។

- វប្បធម៌ជឿនលឿនតែម្នាក់ឯង សង្គមធម៌ទន់ខ្សោយ អរិយធម៌ស្រុតចុះ។ ភស្តុតាងច្បាស់គឺអរិយធម៌អង្គរដែលឡើងដល់កំពូល ពីសតវត្សទី ៩ ដល់ទី ១៣ ដោយសារគ្រឹះវប្បធម៌"មានសាសនាជាដើម" និងគ្រឹះសង្គមធម៌ សេដ្ឋកិច្ចសង្គមកិច្ចដើរត្រូវចង្វាក់គ្នា។ ក្រោយសតវត្សទី ១៣ អរិយធម៌អង្គររលំគ្រេងដោយសារអ្នកដឹកនាំរៀបតែងផ្នែកវប្បធម៌ "សាងប្រាសាទដើម្បីសក្ការៈបូជាដើម្បីកិត្តិយសផ្ទាល់ខ្លួន មិនគិតពីសង្គមធម៌ " សេដ្ឋកិច្ចធ្លាក់ចុះ សង្គមកិច្ចធ្លាក់ប្រេះឆា។

- សង្គមធម៌ជឿនលឿនម្នាក់ឯង វប្បធម៌តាមមិនទាន់ អរិយធម៌ធ្លាក់ចុះមួយរំពេច។ ឧទាហរណ៍ : សម័យសង្គមរាស្ត្រនិយម៌វប្បធម៌តាមមិនទាន់សង្គមធម៌។

- សាលារៀន វិទ្យាល័យដុះដូចផ្សិត តែត្រូវមានចំនួនតិចតួចខ្វះវិជ្ជាគរុកោសល្យ កម្មវិធីសិក្សាបែបផ្សងព្រេងជាគ្រោះថ្នាក់មួយ ផ្តល់ឱ្យសង្គមជាតិ។

- សង់ផ្ទះពេទ្យគ្រាន់តែជាការលំអរ ខ្វះថ្នាំ ខ្វះគ្រូពេទ្យមានសមត្ថភាព។

- នាំគ្នាសង់បង់ថ្ម ដើម្បីបង្អួតទេសចរណ៍។

- ពេលមានភ្ញៀវបរទេស គេអំពាវនាវឱ្យស្លៀកពាក់ស្អាតបាត ដើម្បីទាញសំណើចពីមហាមិត្ត ។

- នាំគ្នាធ្វើបដិវត្តន៍ ដោយមិនបានភ្ញាស់គំនិតបដិវត្តន៍ បដិវត្តន៍នោះរសាត់គ្មានទិសដៅពង្រីកសង្គមធម៌ មិនបានពង្រីកវប្បធម៌សេចក្តីគ្រឹះទាំងពីររឹងមិនស្មើនឹងអរិយធម៌ឃ្លេងឃ្លោង ដូចនេះអរិយធម៌ក៏កើតវិវត្តន៍លូតលាស់ឬលិចលង់គឺដោយសារទំនាក់ទំនងរវាងគ្រឹះទាំងពីរកំលាំងរួមរបស់វប្បធម៌និងអរិយធម៌នេះឯង។

## ប្រធានទី ៣

### ទំនាក់ទំនងរវាងអរិយធម៌បរទេសនិងអរិយធម៌ខ្មែរ

ជនជាតិមួយដែលរស់នៅលើទឹកដីរបស់ខ្លួន តែងកសាងអរិយធម៌ខ្លួនតាមទស្សនៈ ចំនួលចិត្ត និងតាមធម្មជាតិព្រមទាំងប្រទេសធម្មជាតិមនុស្សនេះឯង។ ការរស់នៅតំរូវអោយជនជាតិនិមួយៗ ប្រាស្រ័យទាក់ទងគ្នាតាមវិស័យនយោបាយ សេដ្ឋកិច្ច វប្បធម៌ជាដើម ជាហេតុនាំឱ្យគ្មានអរិយធម៌ណានៅបរិសុទ្ធដូចដើមឡើយ គេតែងទទួលនិងជះឥទ្ធិពលទៅវិញទៅមក ហើយជាកត្តាមួយធ្វើឱ្យមានការរីកចំរើនផងថែមទៀត។ យ៉ាងណាមិញជនជាតិខ្មែរដែលធ្លាប់មានអរិយធម៌ខ្ពង់ខ្ពស់ពីបុរាណកាលមកក៏បានជះឥទ្ធិពលទៅលើជនជាតិជិតខាងផងនិងទទួលឥទ្ធិពលបរទេសមកវិញផងដែរ។ តើខ្មែរបានទទួលឥទ្ធិពលអរិយធម៌ជនជាតិណាខ្លះ? ទទួលដល់កំរិតណា?

អ្នកសិក្សាអំពីជាតិសាសន៍បានសន្និដ្ឋានថា ខ្មែរជាជនជាតិស្ថិតក្នុងអំបូរខ្មែរ មនទាំងពូជមនុស្សនិងភាសាដែលជាអំបូរធំមួយក្នុងសកលលោក។ ជនជាតិខ្មែរមនបានមករស់នៅលើជ្រោយសុវណ្ណភូមិនេះតាំងពីច្រើនសតវត្សមុនគ្រិស្តសករាជ ព្រមទាំងមាន មូលធម៌ អរិយធម៌ច្បាស់ប្រាកដរបស់ខ្លួន។ ក្នុងវិស័យវប្បធម៌ក៏ដូចសង្គមធម៌ដែរ ជនជាតិនេះមានប្រព័ន្ធអរិយធម៌ពិតពុំមែនដូចការស្មានរបស់ជនខ្លះថាខ្មែរជាជនជាតិគ្មានអរិយធម៌នោះទេ។ ជំនឿថាមានព្រលឹងការគោរពអរក្សអ្នកតាការចាត់ទុកស្ត្រីជាធំក្នុងគ្រួសារលក្ខណៈពិសេសរបស់ភាសាជាប្រព័ន្ធវប្បធម៌ជាតិ។ ផ្នែកសង្គមធម៌គេដឹងថាខ្មែរជាជាតិប៉ិនប្រសប់ខាងរបរកសិកម្មមានតិចនិចពង្រីកនយោបាយទឹកជាអាទិ៍។

ចាប់ពីដើមសតវត្សទី ១ នៃគ្រិស្តសករាជមកជនជាតិឥណ្ឌាបាន មកដល់ជ្រោយឥណ្ឌូចិននេះក្នុងគោលបំណងរកគ្រឿងទេសនិងផលិតផលកំដរផ្សេងទៀតដើម្បីបំពេញមុខរបរជំនួញរបស់ខ្លួន។

នៅពេលនោះអរិយធមិឥណ្ឌា ក៏បានចាប់ផ្សព្វផ្សាយពាសពេញអាស៊ីអាគ្នេយ៍ ។ ជនជាតិឥណ្ឌាបានបង្រៀនសាសនារបស់ខ្លួនដល់ម្ចាស់ស្រុកភ្ជាប់ជាមួយភាសាពិសិដ្ឋ "សំស្ក្រឹត" ព្រមទាំងសិល្បៈ ដែលជាមធ្យោបាយសំដែងផ្សាយ សាសនា ច្បាប់ អង្គការ សង្គមកិច្ច ស្បង់ និងតិចនិច ។ ខ្មែរមានទេពកោសល្យខាងធ្វើសម្មានកម្ម មេរៀនឥណ្ឌាដើម្បីទាញយកផ្នែកខ្លះដែលស្របគ្នានិងអរិយធមិ និងការលៃ អ្វីដែលទើសទាល់ឱ្យស្របស្រួលនិងលក្ខណៈជាតិ ។ មិនតែប៉ុណ្ណោះ ខ្មែរទាញយក គំរូដើមមកបង្កើតដោយផ្សែផ្សំធាតុថ្មីជាអរិយធមិមួយថ្មីមិនទើសទាល់និងចំនួល ចិត្តខ្មែរឡើយ ។

លំនាំឥណ្ឌាលំអោនតាមខ្មែរ ចេញជាលទ្ធិផលច្បាស់នៅសម័យអង្គរ ជាផ្លែ ផ្កាមួយមានដើមកំនើតឥណ្ឌាក៏ពិតមែនតែមានលក្ខណៈប្លែកពីលក្ខណៈដើម ត្រលប់ ជាមានលក្ខណៈពិសេសជាខ្មែរទៅវិញ ។ ឥណ្ឌាមានត្រឹមគំនិត តែខ្មែរចេះយកគំនិត មកស្រាយចេញជារូបពិតដូចជាយកទស្សនៈព្រាហ្មណ៍មកសាងក្រុង ឬប្រាសាទជា និមិត្តរូប ហើយមានប្រយោជន៍ដល់សេដ្ឋកិច្ចទ្រទ្រង់អរិយធមិអង្គរថែមទៀត ។

ក្រៅពីឥណ្ឌា ខ្មែរធ្លាប់មានទំនាក់ទំនងជាមួយជនជាតិច្រើនទៀតមាន ចិន ចាម ជ្វា ជាដើម ។ ពាក់កណ្ដាលសតវត្សទី៣ រាជទូតចិនមកដល់ស្រុកខ្មែរ ការប្ដូរទូតរវាងចិនខ្មែរក៏ចាប់ផ្ដើម ។ ទំនាក់ទំនងនយោបាយនិងសេដ្ឋកិច្ចរវាងខ្មែរ និងចិនបានឱ្យអរិយធមិទាំងពីរជ្រាបចូលគ្នាទៅវិញទៅមក ។ ក្បាច់រចនាលំអ ប្រាសាទនានានៅអង្គរជាភស្ដុតាងបញ្ជាក់ឥទ្ធិពលនេះ ។ ឥទ្ធិពលចាម ជ្វា ហូរចូលមកចាប់ពីសតវត្សទី៩ ។ ស្ថាបត្យកម្មអំពីក្បាច់រចនាប្រាសាទភ្នំ សំលៀក បំពាក់ រូបបដិមា បានបង្ហាញនូវឥទ្ធិពលនេះឯង ។ ក្រោយសតវត្សទី១៣ ឥទ្ធិពលសៀម យួន បានចូលមកក្នុងសង្គមខ្មែរ ។

មិនតែប៉ុណ្ណោះជនជាតិអឺរ៉ុបក៏បានមកផ្សាយឥទ្ធិពលរបស់ខ្លួនដែរ ។ ចាប់ពីសតវត្សទី១៦មក ខ្មែរធ្លាប់នៅក្រោមនឹមអាណានិគមអឺរ៉ុបអស់ជិតមួយសតវត្សម្ល៉ោះហើយអរិយធម៌អឺរ៉ុបបានជ្រួតជ្រាបចូលក្នុងអរិយធម៌ខ្មែរ ដូចជាទំលាប់ចាប់ដៃ ងក់ក្បាល ស្លៀកពាក់ កិច្ចការរដ្ឋបាលលទ្ធិប្រជាធិបតេយ្យ ជាដើម ។

រួមសេចក្តីមកមជ្ឈដ្ឋានភូមិសាស្ត្រតំរូវអោយបើកទ្វារចំហទទួលអរិយធម៌បរទេសតាមរយៈជនជាតិបរទេសដែលមកកាន់ជ្រោយឥណ្ឌូចិន ដើម្បីធ្វើជំនួញ រឺបំពេញបំណងផ្សេងៗទៀត ។ ដូចនេះហើយបានជាគេឃើញមានជនជាតិបរទេសជាច្រើនគ្រប់មែកធាងអរិយធម៌ មានសិល្បៈ អក្សរសិល្ប៍ ជំនឿ នយោបាយ ប្រព័ន្ធរឺ ឥទ្ធិពលបរទេសបានរំលើងហើយចូលខ្លួនមកជំនួសអរិយធម៌ដើមរបស់ខ្មែរនោះទេ តែផ្ទុយទៅវិញមូលធម៌មនខ្មែរបានច្នៃលទ្ធិបរទេស ព្រមទាំងធ្វើសម្មានកម្មទាញ យកធាតុបរទេសមកផ្សៃផ្សំជាអរិយធម៌មួយកាន់តែរុងរឿងថែមទៀត ព្រមទាំងមានលក្ខណៈពិសេសរបស់ខ្លួនឯង ។

៑៑៑

## ប្រធានទី៤

**អ្នកប្រាជ្ញម្នាក់និយាយថា:**
" ខ្លឹមសារបរទេសឋិតថេរក្នុងវប្បធម៌ជាតិបានក៏ដោយសារ ស្របស្រួលជាមួយមូលដ្ឋានជាតិផងដែរ "
អាស្រ័យហេតុនេះ អរិយធម៌ឥណ្ឌាដែលជ្រាបចូលមកចាក់ឫស គល់ក្នុងសង្គមខ្មែរបាន
តើអរិយធម៌ទាំងពីរមានលក្ខណៈស្របស្រួលគ្នា យ៉ាងណាខ្លះ ?

មនុស្សរស់នៅជាក្រុម លើទឹកដីរបស់ខ្លួនមានព្រំដែនជាក់លាក់ក្រោមរបប គ្រប់គ្រងមួយមានប្រពៃណី មនោគម សាសនា ជំនឿរួមកើតជាអរិយធម៌របស់ជន ជាតិតែងទទួលឥទ្ធិពលពីអរិយធម៌របស់ជនជាតិខ្លាំងជាង និងជះឥទ្ធិពលខ្លួនទៅលើ អរិយធម៌ ជនជាតិណាដែលមានកំលាំងខ្សោយជាង។ ប៉ុន្តែការជះឥទ្ធិពលនេះអាច មានជីវិតឋិតថេរជាមួយគ្នាបានលុះត្រាតែមានលក្ខណៈមិនទើសទាល់និងគ្នា ដូច សំដីអ្នកប្រាជ្ញម្នាក់និយាយថា "ខ្លឹមសារបរទេសអាចឋិតថេរក្នុងវប្បធម៌ជាតិបាន ក៏ដោយសារស្របស្រួលជាមួយ មូលដ្ឋានជាតិផងដែរ" ។ អាស្រ័យហេតុនេះ អរិយធម៌ឥណ្ឌាដែលចាក់ឫសក្នុងសង្គមខ្មែររាប់សតវត្សមកហើយ មានលក្ខណៈ ស្របស្រួលនឹងមូលដ្ឋានអរិយធម៌ខ្មែរត្រង់ណាខ្លះ?

អរិយធម៌សំគាល់ការចំរើនលូតលាស់នៃប្រទេសនិមួយៗ ក្នុងវិស័យ វប្បធម៌ខ្ពង់ខ្ពស់បានផ្សាយឥទ្ធិពលរបស់ខ្លួនមកពាសពេញអាស៊ីអាគ្នេយ៍ "លើក លែងតែវៀតណាមនិងហ្វីលីពីនចេញ"។ ប្រទេសខ្មែរបានទទួលឥទ្ធិពលនេះយ៉ាង សន្ធឹកសន្ធាប់ ប៉ុន្តែពុំមានន័យថា អរិយធម៌ខ្មែរជាអរិយធម៌ឥណ្ឌាទេ ព្រោះមុនពេល ឥណ្ឌាមកដល់ "ហ៊ុនទៀន ឬកៅណ្ឌិន្យ " ខ្មែរបានកសាងរដ្ឋរបស់ខ្លួនមានអធិប តេយ្យភាពរួចទៅហើយ ។

ការប៉ះទង្គិចនឹងធាតុនៃអរិយធម៌ថ្មី ធ្វើឱ្យមានកំណែច្នៃគ្នាទៅវិញទៅមក ហើយធាតុណាមានលក្ខណៈស្របស្រួលគ្នាក៏បន្តជីវិតចាក់ឫសគល់រហូតមក អ្វីដែលទើសទាល់នឹងមូលដ្ឋានជាតិក៏រលាយខ្លួនទៅវិញផង ដូចជាក្នុងវិស័យវប្បធម៌ឥណ្ឌាបាននាំមកនូវសាសនាធំៗពីរគឺ សាសនាព្រាហ្មណ៍និងពុទ្ធសាសនា តែខ្មែរមានលទ្ធិនិងជំនឿដើមរបស់ខ្លួនរួចទៅហើយដែរ ដល់ជំនឿនេះស្របគ្នាក៏រលាយចូលគ្នាតែម្តង។ យ៉ាងណាមិញ ខ្មែរធ្លាប់គោរពអ្នកតាដែលគេយកដុំថ្មជាតំណាងទីលំនៅអ្នកតាមានគ្រប់ទីកន្លែងដូចជា អ្នកតារក្សាស្រុកនៅក្នុងស្រុក អ្នកតារក្សាភ្នំនៅលើភ្នំ។ ត្រង់នេះស្របគ្នានឹងលទ្ធិសាសនាហិណ្ឌូ ដែលគោរពបូជាព្រះសិវៈដែលមានឈ្មោះថា គិរីស ប្រែថាអ្នកម្ចាស់ភ្នំឬអ្នកដេកលើភ្នំទាំងពីរក៏រលាយចូលគ្នា ហើយចេញជាពិធីទេវរាជនៅសម័យអង្គរ។ ពិធីទេវរាជធ្វើនៅភ្នំដែលព្រះបាទជ័យវរ័ន្មទី២ ចាប់ផ្តើមជាលើកដំបូងនៅលើភ្នំគូលែនដើម្បីអភិសេកស្តេចឱ្យទៅជាទេវរាជគឺស្តេចជាអាទិទេព។ ពិធីទេវរាជតំរូវឱ្យមានសំនង់ប្រាសាទភ្នំដែលជាប្រាសាទដ៏ល្អពិសេសរបស់ខ្មែរ ហើយដែលគ្មាននៅប្រទេសឥណ្ឌា។ ទំនៀមទំលាប់ប្រពៃណីខ្លះទៀតក៏បានរលាយចូលគ្នាជាច្រើនអន្លើដែរ ដូចជាពិធីរំលាយសព ពិធីអាពាហ៍ពិពាហ៍ បុណ្យទានផ្សេងៗដូចជា បុណ្យភ្ជុំបិណ្ឌ បុណ្យកឋិនជាដើម។ បុណ្យភ្ជុំបិណ្ឌជាពិធីមួយលេចចេញពីការផ្សែផ្សំជំនឿខ្មែរ គឺការគោរពមេបា "បុព្វបុរស " ដែលមានលទ្ធិបុគ្គលនិយមក្នុងរាជឥន្ទ្រវរ័ន្មទី ១ "សម័យអង្គរ" ជាភស្តុតាងជាមួយជំនឿពុទ្ធសាសនា។ ម្យ៉ាងទៀតខ្មែរជឿថាមនុស្សស្លាប់ទៅហើយមិនសាបសូន្យទេគឺមានព្រលឹងចេញទៅចាប់កំនើតម្តងទៀត ស្របនឹងជំនឿព្រាហ្មណ៍ស្តីពីអាត្មន។ ពុទ្ធសាសនាថាគ្មានព្រលឹងទេ តែថាស្លាប់ហើយកើតវិញដូចនេះស្របគ្នាត្រង់ស្លាប់ហើយកើតវិញ។ លក្ខណៈស្របស្រួលនឹងមូលដ្ឋានជាតិនេះហើយដែលធ្វើឱ្យជំនឿសាសនាទាំងពីរមានជីវិតជាប់នឹងសង្គមខ្មែររហូតមក។ ប៉ុន្តែពុំមែនខ្មែររក្សាលក្ខណៈសាសនាទាំងនោះដូចដើមទេ

គឺក្លាយជាលក្ខណៈពិសេសមួយផ្សេងពីឥណ្ឌាផងថែមទៀត ព្រោះលទ្ធិព្រាហ្មណ៍និងពុទ្ធសាសនារលាយចំរុះចូលគ្នាចូលក្នុងលទ្ធិជំនឿខ្មែរតាមវិធីសំយោគមួយប្រកបដោយវិចារណកថានិងសង្គមភាព។

ក្នុងវិស័យភាសាវិញមានទំនាស់គ្នាខ្លាំងណាស់ ព្រោះភាសាខ្មែរស្ថិតក្នុងអំបូរ-មនខ្មែរ ដែលមានមូលធមិដាច់ដោយឡែកពីភាសាបាលីសំស្ក្រឹតដែលស្ថិតក្នុងអំបូរឥណ្ឌូ-អឺរ៉ុប ទំនាស់ត្រូវខ្មែរសំរួលច្នៃអ្វីដែលទើសទាល់ឱ្យស្របស្រួលមកវិញតាមមូលវិធីខេមរនីយកម្មប្រកបដោយវិចារណភាព សង្គមភាព និងវឌ្ឍនភាព ព្រោះជាវិធីចំរាញ់ពូតយកខ្លឹមសារបរទេសមកចាក់ចូលក្នុងវប្បធមិជាតិដើម្បីពង្រឹងមូលដ្ឋាននេះឱ្យកាន់តែរឹង និងរីកធំធាត់ឡើង។

ក្នុងសង្គមធមិវិញក៏ដូចនេះដែរ។ វិស័យសេដ្ឋកិច្ចក្ដី នយោបាយក្ដី សន្តិសុខក្ដី សុទ្ធតែបានរលាយចូលគ្នាក្នុងផ្នែកខ្លះដែលស្របស្រួលគ្នាហើយការលៃអ្វីដែលទើសទាល់ឱ្យស្របតាមមូលដ្ឋានជាតិ អ្វីដែលទើសខ្លាំងពេករលាយទៅវិញ។

ភស្តុតាងដែលបង្ហាញមកនេះ បញ្ជាក់ឱ្យឃើញថា ខ្លឹមសារបរទេសអាចនៅឋិតថេរក្នុងវប្បធមិជាតិបានក៏ដោយសារស្របស្រួលនឹងមូលដ្ឋានជាតិ។ យ៉ាងណាមិញទស្សនៈពើងនិយមរបស់ឥណ្ឌា គឺចូលចិត្តបំពើងរឿងពិតឱ្យខ្ពស់ ឡើងផុតពីតថភាពឱ្យទៅជាអច្ឆរិយៈ ត្រូវខ្មែរទាញមករកពិតនិយមទៅវិញដើម្បីសំរបសំរួលតាមចំនូលចិត្តជាតិយើង។ ដូចជាព្រះរាម ជាក្សត្រដែលឥណ្ឌាខំបំពើងឱ្យទៅជាអវតាព្រះវិស្ណុ ត្រូវបានកវីខ្មែរខំទាញមកជាមនុស្សសាមញ្ញទៅវិញ។ រឿងរាមកេរ្តិ៍ឋិតថេរបានយូរក្នុងវប្បធមិជាតិ ត្រង់លក្ខណៈមនុស្សនិយមនេះឯង។ នេះជាភស្តុតាងបញ្ជាក់ឱ្យឃើញរឿងរាមកេរ្តិ៍ពុំមែនជាការចំលងតាមរាមាយណៈឥណ្ឌាទេ តែជានិម្មិតកម្មរបស់ខ្មែរនេះទៅវិញ។

ចំលងឥទ្ធិពលអរិយធម៌ពីជាតិមួយទៅជាតិមួយពុំមែនជាកំហុសអ្វីឡើយ តំលៃពិតនៅត្រង់ចេះយកមូលដ្ឋានជាតិមកចំរាញ់ យកខ្លឹមសារបរទេសមកធ្វើជាជីជាតិដើម្បីធ្វើឱ្យអរិយធម៌ខ្លួនចំរើន ពីព្រោះជីវភាពតំរូវឱ្យមានទំនាក់ទំនងគ្នាគ្រប់វិស័យ ម្ល៉ោះហើយការឆ្លងចុះឆ្លងឡើង ជាការធម្មតាទេ។ គេចាត់ទុកថាខ្មែរជាជនជាតិមានអរិយធម៌ខ្លាំងត្រង់សមត្ថភាពអាចធ្វើខេមរនីយកម្មប្រកបដោយវិចារណភាពឱ្យខ្លឹមសារបរទេសមកជាកំលាំងអរិយធម៌ជាតិនេះឯង។

## ប្រធានទី ៥

> អ្នកខ្លះយល់ថា
> " ខ្មែរជាជាតិមួយមានពូជអំបូរ ជាប់នឹងជនជាតិឥណ្ឌា"
> តើមានយោបល់ដូចម្តេច?

ដើម្បីសិក្សាអរិយធម៌របស់ជនជាតិណាមួយគេត្រូវស្គាល់ពូជអំបូរជាតិនោះសិន ព្រោះអំបូរជាតិសាសន៍ជាមូលធម៌សំរាប់ជួយបំភ្លឺការសិក្សាឱ្យកាន់តែជាក់ច្បាស់ឡើង។ ក្នុងការសិក្សាអរិយធម៌ខ្មែរបញ្ហាពូជអំបូរចោទឡើងជានិច្ច ហើយសព្វថ្ងៃអ្នកសិក្សាពុំទាន់ចុះសំរុងគ្នានៅឡើយ។ ខ្លះយល់ថា "ខ្មែរជាប់ពូជអំបូរជាមួយឥណ្ឌា" ខ្លះថា "ជាជាតិដោយឡែកពីឥណ្ឌា" តើខ្មែរជាប់អំបូរក្នុងក្រុមណា ?

អ្នកដែលយល់ថាខ្មែរជាជនជាតិជាប់ពូជសាសន៍នឹងឥណ្ឌាច្រើនតែសំអាងទៅលើកំណត់ប្រវត្តិសាស្ត្រតាមឯកសារចិន ស្តីពីការបង្កើតរាជវង្សជាដំបូង របស់ហ៊ុន ទៀន នៅលើរដ្ឋហ្វូណន។ សិលាចារឹកចាមនៅ មី សឺន គ.ស ៦៥៨ បានកត់ត្រាថា ព្រាហ្មណ៍ កៅណ្ឌិន្យ បានទទួលលំពែងពីព្រាហ្មណ៍អស្សត្ថាម៉ន ហើយមករៀបអភិសេកជាមួយនាង សោមា។ រឿងព្រេងខ្មែរក៏មានតំណាលពីអាពាហ៍ពិពាហ៍ ព្រះថោង និងនាងនាគដែរ។ ហ៊ុន ទៀន ឬកៅណ្ឌិន្យ ឬព្រះថោង អ្នកសិក្សាខ្លះចាត់ទុកថាជាជនជាតិឥណ្ឌាដែលមកបង្កើតរាជវង្សគ្រប់គ្រងណៅហ្វូន។ អ្នកប្រវត្តិសាស្ត្រខ្មែរម្នាក់បានអះអាងថា " ខ្មែរជាឥណ្ឌាទី ២ " សេចក្តីថាខ្មែរជាជនជាតិមានកំណើតនៅឥណ្ឌា រស់នៅក្នុងរដ្ឋកុមេរុ។ ក្រោយមក កុមេរុក្លាយទៅជាខ្មែរ ដូចជា ភ្នំព្រះសុមេរុ "សុម៉ែ" នេះឯង។ គេថាជនជាតិកុមេរុបានធ្វើដំនើរមកកាន់ជ្រោយសុវណ្ណភូមិដោយមានបំនងធ្វើជំនួញ ខ្លះរត់ភៀសខ្លួនមកពេលស្រុកខ្លួនមានសង្គ្រាម ហើយក៏បាននាំអរិយធម៌ខ្លួនមកផ្សព្វផ្សាយលើជនជាតិជិតខាង។

ភស្តុតាងដ៏ទៃទៀតមានលក្ខណៈ អក្សរ និងភាសា លទ្ធិសាសនា ប្រពៃណី ទំនៀមទំលាប់ គឺជារបស់ឥណ្ឌា ហើយមនុស្សទៀតសោតក៏មានលក្ខណៈដូចឥណ្ឌាផងដែរ។ រាជាធិបតេយ្យខ្មែរ មានលក្ខណៈហិណ្ឌូច្បាស់លាស់ណាស់។

លក្ខណៈមនុស្ស វប្បធម៌ សង្គមធម៌ និងកំនត់តម្រាប្រវត្តិវិទូដូចពោលមកហើយនេះ ជាភស្តុតាងបញ្ជាក់ថាខ្មែរជាប់ពូជសាសន៍ជាមួយមហាអំបូរអារ្យ៉ាន មកពីឥណ្ឌា។ ប៉ុន្តែទស្សនៈបែបនេះពុំទាន់បានទទួលយោបល់យល់ស្របពីសំណាក់អ្នកសិក្សាជាទូទៅទេ។ អ្នកសិក្សាខ្លះយល់ថា ខ្មែរជាអំបូរដាច់ដោយឡែកពីអារ្យ៉ាន ឬឥណ្ឌា។ តើខ្មែរជាអ្នកណាទៅវិញ? មានអ្វីជាភស្តុតាងបញ្ជាក់ថា ខ្មែរពុំមែនជាឥណ្ឌា?

លោកបណ្ឌិត G.Olivier បានសិក្សាតាមស្បង់ពិនិត្យផ្ទៀងផ្ទាត់លក្ខណៈមនុស្សខ្មែរ និងឥណ្ឌា បានផ្តល់លទ្ធផលថា មនុស្ស ខ្មែរ និងឥណ្ឌាមានលក្ខណៈរូបរាងកាយខុសគ្នាឆ្ងាយណាស់ ខ្មែរមានកំពស់មធ្យម ១.៦១ម និងសន្ទស្សន៍លលាដ៍ក្បាល ៨៤.៦ "ក្បាលមូល" ចំណែកឥណ្ឌាវិញ ពួកស និងពួកអារ្យ៉ានមានកំពស់ជា មធ្យម ១.៧២ម និងសន្ទស្សន៍លលាដ៍ក្បាល ៧៣.៨ "ក្បាលពយ" និងពួកខ្មៅ គឺពួកទ្រាវិឌ មានកំពស់ជាមធ្យម ១.៦២ សន្ទស្សន៍លលាដ៍ក្បាល ៧៦.២ "ក្បាលពយ"។ លទ្ធផលនៃការសិក្សាតាមវិធីស្បង់ របស់នរវិទូនេះជាភស្តុតាងជាក់លាក់មួយ អាចឱ្យយើងបដិសេធទស្សនៈថា ខ្មែរជាឥណ្ឌា។

អះអាងថា ខ្មែរជាឥណ្ឌាដោយកត្តាបង្កើតរាជវង្សខ្មែរ ជាអំនាងពុំទាន់សមហេតុផលនៅឡើយទេ ព្រោះថា ពេលដែល ហ៊ុន ទៀនមកដល់ខ្មែរមានរដ្ឋរួចទៅហើយ មានស្តេចគ្រប់គ្រងផងថែមទៀត។ ក្សត្រី លីវ យីបានលើកទ័ពទៅ ទប់ទល់និង ហ៊ុន ទៀន ជាតឹកតាងកាន់តែច្បាស់ថា ខ្មែរជារដ្ឋពេញលក្ខណៈមានទ័ពចេះច្បាំង មានគំនិតការពារអធិបតេយ្យរបស់ខ្លួន។ ដល់ពេលច្បាំងចាញ់ ហ៊ុន ទៀនអ្នកឈ្នះក៏ឡើងគ្រប់គ្រងរដ្ឋនោះទៅ នេះជាការធម្មតាពុំមែនពួក ហ៊ុន ទៀនសំលាបម្ចាស់ស្រុកអស់រលីង ហើយជញ្ជូនជនជាតិឥណ្ឌាមកនៅលើរដ្ឋថ្មីទាំងអស់នោះទេ។

រឿងព្រាហ្មណ៍ កៅណ្ឌិន្យ និងនាងសោមមា ក្តី រឿងព្រះថោងនាងនាគក្តី សុទ្ធតែបញ្ជាក់ថាមានម្ចាស់ស្រុករួចទៅហើយគឺ នាង សោម មា ឬនាងនាគនេះឯងមុនពេលកៅណ្ឌិន្យ ឬព្រះថោងមកដល់។ នេះជាភស្តុតាងមួយទៀតនាំឱ្យយើងពុំអាចទទួលថា ខ្មែរជាឥណ្ឌាបានឡើយ។

លោក Maurice Glaize អតីតអភិរក្សអង្គរបានអះអាងថា "ប្រជាជាតិខ្មែរ ជាអ្នកស្រុកដើមទទួលឥទ្ធិពលអរិយធម៌ ឥណ្ឌា"។

លោក Henri Marschal អតីតអភិរក្សអង្គរដែរ បានបញ្ចេញយោបល់ថា " ខ្មែរមិនមែនជាពូជសាសន៍ហិណ្ឌូទេ "។ សេចក្តីថា ខ្មែរជាជនជាតិមួយផ្សេងដោយឡែកពីឥណ្ឌាមានអរិយធម៌ពេញលេញរបស់ខ្លួន ហើយបានទទួលឥទ្ធិពលឥណ្ឌាខ្លះតែប៉ុណ្ណោះ។ ត្រង់ទំនៀមទំលាប់ ជំនឿសាសនា អក្សរភាសា ដែលអ្នកខ្លះយល់ថា ជារបស់ឥណ្ឌា ពុំមានប្រាកដភាពទេ ព្រោះការសិក្សាដល់ ជម្រៅបង្ហាញថាខ្មែរមានអរិយធម៌របស់ខ្លួនមុនឥណ្ឌាមកដល់ទៅទៀត។ ដល់ប៉ះទង្គិចនឹងអរិយធម៌ឥណ្ឌា អរិយធម៌ទាំងពីរ បានរលាយចូលគ្នាខ្លះ ការលៃកែច្នៃគ្នាខ្លះសំរបសំរួលតាមទស្សនៈខ្លួនកើតជាអរិយធម៌ខ្ពង់ខ្ពស់មួយឡើង។

ភស្តុតាងភ្ជាប់មកនេះ បញ្ជាក់ថាខ្មែរពុំមែនឥណ្ឌា ឬ ហិណ្ឌូ ឬ អារ្យ៉ានទេ។ តើខ្មែរជានរណា?

លោក Pierre Gourou បញ្ចេញយោបល់ថាជនជាតិមនខ្មែរជាជាតិប្រវេសន៍ទំនងជាត្រូវពួកទ្រាវិឌ ឬ អារ្យ៉ានវាយរុញច្រានពីប្រទេសឥណ្ឌាមក។ លោក Etienne Aymonier ថាក្រុមមន-ខ្មែរ-មុណ្ឌ ចុះមកពីជើងភ្នំទីបេ ក្រុមមន-ខ្មែរ ចុះមកអាស៊ីអាគ្នេយ៍ក្រុម មុណ្ឌចូលទៅឥណ្ឌា។

សេចក្ដីថាខ្មែរជាជាតិផ្សេងពីអំបូរអារ្យ៉ែន តែជាជាតិប្រវេសន៍។ ចំនែកលោក Bermard Philhppe Groslier អភិរក្សអង្គរវិញ បានអះអាងថា ជាតិខ្មែរជាជាតិមួយក្នុងអំបូរមនខ្មែរ កកើតក្នុងអាស៊ីអាគ្នេយ៍នេះតែម្ដងលោក យល់ថាអំបូរមនខ្មែរកើតឡើង ដោយបន្សំ កាត់ពូជមេលានេស៊ីយាង និង ឥណ្ឌូនេស៊ីយាង Melanesiens Indonesiens ហើយរស់នៅលើឆ្នេរសមុទ្រពី ព្រំប្រទល់ ឥណ្ឌាមក រហូតសមុទ្រចិន។

សេចក្ដីអធិប្បាយមកហើយនេះ បង្ហាញនូវទស្សនៈផ្សេងៗ ពីដើមកំនើត ជាតិខ្មែរ។ ទស្សនៈខ្លះថា ខ្មែរជាឥណ្ឌា ខ្លះថាខ្មែរជាជាតិប្រវេសន៍ តែពុំមែនឥណ្ឌា និងទស្សនៈចុងក្រោយថាខ្មែរជាជាតិមួយ កកើតក្នុងអំបូរមន-ខ្មែរនៅលើអាស៊ី អាគ្នេយ៍នេះតែម្ដង។ ទោះបីមានមតិពុំចុះសំរុងបែបនេះក៏ដោយ ក៏យើងអាច សន្និដ្ឋានបានថា ខ្មែរជាជាតិមួយមានចំនាស់ក្នុងអាស៊ីអាគ្នេយ៍ ដាច់ដោយឡែក ពីឥណ្ឌាមានអរិយធម៌ខ្ពង់ខ្ពស់ផ្ទាល់របស់ខ្លួន គឺអរិយធម៌អូស្ត្រាអាស៊ីយាទិច Austroassiatiques នេះឯង។ ជនជាតិខ្មែរបាន ផ្ដុំផ្ដើង ជាសង្គមជាតិវិវត្តន៍ និង បន្តឥទ្ធិពលរបស់ខ្លួនលើទឹកដីដូនតាព្រមទាំងផ្សព្វនូវសំនង់អរិយធម៌ជាច្រើនទុក ជាកេរ្តិ៍តំណែលតមក សព្វថ្ងៃនេះ។ ការស្គាល់ដើមកំនើតជាតិខ្លួនមិនច្បាស់នាំឱ្យ អ្នកខ្លះខំពន្យល់ភ្ជាប់ខ្មែរទៅនឹងមហាអំបូរនានា ដែលជាហេតុនាំឱ្យជនបរទេស ខ្លះឆក់ទាញយកផលប្រយោជន៍ពីនេះភ្លាម។

តាមពិតអំបូរមនខ្មែរ ជាជាតិសាសន៍ធំមួយមានអរិយធម៌ខ្ពង់ខ្ពស់ និងមាន វ័យចំនាស់ជាងគេផងទៀតលើអាស៊ីអាគ្នេយ៍យើងនេះ។

## ផ្នែកទី ២ : វប្បធម៌

ជំពូក ១

## សាសនា

### ក. សាសនាធំៗក្នុងលោក :

១- សាសនាព្រាហ្មណ៍ ឬព្រហ្មញ្ញសាសនា" Brah manisme " កំនើតនៅឥណ្ឌា ។

២- ពុទ្ធសាសនា "Bouddhisme" មានកំនើតនៅឥណ្ឌា ។

៣- សាសនាអ៊ិស្លាម "Lslamisme" មានកំនើតនៅអារ៉ាប់ ។

៤- សាសនាគ្រីស្ត "Christianisme" មានកំនើតនៅស៊ីរី ។

៥- សាសនាតៅ "Taiosme" មានកំនើតនៅប្រទេសចិន ។

៦- សាសនាស៊ិន្ត "Shintoisme" មានកំនើតនៅជប៉ុន ។

### ខ. សាសនាឥណ្ឌា

១- សាសនាព្រាហ្មណ៍ : ចែកជាបួនសម័យធំៗ

ទី ១ : សម័យអារ្យ៉ន

ជនជាតិអារ្យ៉ន មានដើមកំនើតនៅភូមិភាគ Caucase និងខ្ពង់រាប Pamit បានវាយលុកប្រទេសឥណ្ឌា "ប្រហែលជារវាង ២៥០០-១៥០០ ឆ្នាំមុនគ.ស" បាននាំជំនឿលទ្ធិផ្សេងៗមកជាមួយផង ។

២ : សម័យវេទៈ ជនជាតិដើមនៅឥណ្ឌាគឺពួកទ្រាវិឌ "Dravidiens" មានជំនឿលទ្ធិមួយរបស់ខ្លួនរួចទៅហើយ គឺគោរពធម្មជាតិដោយចាត់ទុកថាធម្មជាតិទាំងអស់សុទ្ធតែមានជីវិត "ជីវចលនិយម : Animisme " ដូចជាគោរពទឹក ដី ភ្លើង ព្រៃភ្នំជាដើម ។ ដល់ពួកអារ្យ៉ននាំលទ្ធិថ្មីមក លទ្ធិនេះពុំជំនួសជំនឿលទ្ធិចាស់ទាំងស្រុងបានទេ គឺផ្សែផ្សំគ្នាសំរបសំរួលបានជាលទ្ធិថ្មីមួយមានការចំរើនជាងមុនហៅថាលទ្ធិវេទ ។ ក្នុងលទ្ធិវេទ គេគោរពបូជាទេវៈជាច្រើនតែទេវៈធំជាងគេព្រះឥន្ទ្រ ។

ទី៣ : សម័យព្រាហ្មណ៍

មានបដិវត្តន៍ធំមួយ គឺគេរំលំព្រះឥន្ទ្រចោល ហើយកសាងទេវៈថ្មីមួយជំនួស គឺព្រះព្រហ្ម។ ហេតុដែលនាំឱ្យគេរំលំ ព្រះឥន្ទ្រ មកពីទេវៈអង្គនេះមានគុណវិបត្តិច្រើនដូចជា ផឹកស្រាស្រវឹងឡូឡា លួចប្រពន្ធពួកឥសី ច្បាំងចាញ់គេញឹកញាប់ ពេក-ល- លទ្ធិថ្មីបានបង្កើតឱ្យមាន លទ្ធិព្រហ្មចរិយៈ លទ្ធិអាត្មន លទ្ធិឧបនិស័ទ។

ទី ៤ : សម័យហិណ្ឌូ

លទ្ធិព្រាហ្មណ៍មានពុទ្ធសាសនា និងសាសនាជេនជាដើម មេសាសនាព្រាហ្មណ៍ភ្ញាក់ខ្លួនក៏បានរៀបចំធ្វើបដិវត្តន៍មួយ ទៀតដើម្បីទប់ទល់ នឹងលទ្ធិថ្មីៗលទ្ធិហិណ្ឌូ។

២-ពុទ្ធសាសនា :

ជាចលនាបដិវត្តន៍ផ្នែកគំនិតជំនឿដឹកនាំដោយព្រះពុទ្ធ នៅក្នុងសតវត្សទី ៦ មុនគ.សគឺប្រហែលគ្នានឹងគំនិតលទ្ធិព្រាហ្មណ៍និយម។ ដល់សតវត្សទី ១ នៃ គ.ស ក្នុងរាជព្រះបាទកនិស្កៈ ពុទ្ធសាសនាចែកជាពីរនិកាយ " Secte" គឺហីនយាន Petit Vehicule និងមហា- យាន " Grand Vehicule"

## គ.សាសនាខ្មែរ

មុនពួកអារ្យ៉ននាំលទ្ធិសាសនាមកផ្សាយនៅឥណ្ឌា ជនជាតិដើមទ្រាវិឌមានលទ្ធិជំនឿខ្លួនហើយ។ លទ្ធិថ្មីចូលមករលាយចូលផ្សេផ្សំនឹងលទ្ធិម្ចាស់ស្រុក។ ខ្មែរយើងក៏ដូចគ្នាដែរ មុនពេលឥណ្ឌានាំលទ្ធិសាសនាគេមក ខ្មែរយើងមានជំនឿលទ្ធិមួយមុនរួចទៅ ហើយដូចជានិយមគោរពកំលាំងធម្មជាតិ ជឿថាធម្មជាតិសុទ្ធតែមានព្រលឹងកំលាំងស័ក្តិសិទ្ធ គោរពអ្នកតា គោរពមេបាដែលយកធម្មជាតិជាតំណាងថ្ម តំណាងអ្នកតា អ្នកតាងតំណាងធម្មជាតិ រឺមនុស្សដែលស្លាប់ទៅហើយ។

ចាប់ពីសតវត្សទី ១ មកខ្មែរបានទទួលឥទ្ធិពលសាសនាធំៗពីររបស់ឥណ្ឌាគឺសាសនាព្រាហ្មន៍ និងពុទ្ធសាសនា។ ទោះបីជាយ៉ាងណាក៏ដោយក៏ឥទ្ធិពលជំនឿខ្មែរពីដើមនៅមានសេសសល់ដល់សព្វថ្ងៃនេះដែរ។

ប្រធានទី ៦

## លទ្ធិសាសនាជាអ្វី? មានកំណើតមកពីណា? មានមុខងារយ៉ាងណាខ្លះក្នុងសង្គម?

ជាតិសាសន៍នីមួយៗតែងមានពិធីជំនឿសិទ្ធិសាសនារបស់ខ្លួន។ អង្គការរដ្ឋតែងជួយជ្រោមជ្រែងពង្រីក និងការពារលទ្ធិសាសនានេះទៀតផងព្រោះសាសនាជាកំលាំងធ្វើឱ្យអរិយធម៌លូតលាស់ផងដែរ។ តើលទ្ធិសាសនាជាអ្វី? មានកំណើតមកពីណា?

### ១- លទ្ធិសាសនាជាអ្វី?

គឺជាចំនងភ្ជាប់មនុស្សទៅនឹងអាទិទេព។ គំនិតសាសនាជាប់ទៅនឹងសញ្ញាណខ្ពស់ជាងធម្មជាតិ រឺ យ៉ាងហោចណាស់ទៅនឹង អារម្មណ៍ដែលន័យពិតរបស់វត្ថុពុំមែនស្ថិតនៅលើសភាពជាក់ស្តែងដែលយើងឃើញរាល់ថ្ងៃទេ គឺមានលោកអាថ៌កំបាំងមួយទៀត ដែលនៅក្នុងនោះបរិស័ទអាចទាក់ទងបាន។ ខ្ពស់ជាងតថភាពពិសោធន៍មានវិស័យសក្ការៈជាដើម ដែលបរិស័ទអាចឈោងចាប់បាន ។ លទ្ធិសាសនាធំៗចេញមកពីអាទិទេព។ អាទិទេពសាសនាគ្រីស្តនិយាយមកកាន់ បរិស័ទកាតូលិកក្នុងគម្ពីរ ប៊ីប "Bible" អាទិទេព អ៊ីស្លាមនិយាយក្នុងគម្ពីរ កូអាន "Coran" អាទិទេពហិណ្ឌូ និយាយក្នុងគម្ពីរវេទ។

### ២- សាសនាមានកំណើតមកពីណា?

លក្ខណៈសំខាន់របស់សាសនាគឺជំនឿក្នុងអច្ឆរិយ។ ខ្លាចកំលាំងធម្មជាតិដែលមានឫទ្ធិអំនាចខ្លាំង មនុស្សក៏លើកតំកើង ធម្មជាតិ គោរព និងបំប្លែងជាអាទិទេព ជាទេវៈផ្សេងៗ។ គេជឿដោយលិ្ងតលង់ថា ភាវៈមនោគតិនោះអាចដាក់ទោសមនុស្ស បើមិនបន់ស្រន់អាចជួយគេឱ្យបានសុខសប្បាយ បើមានការគោរពបន់ស្រន់ពីមនុស្ស។ ដូចនេះពិធីសក្ការៈបូជាសាសនាក៏មានកំណើតឡើង។ ជាមួយគ្នានេះអ្នកបួស អ្នកថែរក្សាអង្គការ និងស្ថាប័នសាសនាផ្សេងៗ ក៏ចាប់ផ្តើមកើតឡើងដែរ។ ដូចជាពួកអារ្យ៉ានដែលបានចូល មកលុកប្រទេសឥណ្ឌាមានអំនាច

យ៉ាងខ្លាំងនូវកំលាំងធម្មជាតិថ្មី ហើយក៏លើកតំកើងគោរពតាមធម្មជាតិ ទាំងនោះជាអាទិទេព។

**៣- មុខងារ**

លទ្ធិសាសនាមានមុខងារមួយសំខាន់ ក្នុងការអភិវឌ្ឍន៍វប្បធម៌ជាតិ។ តាំងពីបុរាណកាលមកសាសនាច្រើន ត្រូវគេទុកជាឧបករណ៍នយោបាយសំរាប់ប្រមូលផ្តុំប្រជារាស្ត្រឱ្យមានឯកភាពជាតិដើម្បីជាកំលាំង។ ភស្តុតាងច្បាស់គឺអរិយធម៌អង្គរដែល មានការរុងរឿងកំពូលគឺ សាសនាមាន មុខងារសំខាន់ណាស់។ លទ្ធិទេវរាជដែលស្តេចជ័យវរ័ន្មទី ២ បានអនុវត្តជាលើក ដំបូង នៅលើភ្នំគូលេនជាពិធីស័ក្តិសិទ្ធមួយអាចផ្តុំកំលាំងជាតិរំដោះកម្ពុជាចេញពី អំនាចជ្វា។ សាសនានេះឯង ដែលជាគោលពង្រឹងគ្រឹះនយោបាយ និងសេដ្ឋកិច្ចសម័យអង្គររហូតដល់អ្នកខ្លះបានហៅអរិយធម៌អង្គរថាអរិយធម៌សាសនា។ នៅប្រទេសឥណ្ឌាសម័យដើមនយោបាយ ជាប់នឹងសាសនា។ ចំបាំងសាសនាពុំមែនគ្រាន់តែច្បាំងប្រកាប់ប្រចាក់ដើម្បីការពារជំនឿទេ តែជាប់ទាក់ទងនឹងនយោបាយផងដែរ នៅអឺរ៉ុបក្នុងមជ្ឈឹមកាលក៏ដូចគ្នាដែរ អំណាចសាសនាមានឫទ្ធិអនុភាពខ្លាំងជាងអំណាចរដ្ឋ អំណាចស្តេចទៅទៀត។

ប៉ុន្តែ ក្នុងសង្គមមានវណ្ណៈសាសនាអាចផ្តល់ផលអាក្រក់ដល់វណ្ណៈមួយដែលបំរើវណ្ណៈមួយ។ វណ្ណៈជិះជាន់កើតឡើងមនុស្សទៅជាល្បែងកំលាំងសង្គមដែលគ្មានអនុភាពចំពោះមុខធម្មជាតិ។

ភាពទន់ខ្សោយនៃវណ្ណៈ ត្រូវគេជិះជាន់ក្នុងការប្រយុទ្ធនឹងវណ្ណៈជិះជាន់បង្កើតឱ្យមានជំនឿថា មានជីវភាពដ៏មនោរម្យមួយ នៅបរលោកមិនខុសពីអ្នកចុះចាញ់ធម្មជាតិជឿថា មានទេវតា មានខ្មោច អារក្ស អ្នកតាឡើយ។ អ្នកខ្សត់ខ្សោយក៏ផ្សងវាសនា បណ្តែតខ្លួនក្នុងភពមនោគតិសាសនារបស់ខ្លួន ដើម្បីសេចក្តីសុខ តាមបែបផ្សេង បណ្តោយឱ្យវណ្ណៈជិះជាន់គេរស់នៅយ៉ាងសប្បាយ

ទៅទៀត។ ក្នុងពេលនេះ លទ្ធិសាសនាជានីមសីលធមិសង្កត់អ្នកខ្សត់ខ្សោយឱ្យទ្រាំរស់ក្នុងសភាពអយុត្តិធមិក្នុងទាសភាព និងពង្រឹង អំណាចរបស់វណ្ណៈអភិជន។

ឧបសគ្គវិឌ្ឍនភាពលេចចេញពីសាសនាមួយផ្នែកទៀត គឺត្រង់សាសនារារាំងល្បឿនលូតលាស់របស់ស្យង់សេចក្តីថាទាត់ចោល ទស្សនៈស្យង់និយម។ កាលពីច្រើនសតវត្សមកហើយ អំណាចព្រះវិហារបានគំរាមកំហែងស្យង់ សំលាប់អ្នកប្រាជ្ញវិទ្យាស្យង់ ជាច្រើនព្រោះគំនិតស្យង់ផ្តល់នូវសច្ចៈ ជួនកាលផ្ទុយពីគំនិតក្នុងគម្ពីរសាសនា ជាហេតុនាំឱ្យខូចអនុភាពសាសនានេះឯង។ អំណាចព្រះវិហារ ហាមឃាត់ការផ្សាយគំនិតជឿនលឿន ចាប់អ្នកជឿនលឿននិយមដាក់គុក ជួនកាលចាប់ដុតទាំងរស់ តុលាការសាសនាបានប្រហារអ្នកបដិវត្តន៍គំនិតក្នុងចំណោមនោះមានអ្នកប្រាជ្ញស្យង់សំខាន់ជាច្រើនរូបដូចជា Giordane Bruno Lucilio Vanini ។ល។

ទោះបីជាយ៉ាងនេះក្តីក៏អំណាចព្រះវិហារទប់អភិវឌ្ឍន៍ស្យង់មិនជាប់។ សព្វថ្ងៃនេះ ដោយបដិសេធសមិទ្ធិស្យង់មិនកើត អ្នកកាន់អំណាចព្រះវិហារខំផ្សះផ្សារស្យង់និងសាសនា ខំស្រាយបញ្ជាក់ថា របកគំហើញស្យង់ពុំមែនផ្ទុយនិងជំនឿសាសនាទេ។ ប៉ុន្តែ ស្យង់ និងសាសនាមិនអាចជានាទីងគ្នាវិញឡើយ ទីណាស្យង់ចំរើន ទីនោះសាសនាចុះថយ ទីណាស្យង់មិនទាន់រីកចំរើន ទីនោះ សាសនាលូតលាស់។ សេចក្តីស្រាយមកហើយនេះបញ្ជាក់ឱ្យឃើញថា លទ្ធិសាសនាកើតឡើងពីអំណាចធម្មជាតិនៅពេលមនុស្សល្ងង់ខ្លៅ។ ជំនឿនេះថយឥទ្ធិពលទៅវិញចំពោះមុខអភិវឌ្ឍន៍ស្យង់។ ក្នុងសង្គមមនុស្សវិញ សាសនាមានមុខងារសំខាន់អាចជាកំលាំងពង្រឹងនយោបាយ សេដ្ឋកិច្ច និងអាចជាគ្រឹះអភិវឌ្ឍន៍ជាតិ ប៉ុន្តែសាសនាអាចទៅជាឧបករណ៍ របស់វណ្ណៈមនុស្សមួយពង្រឹងការជិះជាន់របស់គេបិទបាំងការពិតតាមរនាំងសាសនា ដើម្បីបន្តអំណាចការជិះជាន់និងការរស់យ៉ាងសង្ហាតទៅទៀត។

## ប្រធានទី ៧

### ក្នុងសម័យវេទព្រះឥន្ទ្រមានមុខងារអ្វីខ្លះ? ហេតុអ្វីបានជាសម័យក្រោយវេទគេធ្វើបរិវត្តន៍រំលំព្រះឥន្ទ្រ?

កាលពីច្រើនសតវត្សមុនគ.ស ជាតិអារ្យ៉ន (Aryens) បានវាយលុកអ៊ីរ៉ុបមួយផ្នែកហើយមួយទៀតបានចូលមកលុកលុយ ប្រទេសឥណ្ឌាខាងជើង។ ដោយជនជាតិថ្មី ជាអ្នកចេះដឹងជាង ម្ចាស់ស្រុកក៏យកជោគជ័យលើពួកនេះបានហើយយកលទ្ធិសាសនា ជំនឿខ្លួនមកផ្សព្វផ្សាយ។ លទ្ធិថ្មីប៉ះទង្គិចនិងលទ្ធិជំនឿអ្នកក្នុងស្រុករួមផ្សំគ្នាកើតជាលទ្ធិថ្មីមួយហៅថាលទ្ធិវេទ។ ក្នុងសម័យទេវនិយមនេះ គេគោរពទេវៈជាច្រើនតាមការបង្កើតរបស់តាបសឫសី តែទេវៈមានមុខមាត់ជាងគេគឺព្រះឥន្ទ្រ។ តើព្រះឥន្ទ្រមានមុខងារអ្វីខ្លះ? ហើយដល់សម័យក្រោយមកហេតុអ្វី បានជាគេទាត់ព្រះឥន្ទ្រចោល?

ព្រះឥន្ទ្រជាទេវៈ មានប្រជាប្រិយភាពជាងគេទាំងអស់ នៅសម័យវេទប្រកបដោយរូបរាងយ៉ាងកំណាចអស្ចារ្យ។ ទេវៈអង្គ នេះ តែងកាន់ដំបងពេជ្រនៅដៃ។ តាមទេវសាស្ត្រ ដំបងពេជ្រតំណាងពន្លឺរន្ទះ គឺអាវុធយ៉ាងសំខាន់ជួនកាលព្រះឥន្ទ្រកាន់ធ្នូស និង កង្វេរដែកថែមទៀត។

មុខងារសំខាន់របស់ព្រះឥន្ទ្រ ដំបូងឡើយគឺជាអ្នកបំផ្លាញនូវការរាំងស្ងួត និងសភាពងងឹត។ បន្ទាប់មកព្រះឥន្ទ្រជាមេទ័ព វី ជាទេវៈចំបាំង ដែលបានជួយធ្វើសង្គ្រាមពួកអារ្យ៉ន។ គម្ពីរវេទបានឱ្យដឹងថា មុនពេលចេញច្បាំងព្រះឥន្ទ្រផឹកស្រាសោមអស់ច្រើនស្រះ ពេលស្រវឹង ព្រះឥន្ទ្រគ្រញែងខ្លួន គ្រវីក្បាល ដើម្បីសំដែងអំណាចខ្លួន។

នៅរដូវរាំងរីង ប្រជាជនសម័យវេទច្រើនបន់ស្រន់បួងសួងសុំឱ្យព្រះឥន្ទ្របង្អុរទឹកភ្លៀង និងបញ្ចេញនូវពន្លឺថ្ងៃ។ អ្នកចំបាំង តែងបន់ស្រន់ដល់ព្រះឥន្ទ្រមុនចូលប្រយុទ្ធ ហើយទេវៈអង្គនេះជាមេទ័ពរបស់ជនជាតិអារ្យ៉ននេះតែម្តងក្នុងពេលវាយលុកប្រទេសឥណ្ឌា។

មិនតែប៉ុណ្ណោះ គេចាត់ទុកថាព្រះឥន្ទ្រជាអាទិទេពបង្កើតលោកយើងនេះថែម ទៀតផង។

តែដល់ចុងសម័យវេទ ប្រជាប្រិយភាពព្រះឥន្ទ្រស្រុតចុះ ព្រោះព្រះឥន្ទ្រ ច្បាំងចាញ់ញឹកពេក មានគុណវិបត្តិច្រើន ដូចជា ផឹកស្រាស្រវឹង ឡូឡា ក្អេងក្អាង លោភកាមគុណ មានទេវីអមច្រើនពាន់ហើយថែមទាំងលួចប្រពន្ធឥសីជាញឹកញាប់ ទៀតផង។ គុណវិបត្តិទាំងនេះធ្វើឱ្យព្រះឥន្ទ្របាត់បង់កិត្តិយស ហើយគ្មានមកពីអ្វី ក្រៅពីអំនួតក្អេងក្អាង របស់ព្រះឥន្ទ្រនៅពេលដែលឃើញគេលើកតំកើងខ្លួននោះ ឡើយ។ បន្ទាប់មកគេបានរំលំព្រះឥន្ទ្រចោលហើយបង្កើតទេវៈមួយទៀតមក ជំនួសគឺ ព្រហ្ម។ សម័យថ្មីមួយក៏ចាប់ផ្តើម ឡើងគឺសម័យព្រាហ្មណ៍និយម។

សេចក្តីអធិប្បាយមកខាងលើ បង្ហាញមុខងារព្រះឥន្ទ្រក្នុងលទ្ធិវេទនិយម។ ព្រះឥន្ទ្រជាមេទ័ពរបស់ពួកអារ្យ៉ែនតែក្រោយមក ត្រូវធ្វើបដិវត្តន៍រំលំចោល។ បុព្វហេតុនៃការដួលរលំនេះ មកពីគុណវិបត្តិរបស់ព្រះឥន្ទ្រ រឿងនេះទំនងជាមេទ័ព របស់អារ្យ៉ែនដែលច្បាំងឈ្នះពួកម្ចាស់ស្រុកឥណ្ឌាត្រូវគោរពកោតខ្លាចលើកតំកើង ដល់ក្រោយដោយមានអំនួត និងកត្តិយសនេះ មេទ័ពទាំងនោះត្រឡប់ជាព្រហើន កោងកាចរំលោភលើអ្នកតូចតាច មានការចាប់ប្រពន្ធគេជាដើម។ គុណវិបត្តិនេះ នាំឱ្យពួកអារ្យ៉ែនមានការភ័យខ្លាចបាត់បង់ ឬទ្ធានុភាពក្រុមខ្លួន ក៏ប្តូរអ្នកដឹកនាំថ្មី គឺបង្កើតទេវៈថ្មីមួយ ជំនួសដើម្បីរំងាប់កំហឹងអ្នកស្រុក។ នេះជាពន្លឺមួយសំរាប់ បំភ្លឺឱ្យឃើញថា គេមិនត្រូវលើកតំកើងជនណាម្នាក់ឱ្យខ្ពស់ពេកទេ ត្រូវតែមានការ ទិតៀនផង សរសើរផង។

## ប្រធានទី ៨

**ក្នុងសម័យវេទគេគោរពព្រះឥន្ទ្រ ដល់សម័យព្រាហ្មណ៍គេគោរពព្រះព្រហ្មទៅវិញ។ តើក្នុងសម័យព្រាហ្មណ៍និយមមានលទ្ធិអ្វីខ្លះកើតឡើងដែលជាហេតុនាំឱ្យគេចាត់ទុកថាមានបរិវត្តន៍ក្នុងសាសនា?**

លទ្ធិពួកជនជាតិអារ្យ៉ន់ដែលជាអ្នកវាយលុកលុយឥណ្ឌា ផ្សំជាមួយលទ្ធិម្ចាស់ស្រុកកកើតជាលទ្ធិថ្មីមួយហៅថា "វេទនិយម "។ ដល់ក្រោយមកមានបរិវត្តន៍ធំមួយក្នុងវិស័យសាសនាគឺគេទំលាក់ព្រះឥន្ទ្រដែលជាទេវៈសំខាន់រួចបង្កើតព្រះព្រហ្មជំនួសវិញ ហើយចាប់ផ្ដើមសម័យព្រាហ្មណ៍និយមឡើង។

ទេវៈសំខាន់ក្នុងសម័យវេទគឺ ព្រះឥន្ទ្រត្រូវគេរំលំចោលដោយហេតុថាទេវៈអង្គនេះមានគុណវិបត្តិច្រើនពេក ដូចជាផឹកស្រាស្រវឹង អួតក្អេងក្អាងលួចប្រពន្ធគេ ពិសេសច្បាំងចាញ់គេញឹកញាប់ពេក។ គេបង្កើតទេវៈថ្មីមកជំនួសគឺព្រះព្រហ្ម ដំបូងព្រះព្រហ្មជា ទេវៈគ្មានរូបទេ គឺគ្រាន់តែជាសភាវៈធម៌ តែក្រោយមកដើម្បីស្រួលគោរពបូជា គេក៏បង្កើតរូបមានមុខបួន។

ក្នុងលទ្ធិថ្មីនេះ គេចាត់ទុកថាព្រះព្រហ្មជាទេវៈបង្កើតលោក។ លទ្ធិសំខាន់បីកើតឡើង គឺលទ្ធិព្រហ្មចារិយ លទ្ធិអាត្មន និងលទ្ធិឧបនិស័ទ។

លទ្ធិព្រហ្មចារិយ គឺជាទ្រឹស្ដីពន្យល់ឱ្យមនុស្សកសាងអំពើល្អ ដើម្បីឱ្យព្រលឹងបានទៅរួបរួមព្រហ្ម័នវិញ។ អ្នកបួសមានពីរប្រភេទ គឺសមណព្រាហ្មណ៍ ដែលជាអ្នកបួសប្រព្រឹត្តព្រហ្មចារិយធម៌-អត់ប្រពន្ធកូន និងពួកគហបតីព្រាហ្មណ៍ ដែលជាអ្នកនៅផ្ទះ មានប្រពន្ធកូន ប្រកបមុខរបរដូចជនធម្មតា។ គេចែកឆាកជីវិតជាបួនក្នុងមនុស្សម្នាក់ៗ។ ផ្នែកទី ១ គឺមនុស្សម្នាក់ត្រូវចំណាយពេល រស់នៅជាមួយអ្នកបួស ដើម្បីរៀនសូត្រផ្នែកផ្លូវធម៌ អស់រយៈពេលពី ៦ ឆ្នាំ ទៅ ៣០ ឆ្នាំ ផ្នែកទី ២ នៃឆាកជីវិតគឺត្រូវខំប្រឹងប្រកបការងារចិញ្ចឹមគ្រួសារ ផ្នែកទី ៣ គឺត្រូវប្រគល់ទ្រព្យសម្បត្តិទៅឱ្យកូន ហើយទៅរស់នៅក្នុងព្រៃដើម្បីស្វែងរកធម៌។ ផ្នែកទី ៤ គឺឆាក ជីវិតរបស់អ្នកបួស។

នេះជាបដិវត្តន៍ក្នុងកិច្ចប្រតិបត្តិនៅក្នុងលទ្ធិថ្មី ព្រោះកាលពីសម័យវេទ ពួកឥសីដែលជាអ្នកបួសរស់ក្នុងសង្គម មនុស្ស ហើយព្យាយាមអធិប្បាយជាកំនាព្យ ពីសភាវៈរបស់ធម្មជាតិ ដែលផ្តល់គុណសម្បត្តិ និងគុណវិបត្តិដល់មនុស្ស ចំនែកក្នុង សម័យថ្មីនេះវិញ គេចំនាយពេលមកមើលខាងក្នុងជីវិរបស់មនុស្ស ពិចារណា ពីកំនើតសុខទុក្ខរបស់មនុស្សក្នុងលោកនេះនិងលោក ខាងមុខ។ បដិវត្តន៍មួយទៀត គឺគេវិលមករកការប្រតិបត្តិរបស់មនុស្សនេះវិញ សម័យវេទគេនិយមការបន់ស្រន់ ព្រោះទេវៈជាអ្នកផ្តល់ សុខ រឺទុក្ខឱ្យមនុស្ស តែសម័យព្រាហ្មណ៍មនុស្សម្នាក់ៗ ពុំមែន ត្រូវបន់ស្រន់ទេ គឺត្រូវកសាងខ្លួនដោយខ្លួនឯងដូចជាឆាកជីវិតបួននេះជា ដើម។

លទ្ធិអាត្ម័នជាលទ្ធិខ្ពស់ក្រៃលែងក្នុងលទ្ធិព្រាហ្មណ៍។ ក្នុងលទ្ធិនេះពន្យល់ថា មនុស្សស្លាប់ហើយព្រលឹង រឺអាត្ម័នរបស់មនុស្ស បានទៅទុំនៅដើមឈើអស់មួយ រយៈពេល ទើបទៅសំចតនៅព្រះច័ន្ទ។ គេយល់ថា អាត្ម័នជាព្រលឹងមនុស្សម្នាក់ៗ មហាត្ម័ន រឺ ព្រហ្ម័នជាព្រលឹងសកល។ អាត្ម័នរបស់មនុស្សម្នាក់អាចទាក់ទងនឹង ព្រហ្ម័នបានតាមអំពើល្អ។

មហាត្ម័នរឺព្រហ្ម័ននេះគឺព្រះព្រហ្មនេះឯង។ ដូចនេះពេលមនុស្សស្លាប់អាត្ម័ន មិនស្លាប់ទេ។ គឺបន្តដំនើរទៅសណ្ឋិតក្នុងរូបរាងកាយថ្មីមួយទៀតតាមកំលាំងកម្មន្ត ។ កម្មន្តជាកំលាំងរុញច្រានអាត្ម័នពីរូបកាយដែលស្លាប់ទៅកាន់រូបថ្មីតាមអំពើដែល ខ្លួនបានកសាង។ ការវិលវល់ចេញពីរូបមួយទៅរូបមួយនេះ គេហៅថាសំសារៈ។ ដូចនេះរនាំងបាំងមិនឱ្យអាត្ម័នទៅជួបព្រហ្ម័ន គឺកម្មន្តនេះឯង ត្រង់នេះបង្ហាញ នូវគំនិតបដិវត្តន៍មួយដែរ ព្រោះសម័យវេទ សុខរឺទុក្ខ ល្អរឺអាក្រក់ស្ថិតនៅ លើជំនឿទៅលើអាទិទេព ការបន់ស្រន់នេះជាដើម មកដល់សម័យព្រាហ្មណ៍ ល្អរឺអាក្រក់ស្ថិតនៅលើអំពើរបស់ខ្លួនទៅវិញ។

លទ្ធិឧបនិស័ទ ជាទ្រឹស្តីមួយបំនងបំបាត់ ការវិលកើត វិលស្លាប់ ធ្វើឱ្យវិញ្ញាណរួចជ្រះស្រលះដើម្បីសំរេច មោក្សៈ គឺអាត្ម័នវិលទៅចូលក្នុងព្រហ្ម័នវិញ មានវិធីសំខាន់ពីរ គឺតបៈ និងយោគៈ គឺរំងាប់កាមកិលេសតាមផ្លូវកាយ និងតាមផ្លូវចិត្តឱ្យស្ងប់។

រួមសេចក្តីមកលទ្ធិព្រាហ្មណ៍ ជាលទ្ធិបន្តពីលទ្ធិវេទតែមានការចំរើនមួយកំរិត សម័យនេះមនុស្សវិលមករកមើលបញ្ហាមនុស្សខ្លួនឯងនិងជីវិតមនុស្សវិញ ពុំមែនដូចសម័យវេទដែលសំលឹងមើលតែធម្មជាតិខាងក្រៅនេះទេ។

គេទុកជាបដិវត្តន៍មួយខាងសាសនា គឺរំលំព្រះឥន្ទ្រដែលជាទេវៈរបិលរប៉ូចលួចប្រពន្ធគេ ហើយយកទេវៈថ្មីមកជំនួសមាន លក្ខណៈប្រសើរជាងមុន។ គេចាត់ទុកជាបដិវត្តន៍សង្គមផងថែមទៀត ព្រោះលទ្ធិថ្មីបានអប់រំមនុស្ស ឱ្យកសាងសេចក្តីសុខរបស់ ខ្លួនដោយខ្លួនឯង ពុំមែនបន់ស្រន់ទេវៈដូចសម័យវេទឡើយ។ ម្យ៉ាងទៀតគេថា លទ្ធិអាត្ម័នជាលទ្ធិខ្លួនឯងព្រោះអាត្ម័នជាមហាអាត្ម័ន រឺព្រហ្ម័ន ព្រហ្ម័នគឺខ្លួនឯង។

៙០៙

# ពុទ្ធសាសនា

## ១.កំណើត :

នៅប្រទេសឥណ្ឌាក្នុងសតវត្សទី ៦មុនគ.ស។ ចាប់ពីសតវត្សទី ១ ចែកជាពីរនិកាយ (Secte) គឺ និកាយហិនយាន និងមហាយាន។

- និកាយហិនយាន (Petit Vehicule) គោរពព្រះពុទ្ធ សមណគោតម ដែលត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ និងទ្រង់បាន ចូលព្រះនិព្វានបាត់ទៅហើយ។ ប្រទេសនិយមពុទ្ធសាសនាហិនយានគឺ ខ្មែរ.សៀម. លាវ. ភូមា. ឥណ្ឌា. លង្កា ។ល។

-និកាយមហាយាន ពុំគោរពព្រះពុទ្ធទេ តែគោរពពោធិសត្វដូចជា អវលោកិតេស្វរៈ វីលោកកេស្វរៈ មញ្ជុស្រី មៃ ត្រេយ ប្រជ្ញា បារមិតា ។ល។ យួន. ចិន. ជប៉ុន. ទីបេ ជាប្រទេសកាន់ពុទ្ធសាសនាមហាយាន។

## ២.ពុទ្ធប្រវត្តិសង្ខេប :

ជាបុត្រព្រះសទ្ធោទន៍ និងនាង សិរិមហាមាយា· ជាក្សត្រសោយរាជនគរ កបិលពស្តុ(នេប៉ាល់សព្វថ្ងៃ)។ មហេសីព្រះនាមពិម្ពាយសោយរាជ្យព្រះនាម រាហ៊ុល កុមារ។ ព្រះពុទ្ធនាម សិទ្ធត្ថ។

-ព្រះជន្ម ១៦ វស្សាបានទទួលរៀបអភិសេក

-ព្រះជន្ម ២៩ វស្សាបានចេញទៅបួស

-ព្រះជន្ម ៨០ វស្សាចូលបរិនិព្វាន

## ៣.ទ្រឹស្តី :

ក- អរិយសច្ចៈ (Nobles Verites)

ខ- បដិច្ចសមុប្បាទ (Causalite)

គ- អនត្តៈ (Non-soi)

ប្រធានទី ៩

# គោលសំខាន់នៃទស្សនៈវិជ្ជាក្នុងពុទ្ធសាសនា

១. អរិយសច្ចៈ ៤ : បួន

-ទុក្ខ

-សមុទយៈ

-និរោធ

-មគ្គៈ

២. កម្មផល

៣. បដិច្ចសមុប្បាទ

៤. អនត្តៈរឺអនាត្មន

ពុទ្ធសាសនាអាចចាត់ទុកថា ជាទស្សនវិជ្ជាក៏បាន ជាធមិសំរាប់ប្រតិបត្តិដើម្បីរំដោះខ្លួនពីសេចក្តីទុក្ខក៏បាន។ ជាបឋម ពុទ្ធសាសនាបង្រៀនឱ្យសំគាល់ដំនើរចិត្ត រួចពន្យល់ពីដំនើរលោករបស់មនុស្ស ដែលទាក់ទងទៅនឹងការវិលវល់របស់សត្វលោកតាមផ្លូវចិត្ត ដូចនេះឯង។ ជាពិសេសពុទ្ធសាសនាបានដៅផ្លូវប្រតិបត្តិដើម្បីឱ្យមនុស្សយកមកអនុវត្តន៍ផ្ទាល់ខ្លួនឯង។ តើគោលសំខាន់ដែលព្រះពុទ្ធបានដៅមកមានអ្វីខ្លះ?

ទស្សនៈវិជ្ជាសំខាន់ដែលព្រះពុទ្ធរកឃើញគឺទ្រឹស្តីអរិយសច្ចៈ (Nobles Vérités) ។ តើអរិយសច្ចៈជាអ្វី? គឺជាសច្ចៈ គឺការពិតដ៏ខ្ពង់ខ្ពស់។ ព្រះពុទ្ធរកឃើញថាការពិតសំខាន់ ដ៏ខ្ពង់ខ្ពស់មានបួនហៅថាចតុរារិយសច្ចៈគឺ ទុក្ខអរិយសច្ចៈ សមុទយអរិយសច្ចៈ និរោធអរិយសច្ចៈ និងមគ្គអរិយសច្ចៈ។

ទុក្ខអរិយសច្ចៈជាសេចក្តីពិតមួយ គឺថាមានជីវិតពិតជាមានទុក្ខពុំអាចជៀសវាងបានឡើយ គ្រាន់តែអ្នកខ្លះមានទុក្ខតិច អ្នកខ្លះមានទុក្ខច្រើនតែប៉ុណ្ណោះ។

សមុទយអរិយសច្ចៈជាសេចក្តីពិតមួយ គឺថាទុក្ខរបស់មនុស្សពិតជាមានហេតុ។ ហេតុសំខាន់មានពីរ គឺលំងបរឹតណ្ហា (Passion) និងអវិជ្ជា (Ignorance)។

និរោធអរិយសច្ចៈ ជាសេចក្ដីពិតមួយ គឺថាទុក្ខពិតជាអាចរលត់ទៅវិញបាន។ គេបំបាត់ទុក្ខដោយគាស់រំលើង ហេតុរបស់ទុកគឺបំបាត់តណ្ហា និងអវិជ្ជានេះឯង។

មគ្គអរិយសច្ចៈ ជាសេចក្ដីពិត គឺថាទុក្ខអាចរលត់ទៅវិញ តាមផ្លូវឬមធ្យោបាយត្រូវ។ ព្រះពុទ្ធបានកំណត់យកផ្លូវកណ្ដាល (មជ្ឈិមាបដិបទា) ដោយប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវមគ្គ ៨ យ៉ាងដែលគេហៅថា អដ្ឋង្គិកមគ្គ គឺការយល់ឃើញក្នុងផ្លូវត្រូវហៅថា សម្មាទិដ្ឋិ ការត្រិះរិះក្នុងផ្លូវត្រូវហៅថា សម្មាសង្កប្បសំដីត្រឹមត្រូវហៅថា សម្មាវាចា ប្រព្រឹត្តតែអំពើត្រឹមត្រូវហៅថាសម្មាកម្មន្ត ចិញ្ចឹមជីវិតក្នុងផ្លូវត្រូវហៅថា សម្មាអាជីវៈ ការព្យាយាមត្រឹមត្រូវហៅថា សម្មាវាយាម ការរំលឹកខ្លួនឱ្យផ្ចង់ស្មារតីត្រឹមត្រូវ ហៅថា សម្មាសតិ ការធ្វើសម្មាធិត្រឹមត្រូវ ហៅថា សម្មាសមាធិ។

ទ្រឹស្ដីសំខាន់មួយទៀត គឺទ្រឹស្ដីកម្មផល។ តើកម្មផលក្នុងលទ្ធិពុទ្ធសាសនាមានន័យដូចម្ដេច?

តាមទស្សនៈពុទ្ធនិយម សត្វលោកតែងវិលកើត វិលស្លាប់មិនចេះចប់ក្នុងវដ្ដសង្សារ។ មានជីវិតរមែងជួបប្រទះនឹងទុក្ខសោក រោគាព្យាធិ សេចក្ដីលំបាក ហើយកើតមកតែងចាស់ -ឈឺ- ស្លាប់ទៅវិញ។ តាមពុទ្ធលទ្ធិភាវៈ កើតឡើងខ្លួនឯងតាមកំនត់ច្បាប់ធម្មជាតិ។ ធាតុដែលនាំឱ្យកើត រឺស្លាប់គឺ ខន្ធទាំង ៥ ហៅថា បញ្ចក្ខន្ធ - មានរូបក្ខន្ធ - វេទនាខន្ធ - សញ្ញាខន្ធ - សង្ខារខន្ធ - វិញ្ញាណក្ខន្ធ សេចក្ដីថាជាការរួមផ្គុំផ្សំរវាងភាពទាំងឡាយ។ ភាវៈមានកំនើតហើយធំធាត់ រួចទ្រុឌទ្រោមទៅវិញ រួចធាតុក៏ផ្គុំផ្សំជាថ្មី កើតជាជីវិតថ្មីមួយទៀត។ ដូចនេះជីវិតថ្មីមានជាប់ទាក់ទងទៅនឹងជីវិតចាស់ ចំនែកកំលាំងអន្ទោលចុះឡើងពីជីវិតមួយទៅជីវិតមួយគឺ កម្មផល។ តើកម្មផលជាអ្វី?

កម្មមានន័យថាអំពើ ផលជាផ្លែផ្កាលេចចេញពីអំពើ។ ដូចនេះតាមទស្សនៈពុទ្ធនិយមផលល្អ រឺអាក្រក់បានមកពីការកសាងរបស់ខ្លួន ពុំមែនមកពីអាទិទេពទេ។ អំពើល្អ និងអំពើអាក្រក់ពុំអាចសងគ្នាបានឡើយ។ សេចក្តីថាអំពើអាក្រក់ផ្តល់ផលអាក្រក់ អំពើល្អផ្តល់ផលល្អ បើអំពើល្អនោះផង អាក្រក់ផង ផលក៏ត្រូវល្អផង និងអាក្រក់ផងដែរ។

រួមសេចក្តីមកទ្រឹស្តីកម្មផល ជាទ្រឹស្តីទំនាក់ទំនងហេតុផល។ ទ្រឹស្តីនេះព្រះពុទ្ធបានពន្យល់ក្បោះក្បាយ ហើយដាក់ឈ្មោះថា ទ្រឹស្តីបដិច្ចសមុប្បាទ។ តើបដិច្ចសមុប្បាទជាអ្វី?

គឺជាធម្មភាពភ្ជាប់ហេតុទៅនឹងផល (Loi de causalité) ។ ភាវៈទាំងអស់ដែលកើតឡើងសុទ្ធតែមានបច្ច័យទាក់ទងគ្នា បើនេះមាន នោះក៏មាន បើនេះគ្មាន នោះក៏គ្មានដែរ។

ដំនើរវិលកើតវិលស្លាប់របស់មនុស្ស ទ្រឹស្តីបដិសមុប្បាទ បានប្រទាក់គ្នាជាកំរងច្រវ៉ាក់នូវហេតុ ១២ យ៉ាងគឺ អវិជ្ជា (Ignorance) សង្ខារ (Fornatimn) វិញ្ញាណ (Conscience) នាមរូប (Mentalité et physigue) ។ អាយតនៈ (Sens) ផស្ស (Contact sensoriel) វេទនា (Sensation) តណ្ហា (Désir soif) ឧបាទាន (Attachement) ភព (Existence) ជាតិ (Naissance) ជរា (Vieillesse) នាំឱ្យកើតមរណៈ (Mort) ។ បើធាតុណាមួយកើតឡើង ធាតុដ៏ទៃក៏មានកំនើតជាបន្តបន្ទាប់ រហូតដល់មរណៈ។

ទ្រឹស្តីសំខាន់មួយទៀត ដែលជាប្រតិកម្មប្រឆាំង និងលទ្ធិសាសនាព្រាហ្មណ៍ក្នុងសម័យព្រាហ្មណ៍និយមគឺ ទ្រឹស្តី អត្តៈ រឺអាត្ម័ន។ ក្នុងសម័យព្រាហ្មណ៍និយមគេជឿថាព្រះព្រហ្មជាទេវៈបង្កើតលោកបង្កើតមនុស្ស ក្នុងខ្លួនមានអាត្ម័ន រឺព្រលឹងដែលចេញពីរូបមួយទៅរូបមួយ មានកំលាំងអាត្ម័នជាព្រលឹងមនុស្សម្នាក់ព្រហ្ម័នជាព្រលឹងសកល រឺមហាត្ម័ន។ អាចវិលទៅជួបព្រហ្ម័នវិញបាន។ ព្រះពុទ្ធបដិសេធជំនឿបែបនេះដោយពន្យល់ថាគ្មាន អាត្ម័ន រឺព្រលឹងទេ ព្រហ្ម័នក៏គ្មានដែរ។

រួមសេចក្តីមកទ្រឹស្តីរបស់ព្រះពុទ្ធ ដូចបានបង្ហាញមកនេះជាទ្រឹស្តីទស្សនៈវិជ្ជាសំខាន់ៗ ដែលមានលក្ខណៈស្របនិងស្បង់ជាច្រើន។ ទ្រឹស្តីនេះ ជាគំនិតបដិវត្តន៍មួយក្នុងសង្គមតណ្ហា ព្រោះទ្រឹស្តីរបស់ព្រះពុទ្ធប្រឆាំងនឹងជំនឿក្នុងលទ្ធិព្រាហ្មណ៍។ ព្រះពុទ្ធទ្រង់បានត្រិះរិះពិចារណាពីជីវិតរបស់មនុស្ស ស្វែងរកសច្ចៈដែលជាផ្លូវស្វែងរកសុខៈ ហើយទីបំផុតបានសំរេចដូចបំនងរបស់លោកតាមវិធីពិចារណាពិសោធន៍អស់រយៈពេលជាច្រើនឆ្នាំ។ ដូចនេះទ្រឹស្តីរបស់លោក ជាទស្សនៈវិជ្ជា មានលក្ខណៈមនុស្សនិយម ពោលគឺមិនពិចារណាពីអាទិទេពទេ ត្រលប់មកពិចារណាពីសុខទុក្ខរបស់មនុស្សនេះវិញ ព្រមទាំងបដិសេធអាទិទេពទៀតផង។

៚៙

# អាទិទេពក្នុងត្រីមូ៌តិ

លទ្ធិសាសនាមានចំនាស់ជាងគេនៅឥណ្ឌា គឺលទ្ធិព្រាហ្មណ៍។ ដំបូងលទ្ធិនេះកើតឡើងដោយបន្សំរវាងជំនឿអ្នកស្រុក និង ជំនឿជនជាតិអារ្យ៉ន ហើយគេហៅថាលទ្ធិវេទនិយម។ វេទនិយមបានប្តូរទំរង់ជាលទ្ធិព្រាហ្មណ៍និយម ចាប់ពីសតវត្សទី ១៦ មុនគ.សមក។ ដោយមានការប្រកួតប្រជែងនឹងពុទ្ធសាសនា អ្នកកាន់កាប់ផ្សាយ លទ្ធិព្រាហ្មណ៍ក៏ខិតខំច្នៃលទ្ធិសាសនាខ្លួន ឱ្យកាន់តែមានភាពប្រសើរជាងមុន ហើយគេសន្មត់ហៅថាសាសនាហិណ្ឌូ។ ក្នុងសាសនាហិណ្ឌូ មានទស្សនៈសំខាន់មួយលេចមុខមាត់ជាងគេគឺការគោរពអាទិទេពក្នុងត្រីមូ៌តិ។ តើត្រីមូ៌តិជាអ្វី? ក្នុងសម័យវេទ គេគោរពព្រះឥន្ទ្រជាធំក្នុងសម័យព្រាហ្មណ៍ គេគោរពព្រះព្រហ្មជាធំមកដល់សម័យហិណ្ឌូ គេគោរពទេវៈធំៗ បី គឺព្រះព្រហ្ម ព្រះវិស្ណុ និងព្រះសិវៈ រឺឥសូររួមជាមួយគ្នាហៅថាត្រីមូ៌តិ។

គម្ពីរខ្លះបានបង្ហាញថា វិស្ណុជាអាទិទេពធំជាងគេ គម្ពីរខ្លះទៀតថា ព្រះព្រហ្ម ធំជាងគេ គម្ពីរខ្លះទៀតថា ព្រះឥសូរធំជាងគេ។ បានជាដូចនេះគឺមកពីអ្នកដឹកនាំ ក្រុមទាំងបីចង់ប្រណាំងប្រជែងក្អាយកធំរៀង១ខ្លួន ម្ល៉ោះហើយក៏ខំអួតផ្សាយពីសកម្មភាពរបស់ អាទិទេពខ្លួន។

អ្នកចាត់ទុកថា វិស្ណុ រឺនារាយណ៍ជាអាទិទេពធំបានសំអាងទៅលើ មុខងារសំខាន់របស់វិស្ណុ គឺការបង្កើតលោក។ គេបង្ហាញថា ព្រះវិស្ណុបានផ្ទុំលក់ស៊ប់លើនាគដែលបើកពពែការពារ ហើយមានផ្កាឈូកមួយផុសចេញពីផ្ចិតរបស់វិស្ណុ។ ព្រះព្រហ្មមុខបួនអង្គុយលើផ្កាឈូកនោះ ហើយមានព្រះនាងលក្សីជាមហេសីអង្គុយច្របាច់ជើង។ វិស្ណុដែលផ្ទុំលក់នេះ តាមទស្សនវិជ្ជាថា ជាធាតុអកម្មព្រះព្រហ្ម ជាធាតុសកម្ម។ ដូចនេះព្រះវិស្ណុជាទេវៈ បង្កើតលោកផង ហើយជាទេវៈការពារ លោកផង។ ដើម្បីការពារលោកព្រះវិស្ណុវិនបែងចេញជាអវតារ។ អវតារទាំង អស់មាន ១០ គឺមក្សភូមិវរាហ នរសីង្ហ វាមន បរសុរាម រាម ក្រិស្ណ កល្កិន និងព្រះពុទ្ធ។ ប៉ុន្តែព្រះពុទ្ធ បដិសេធ លោកពុំទទួលយល់ព្រមថាលោកជាអវតារឡើយ។

ក្រុមអ្នកគោរពព្រះព្រហ្មថា ព្រះព្រហ្មជាអ្នកបង្កើតលោក ដោយសំអាងទៅលើមុខងារដែលព្រះព្រហ្មបានធ្វើជាមួយព្រះវិស្ណុនិង សំអាងទៅលើទស្សនវិជ្ជាមួយផ្នែក ដែលថាព្រះព្រហ្មមានលំនៅស្ថានខ្ពស់ជាងគេ។

អ្នកគោរពព្រះសិវៈ ថាសិវៈជាអាទិទេពច្បង ជាទេវៈបង្កើតលោកផងបំផ្លាញលោក និងការពារលោកផង។ ប៉ុន្តែគេសង្កេត ឃើញមានទំនោរបង្រួបបង្រួមលទ្ធិវិស្ណុនិយម សិវៈនិយមឱ្យទៅជាលទ្ធិតែមួយគឺ ហរិហរៈ។

គម្ពីរមួយឈ្មោះវាយុបុរាណបានដំណាលពីកំនើតសិវៈថា ថ្ងៃមួយព្រះព្រហ្មនិងព្រះវិស្ណុ កំពុងឈ្លោះគ្នាដោយតាំងខ្លួនថា ជាអ្នកបង្កើតលោករៀង១ខ្លួន ពេលនោះស្រាប់តែមានសសរភ្លើងធំមួយផុសឡើង នៅចន្លោះអាទិទេពទាំងពីរនោះ។ ដោយចង់ដឹងអំពីប្រភពសសរភ្លើងទាំងនោះ ព្រះវិស្ណុបានកាលាខ្លួនជាជ្រូកព្រៃ ឈូសដីទៅមើលខាងក្រោម ព្រះព្រហ្មកាលាខ្លួនជាបក្សីហើរទៅមើលខាងលើ។ អស់ច្រើនពាន់ឆ្នាំមកអាទិទេពទាំងពីរ រកប្រភពសសរភ្លើងមិនឃើញស្រាប់តែព្រះសិវៈចេញមកហើយប្រាប់ថា សិវៈជាអ្នកបង្កើតលោក។ អាស្រ័យលើជំនឿនេះគេក៏នាំគ្នាសាងរូបលិង្គព្រះឥសូរ ឬសិវលិង្គ ដើម្បីទុកជានិមិត្តរូបសសរភ្លើងនោះផង ជានិមិត្តរូបនៃការបង្កើតលោកផង។

សេចក្តីអធិប្បាយមកហើយនេះ បង្ហាញឱ្យឃើញថា អាទិទេពធំ១ បីដែលត្រូវគេ គោរពខ្លាំងជាងគេក្នុងសម័យហិណ្ឌូ គឺព្រះព្រហ្ម ព្រះសិវៈ និងព្រះវិស្ណុ ប៉ុន្តែការ លើកតំកើងអាទិទេពនីមួយ១ ប្រែប្រួលតាមក្រុមអ្នកកាន់សាសនានោះ។ ក្រុមខ្លះលើក តំកើងព្រះវិស្ណុ ខ្លះលើកព្រះព្រហ្ម ខ្លះទៀតលើកព្រះសិវៈ។

នៅប្រទេសខ្មែរយើង ក្នុងសម័យសាសនាព្រាហ្មមានការចំរើនលូតលាស់មានការគោរពបូជាអាទិទេពតាមទស្សនៈឥណ្ឌាដែរ ប៉ុន្តែអាទិទេពដែលមានប្រជាប្រិយភាពជាងគេគឺ ព្រះឥសូរ បន្ទាប់មកព្រះនារាយណ៍។ មានរូបចំលាក់ជាច្រើនបង្ហាញពីទេវៈទាំងពីរនេះ ចំនែកព្រះព្រហ្មពុំសូវឃើញមានរូបចំលាក់ទេ។

## ប្រធានទី ១១ ភាសា_អក្សរ_អក្សរសិល្ប៍

### (ភាសាបង្កើតចលនាលូតលាស់មួយផ្នែកក្នុងវប្បធម៌ជាតិ)

គំនិតបង្កើតភាសាដូចនេះ មានតែមនុស្សទេ ដែលអាចបង្កើតភាសាបាន ព្រោះមនុស្សជាភាវៈគំនិត។ សត្វគ្មានភាសាដូចអ្នកខ្លះស្មានឡើយ ពិតមែនតែវាចេះសំដែងសេចក្តីត្រូវការរបស់វាឱ្យមនុស្ស រឺសត្វដូចគ្នាយល់បានព្រោះការសំដែងនេះគ្មាន តែជាសញ្ញាទំនាក់ទំនងតាមគំរោងសភាវគតិតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ ភាសាមនុស្សជាសម្បទាបង្កើត រឺប្រើប្រាស់សញ្ញាដោយចេតនា។ ភាសាមនុស្សពុំមែនកើតតាមសភាវគតិទេ តែកើតតាមការបង្រៀន និងការរៀន ព្រោះជាបំនែកបង្កើតថ្មីដោយស្រុះស្រួលគ្នា។ ដូចនេះមនុស្សបង្កើតភាសាដើម្បី សំដែងគំនិតបង្ហាញក្រុមរបស់ខ្លួន។ ចំនេះចំនឹងអាចចេញពីម្នាក់ទៅម្នាក់តាមរយៈភាសានេះឯង ដូចនេះហើយបានជាគេយល់ថា "ភាសាបង្កើតចលនាលូតលាស់មួយផ្នែកក្នុងវប្បធម៌ជាតិ"។ តើភាសាមានមុខងារសំខាន់យ៉ាងណាខ្លះក្នុងការអភិវឌ្ឍន៍វប្បធម៌?

ភាសាជារស្មីតថភាពចាំងចេញពីញាណមនុស្ស។ គេដឹងសេចក្តីត្រូវការរបស់មនុស្សឬរចំនេះចំនឹង តាមទំនាក់ទំនងញាណ ដោយប្រើភាសានេះឯង។ ភាសាកើតឡើងតាំងពីមានកំនើតសង្គមមនុស្ស ក្នុងកំឡុងដំនើរជីវភាព។ ភាសាទាក់ជាប់នឹងសេចក្តីត្រូវការរបស់មនុស្ស សេចក្តីត្រូវការថ្មីៗ តំរូវឱ្យបង្កើតពាក្យថ្មីបន្ថែមទៀត សេចក្តីថាមនុស្សបង្កើតភាសាដើម្បីសេចក្តីត្រូវការរបស់ខ្លួនពោលគឺភាសារបស់ក្រុមណា បំរើផលប្រយោជន៍ក្រុមនោះ។ ភាសាសំស្ក្រឹតជាភាសាអាទិទេព ដែលពួកព្រាហ្មណ៍កាន់កាប់ផ្តាច់មុខសំរាប់ផ្សាយសាសនា។ ភាសាពិសិដ្ឋនេះ បំរើផលប្រយោជន៍ព្រាហ្មណ៍។ ពុទ្ធសាសនាបង្កើតភាសាដោយរំលុតពីព្រាហ្មណ៍ គឺភាសាបាលី។ ប្រជារាស្ត្រប្រើភាសាមួយផ្សេងទៀតតាមក្បួនច្បាប់សំដីខ្លួន។

ដូចនេះក្នុងសង្គមមានវណ្ណៈ ភាសាមានលក្ខណៈប្លែកតាមក្រុម វណ្ណៈមួយបង្កើតភាសាមួយ ដើម្បីប្រើជាប្រយោជន៍ផ្ទាល់ខ្លួន។ ជាតិនីមួយៗតែងខិតខំពង្រីង ពង្រីកអង្គការការពារ បង្កើតនិងបំភ្លឺពីអក្សរ និងភាសាខ្លួនដែលជាកត្តាចាំបាច់នៃការអភិវឌ្ឍន៍វប្បធម៌។ ទំនោររវាងអំណាចរបស់ជាតិធំៗតាមកំលាំងនយោបាយក្តី កំលាំងសេដ្ឋកិច្ចក្តី កំលាំងយោធាក្តី សាសនាក្តីតែងនាំយកភាសាទៅផ្សាយជាមួយព្រោះកាលណាភាសាជ្រាបចូលក្នុងសង្គមបរទេស ហើយវាអាចបង្កើតចលនារំលើងវប្បធម៌ជាតិនោះ និងយកវប្បធម៌របស់ខ្លួនមកជំនួស ហើយជាប្រផ្នូលនៃការផុតរលត់អាយុជីវិតជាតិ ស្របតាមទំនឹមទំនាមថា "វប្បធម៌រលត់ជាតិរលាយ" ។ ដូចនេះហើយបានជាជនជាតិនីមួយៗ ហ៊ានចំនាយប្រាក់ទន់ជាច្រើនដើម្បីផ្សាយភាសាគេឱ្យជ្រួតជ្រាប ក្នុងមជ្ឈដ្ឋានបរទេស។

ក្នុងសង្គមខ្មែរវិញមានការនិយមភាសាបរទេសច្រើន ភាសាចិនក្លាយជាភាសាសេដ្ឋកិច្ចផ្គាច់មុខ ភាសាបារាំងទៅជាភាសារដ្ឋបាលទៅហើយ ទោះមានច្បាប់ប្រកាសប្រើភាសាជាតិជាផ្លូវការក៏ដោយ ភាសាអង់គ្លេសជាភាសាមួយកំពុងពេញមានសំរស់។ សេចក្តីមកហើយថា "ភាសាជាតិណាបំរើជាតិនោះ"។ ដូចនេះក្នុងវិស័យដែលជាអាយុជីវិត រឺ ជាដង្ហើមជាតិ ត្រូវតែយកភាសាជាតិមកធ្វើជាយានពុំមែនត្រូវធ្វើខេមរយានកម្មតែក្នុងវិស័យសិក្សាទេ គឺត្រូវធ្វើ "ខេមរនីយកម្ម" គ្រប់វិស័យទាំងអស់ដើម្បីទាញផលប្រយោជន៍មកឱ្យខ្មែរ។ គ្រប់ប្រទេសឯករាជ្យទាំងអស់ គេធ្វើបែបនេះ ដើម្បីធ្វើឱ្យចលនាវប្បធម៌មានល្បឿនកាន់តែខ្លាំងឡើងផង ចាក់ឫសកាន់តែមាំទាំផង។

សេចក្តីនេះ ពុំមានន័យហាមឃាត់មិនឱ្យកូនខ្មែរសិក្សាភាសាបរទេសនោះទេ ព្រោះភាសាបរទេសអាចឱ្យយើងស្គាល់វប្បធម៌បរទេស ព្រឹត្តិការណ៍អន្តរជាតិ និងការចំរើនលូតលាស់ក្នុងពិភពលោកថែមទៀតផង។ ជាតិនិយមជ្រុលរហូតហាមឃាត់កូនខ្មែរមិនឱ្យសិក្សាភាសាបរទេស ជាកំហុសមួយធ្ងន់ ព្រោះគេអាចចោទថា

បង្អាក់ដំនើរសិក្សាកូនខ្មែរ ។ ប៉ុន្តែតំលៃពិតស្ថិតនៅលើស្មារតីជាតិដែលពុំមែនចេះភាសាបរទេសដើម្បីបំរើបរទេសបង្អាប់បង្អោនភាសាជាតិនោះទេ គឺត្រូវចេះយកចំនេះខ្លួនមកប្រើធ្វើខេមរនីយកម្ម តាមខេមរនីយកម្មវិធីឱ្យមានខេមរភាពឡើងដើម្បីធ្វើឱ្យភាសាជាតិចំរើនលូតលាស់ថែមទៀត ។

ការពិនិត្យពាក្យពេចន៍ចាស់ៗ ការបង្កើតពាក្យថ្មីតាមសេចក្តីត្រូវការថ្មី ។ ការបង្កើតអង្គការជាតិដែលទុកជាអង្គការកណ្តាល សំរាប់រកមូលភាពភាសាជាតិជាការចាំបាច់មួយព្រោះភាសាខ្មែរយើងសព្វថ្ងៃពុំទាន់មានមូលភាពផ្លូវការច្បាស់លាស់នៅឡើយ ។ គោលការណ៍ច្បាស់លាស់របស់ភាសាជាតិកំលាំងបង្កើនចលនាអភិវឌ្ឍន៍វប្បធម៌ ។

៚

ប្រធានទី ១២

**អ្នកខ្លះយល់ថា: "ភាសាខ្មែរមានឫសគល់ចេញមកពីបាលី-សំស្ក្រឹត" តើអ្នកយល់ស្របដែរឬទេ?**

មនុស្សរស់នៅជាសហគមន៍តាមទំនាក់ទំនងឈាម និងទំនាក់ទំនងសេដ្ឋកិច្ច។ ល្បឿនអភិវឌ្ឍន៍សហគមន៍ឋិតនៅលើធនធាន និងមធ្យោបាយរួមសំរាប់បង្កើតផល។ ប៉ុន្តែកត្តាមួយទៀតមានសារៈសំខាន់ណាស់ដែរ ដែលជាមធ្យោបាយសំរាប់ឱ្យមានទំនាក់ទំនងរវាងញាណមនុស្ស គឺភាសា។ ភាសាជាឧបករណ៍បង្កើនល្បឿនអភិវឌ្ឍន៍សង្គមមនុស្ស។ សង្គមជាតិនីមួយៗ តែងមានភាសាផ្ទាល់សំរាប់ប្រើប្រាស់តាមសេចក្ដីត្រូវការរបស់ខ្លួន។ តែអ្នកខ្លះបែរជាខំអះអាងថាខ្មែរគ្មានភាសាទេ ព្រោះភាសាខ្មែរមានឫសគល់ចេញមកពីបាលី-សំស្ក្រឹតទៅវិញ។ តើភាសាខ្មែរដែលជាជាតិសាសន៍មួយនឹងគេដែរនោះ គ្មានភាសាមែនរឺដូចម្ដេច? តើបាលី-សំស្ក្រឹតជាម្ដាយភាសាខ្មែរ រឺយ៉ាងណា?

តាមការសង្កេត ភាសាបាលី-សំស្ក្រឹតមាននៅលាយចំរុះនឹងភាសាខ្មែរមែន។ ល្បាយភាសានេះមានតាំងតែពីយូរណាស់មកហើយ។ ទំនាក់ទំនងនយោបាយ សេដ្ឋកិច្ច និងសាសនាចាប់ពីគ្រឹស្តសតវត្សទី ១ រវាងខ្មែរ និងឥណ្ឌា បានធ្វើឱ្យភាសាឥណ្ឌាជ្រាបចូលក្នុងភាសាខ្មែរជាច្រើន។ ពុទ្ធសាសនាបានធ្វើឱ្យភាសាបាលីចំរើនលូតលាស់ សាសនាព្រាហ្មណ៍បានផ្សាយភាសា-សំស្ក្រឹត។ ដោយឥទ្ធិពលឥណ្ឌាជះចូលយ៉ាងខ្លាំងក្នុងផ្នែកនយោបាយ ភាសា-សំស្ក្រឹតក្លាយទៅជាភាសាផ្លូវការក្នុងកិច្ចការរដ្ឋបាលក្នុងសម័យបុរាណ។ ម្យ៉ាងទៀតដោយចំនេះថ្មីៗមកបញ្ជាក់ពន្យល់ ខ្មែរត្រូវខ្ចីភាសានេះពីបាលី-សំស្ក្រឹត អាស្រ័យហេតុនេះហើយកំចីបាលីសំស្ក្រឹតក្នុង ភាសាខ្មែរមានច្រើនសន្ធឹកសន្ធាប់ណាស់។ ប៉ុន្តែកំចីបរទេសខ្លះដែលមានក្នុងភាសារបស់ជនជាតិមួយ ដូចនេះតើអាចចាត់ទុកថា ជាភស្តុតាងបញ្ជាក់ថាឫសគល់របស់ភាសាជាតិ គឺភាសាបរទេសបានដែរ រឺទេ?

ជីវភាពតំរូវឱ្យមនុស្សទាក់ទងគ្នា។ ទំនាក់ទំនងអន្តរជាតិក្នុងវិស័យនយោបាយសេដ្ឋកិច្ច និងវប្បធម៌តំរូវឱ្យភាសាឆ្លងគ្នាទៅវិញទៅមក។ កំចីភាសារបស់ជនជាតិមួយពីជនជាតិមួយទៀតតែងមានជាធម្មតា។ ដូចនេះកំចីខ្លះពីបរទេសពុំមានន័យថាឫសគល់ភាសា គឺបរទេសទេ។ យ៉ាងណាមិញភាសាខ្មែរនិងភាសាបាលីសំស្ក្រឹតជាភាសាពីរដាច់ដោយឡែកពីគ្នា។ ភាសាបាលីសំស្ក្រឹតស្ថិតក្នុងអំបូរឥណ្ឌូ អឺរ៉ុប គឺជាភាសាមានវិភត្តិ ចំនែកភាសាខ្មែរស្ថិតក្នុងអំបូរ ខ្មែរ-មនទៅវិញ។ តើភាសាខ្មែរនិងបាលី-សំស្ក្រឹតមាន លក្ខណៈខុសគ្នាយ៉ាងណាខ្លះ?

វិភាគស្រៈ ព្យញ្ជនៈ ព្យាង្គ បានបង្ហាញថាភាសាខ្មែរមានគោលពិសេសមួយគឺសំលេង អ -អ៊ ភាសាមនមានសំលេង អ- អ៊ សេចក្តីថាមានសូរជាគូរគ្នាឯភាសាបាលី-សំស្ក្រឹតវិញមានតែសំលេងមួយគឺសូរ អះ។ សូរ អ-អ៊ ពុំមែនជាសូរឃោសៈ អឃោសៈទេ ព្រោះឃោសៈជាសំលេងញ័ររញ្ជួយ អឃោសៈជាសូរមិនញ័ររញ្ជួយទេគឺសូរថ្លង់។ ចំណែក អ អ៊ ជាសូរមិនញ័ររញ្ជួយដូចគ្នា គ្រាន់តែមួយសូរ អមួយសូរ អ៊។

ចំណុចសំខាន់មួយទៀតគឺចំនួនព្យាង្គ ពាក្យខ្មែរមានព្យាង្គតិច បាលី-សំស្ក្រឹតមានព្យាង្គច្រើន។ ពាក្យខ្មែរច្រើនតែព្យាង្គតិចយ៉ាងច្រើនពីរព្យាង្គ តែកាលណាពាក្យមានពីរព្យាង្គ អំនាននៅតែមានទំនោរផ្តួបព្យាង្គដូចជាពូកែគេថា ពកែ ប្រអប់គេថា បះអប់ មួយដុំគេថា ម៉ុំ មួយដង គេថាម្តង។ ទំនោរបង្រួមព្យាង្គនេះមានឥទ្ធិពលខ្លាំងទៅលើពាក្យបាលីសំស្ក្រឹត សេចក្តីថាពាក្យបាលី-សំស្ក្រឹតដែលចូលក្នុងភាសាខ្មែរត្រូវខ្មែរកាត់ចោលខ្លះ ដើម្បីឱ្យនៅតែមួយព្យាង្គដូចជា ពាក្យសម្ពាធិក្លាយទៅជាស្នាធ៍" ៣ ព្យាង្គនៅសល់តែ មួយព្យាង្គ " ជាតិអានថាជាត " ២ ព្យាង្គនៅសល់តែមួយព្យាង្គ"។ នេះជាភស្តុតាងមួយទៀតបញ្ជាក់ឱ្យឃើញថាខ្មែរបានប្រើខេមរនីយវិធីដើម្បីកាលៃពាក្យបាលី-សំស្ក្រឹតឱ្យមកជាខ្មែរ ពុំមែនចំលងតាមឥណ្ឌាឡើយ។

លក្ខណៈពិសេសមួយរបស់ខ្មែរ គឺត្រង់មានស្រៈផ្គុំតួក្នុងតួព្យញ្ជនៈដូចជា ក មានស្រៈ អ គ មានស្រៈ អ៊ ក្នុងនោះ ដូចនេះ ហើយបានជាព្យញ្ជនៈតែមួយក៏អាចទៅជាព្យាង្គមួយបានដែរ ដូចកដៃ កជើង មនុស្ស គ។ល។ ប៉ុន្តែព្យញ្ជនៈជាតួប្រកបគ្មានស្រៈផ្គុំតួទេ ដូចជាពាក្យ គុក ក គ្មានសូរឡើយ។ ចំនែកភាសាបាលី-សំស្ក្រឹតវិញគ្មានលក្ខណៈបែបនេះទេ។

វិធីកំលាយពាក្យខ្មែរមានលក្ខណៈផ្ទាល់ខ្លួនប្លែកពីបាលី-សំស្ក្រឹត។ ខ្មែរមានវិធីកំលាយធ្វើឱ្យឫសពាក្យតែមួយ បែកជាពាក្យច្រើនមានន័យប្លែកគ្នាដូចជាឫស កើតក្លាយទៅជា បង្កើត ខ្មើត ខ្នើត កំណើត ចុក បញ្ចុក ឆ្នុក ឆ្នុក ចំណុច។ វិធីកំលាយស្នៀតដែលចុះព្យញ្ជនៈជ្រៀតចូលកណ្ដាលឫសខ្មែរប្លែកពីអាគមក្នុងពាក្យបាលី-សំស្ក្រឹត ព្រោះអាគមគ្រាន់តែមកចុះសំរួលភ្ជាប់សន្ធិឱ្យពិរោះតែប៉ុណ្ណោះ ពុំមែនដូចស្នៀតខ្មែរចុះមកបំបែករីសឱ្យមានន័យប្លែកឡើយ ដូចជា : អ+ អត្ត > អ+ន+អត្ត > អនត្ត (នៈអាគម)។ ចំណែកបទភ្ជាប់ខាងចុង (suffixe) ពុំឃើញមានក្នុងភាសាខ្មែរយើងទេ។

ភាសាក្នុងអំបូរតណ្ឌា អឺរ៉ុបសុទ្ធតែមានលិង្គសំគាល់ (ភេទស្រី ឬញី) នបុំសកលិង្គ (មិនមែនប្រុស-ស្រី) (neutre)។ គេអាចស្គាល់លិង្គទាំងបី ដោយសារការន្ត (terminaison)។ វចនៈ (nombre) របស់នាមក៏មានគ្រឿងសំគាល់ជាប់នឹងពាក្យដែរ ដូចជាមនុស្សោ (ឯកវចនៈ) មនុស្សា (ពហុវចនៈ) កាលណាពាក្យនោះមានលក្ខណៈជាកម្មបទ។ តើពាក្យខ្មែរលិង្គ និងវចនៈដូចគ្នាដែររឺទេ?

វេយ្យាករណ៍ខ្មែរច្រើនពន្យល់ជាភាសាខ្មែរភ្ជាប់នឹងភាសាបាលី-សំស្ក្រឹតម្ល៉ោះហើយខំពន្យល់ លិង្គនិងវចនៈក្នុងភាសាខ្មែរ។ តាមការពិចារណាហ្មត់ចត់មែនទែនទៅ ពាក្យខ្មែរគ្មានលិង្គនិងវចនៈទេ កាលណាគេចង់បញ្ជាក់ភេទរឺចំនួនគេត្រូវប្រើពាក្យបន្ថែម ដូចជា មាន់ញី ជ្រូកឈ្មោល គោមួយ ក្របីទាំងឡាយ ។ល។

ដូចនេះពាក្យខ្មែរមិនផ្លាស់ប្ដូរតាមភេទ តាមចំនួន តាមមុខងារទេ

ម្ល៉ោះហើយគ្មានប្រយោជន៍ទាល់តែសោះក្នុងការធ្វើ សម្ព័ន្ធឃ្លា។ ភាសាខ្មែរគ្មាន (indeclinle) វិភត្តិ ផ្ទុយពីបាលី-សំស្ក្រឹតដែលជាភាសាមានវិភត្តិ គឺជាភាសាដែលពាក្យត្រូវផ្លាស់ប្ដូរ តាមទំនាក់ទំនង (accord) ឃ្លា។

សេចក្ដីអធិប្បាយមកនេះ បញ្ជាក់ឱ្យឃើញថា ភាសាខ្មែរ និងភាសាបាលី-សំស្ក្រឹតជាភាសាពីរដាច់ដោយឡែកពីគ្នាក្នុងអំបូរផ្សេងគ្នា។ សូរក្តី សព្ទក្តី សម្ព័ន្ធកំលាយពាក្យក្តី មានលក្ខណៈខុសគ្នាឆ្ងាយណាស់។ ប៉ុន្តែទំនាក់ទំនងរវាងខ្មែរ និងឥណ្ឌាបានធ្វើឱ្យមានល្បាយភាសាខ្មែរ បាលី-សំស្ក្រឹត។ ល្បាយនេះជាការធម្មតាទេ ព្រោះគ្រប់ភាសាក្នុងលោកតែងឆ្លងគ្នាបែបនេះឯង។ ប៉ុន្តែតំលៃស្ថិតត្រង់ចេះកាលៃពាក្យបរទេសសំរូលតាមលក្ខណៈជាតិ តាមមូលភាពជាក់លាក់។ ដូចនេះ ភាសាខ្មែរពុំមែនមានឫសគល់មកពីបាលី-សំស្ក្រឹតទេ គឺជាភាសាមួយផ្សេងក្នុងអំបូរខ្មែរមន មានមូលភាព មូលវិធីតម្រាក្បួនច្បាប់ស្រដីជាក់លាក់របស់ខ្លួន។ ការស្គាល់ភាសា ជាតិមិនច្បាស់ជាកត្តាមួយធ្វើឱ្យខ្មែរគ្មានមោទនៈភាព ហើយខំភ្ជាប់ភាសាខ្លួនទៅនឹងបរទេស។ យល់បែបនេះពុំទាន់មានស្មារតីជាតិជាក់លាក់ទេ ព្រោះស្មារតីជាតិស្ថិតនៅលើចំនេះ ចេះច្បាស់ យល់ច្បាស់ ពីឫសគល់វប្បធម៌ជាតិនេះឯង។

៚

ប្រធានទី ១៣

## អក្សរខ្មែរមានលក្ខណៈដូចម្ដេចខ្លះ?

ដើម្បីសំដែងឱ្យអ្នកដទៃយល់គំនិត និងដើម្បីយល់គំនិតអ្នកដទៃមនុស្សបានបង្កើតភាសា។ ភាសានិយាយអាចទាក់ទងគ្នា បានផ្ទាល់ក្នុងទីជិតគ្នា និងក្នុងពេលតែមួយដើម្បីពង្រីកទំនាក់ទំនងក្នុងកាលអាកាសនេះ មនុស្សបានបង្កើតសញ្ញាសំរាប់កត់សំគាល់ភាសា។ សញ្ញានេះក្រោយមកបានក្លាយជាអក្សរ។ អក្សរបានវិវត្តន៍ក្នុងកំឡុងពេលជាច្រើនសតវត្ស តាមលក្ខណៈភាសារបស់ជនជាតិនិមួយៗ។ តើអក្សរខ្មែរសព្វថ្ងៃមានលក្ខណៈយ៉ាងណាខ្លះ?

អក្សរជាកំរងសញ្ញាប្រទាក់គ្នាជាក្បួន ស្ថិតលើមូលភាពភាសាមួយជាក់លាក់។ អក្សរខ្មែរក៏មានក្បួនតម្រាប្រទាក់តួសញ្ញា ទាំងនោះតាមមូលវិធីរបស់ខ្លួនដែរ។ ព្យញ្ជនៈនិងស្រៈទាក់ចូលគ្នា គេហៅថាស្រៈកប់ រឺស្រៈអនុស័យក្នុងព្យញ្ជនៈ។ ស្រៈអនុស័យមាន ពីរបែបគឺ អ និង ពួក-អ៊ិស្រៈពីរពួកបានទាញព្យញ្ជនៈឱ្យមានពីរពួកដែរដូចជា ព្យញ្ជនៈ ក ខ ច ឆ និងព្យញ្ជនៈ គ ឃ ជ ឈ។ ចំនែកស្រៈនិស័យ អ អ៊ិ ដូច កី ទៅ កី "ពួកអ" គី ទៅជា គី "ពួកអ៊ិ"ទៅវិញ។ ព្យញ្ជនៈមានស្រៈអនុស័យមួយតួអាចជាព្យាង្គមួយបានដែរ ដោយសារតែស្រៈអនុស័យក្នុងព្យញ្ជនៈនេះឯងដូច ត គឺជាព្យាង្គមួយ "តខ្សែ" ស "ពណិស" ខ "ខត្រី" ។ល។ អក្សររ៉ូម៉ាំង "Romain" មានបារាំងជាដើម ព្យញ្ជនៈមិនអាចទៅជាព្យាង្គបានឡើយ អាចទៅជាព្យាង្គបានលុះត្រាតែភ្ជាប់ជាមួយស្រៈ។ អក្សរ រ៉ូម៉ាំងតួនៅជិតគ្នាពុំអាចទៅជាព្យាង្គបានទេ គឺគ្រាន់តែជាព្យញ្ជនៈផ្សំដូច "Pr" Prouver "Str" Structure ចំនែកអក្សរខ្មែរវិញ តួព្យញ្ជនៈពីរជាគ្នាក៏អាចទៅជាព្យាង្គមួយបានដែរ ព្រោះមានស្រៈកប់ក្នុងព្យញ្ជនៈដើមរួចហើយ តែព្យញ្ជនៈចុងគ្មានស្រៈកប់ទេ ម្ល៉ោះហើយសូរក៏គ្មានដែរ ដូចជា កម គង ចក ។ល។

ព្យញ្ជនៈផ្សំខ្មែរសរសេរត្រួតគ្នា ជាហេតុបណ្ដាលឱ្យមានការបង្កើតជើងអក្សរព្រោះព្យញ្ជនៈមួយផ្សំនឹងជើងព្យញ្ជនៈមួយទៀត កើតជាព្យញ្ជនៈផ្សំដូចជាៈ ខ្ល "ខ្លួន" ឆ្ល "ឆ្លង" ឆ្ន "ឆ្នាំ "។ល។

ម្យ៉ាងទៀតជើងព្យញ្ជនៈអាចប្រើជាព្យញ្ជនៈដើមព្យាង្គ នៃព្យាង្គតំរូតថែមទៀតដូចជា ពន់+ យល់ > ពន្យល់។

លក្ខណៈពិសេសរបស់អក្សរខ្មែរយើងគឺតួព្យញ្ជនៈមានសក់។ យើងធ្លាប់យកសក់ ក"៊ " មកប្រើដើម្បីបំបែរសព្ទ ព្យញ្ជនៈ ពួក អ ឱ្យមក អ៊ិ វិញដូចជា ប៊ិ ស៊ិ ហ៊ិ។ សក់នេះទំរង់ជាក្បាច់រំលេច ដើម្បីធ្វើឱ្យតួអក្សរមានរូបរាងឆើតឆាយឡើងព្រោះបុព្វបុរសខ្មែរ ជាអ្នកមានថ្វីដៃល្បាញល្បីខាងសិល្បៈរចនា។ ចំនែកអក្សរសៀម លាវ ដែលយកលំនាំតាមខ្មែរបានកាត់សក់ចេញនៅសល់តែតួ។

សេចក្ដីអធិប្បាយមកនេះ បង្ហាញឱ្យឃើញថាអក្សរខ្មែរមានរាងរៅមានក្បួនច្បាប់ មានវិធីច្បាស់លាស់ ដែលគេអាចយកមកប្រើសំរាប់កត់ត្រាគំនិតព្រឹត្តិកាណ៍ សញ្ចេតនា និងវិជ្ជាផងទាំងពួងបានតាមសេចក្ដីត្រូវការ។

## ប្រធានទី ១៤

**លោក "J. Taupin" អះអាងថាអក្សរសិល្ប៍ និងភាសាខ្មែរ ជាកូនរបស់ភាសាសំស្ក្រឹត តើអ្នកយល់ស្របបែបណា?**

**គោលគំនិត :**

១ - ហេតុអ្វីបានជាថា អក្សរសិល្ប៍ និងភាសាខ្មែរជាកូនសំស្ក្រឹត?

- មកពីទទួលឥទ្ធិពលព្រហ្មណ៍សាសនា :
- សម័យមុនអង្គរ "សតវត្សទី ១- ទី ៨" : គេច្រើនប្រើភាសាសំស្ក្រឹត
- សិលាចារិកជាច្រើនសរសេរជាសំស្ក្រឹត

**សម័យអង្គរ : មានពីរបែប :**

-មួយសរសេរលើក្បាលសត្វ "ខូចអស់"

-មួយចារលើផ្ទាំងថ្ម " នៅសល់ដល់សព្វថ្ងៃ"

-អ្នកនិពន្ធប្រើភាសាសំស្ក្រឹត និងភាសាខ្មែរបុរាណ

**សម័យក្រោយអង្គរ :**

-ចាប់ពីសតវត្សទី ១៧ មក អក្សរសិល្ប៍ចាប់ផ្តើមសរសេរលើស្លឹករឹត រឹលើក្រាំង " ឥទ្ធិពលពុទ្ធសាសនាខ្លាំងជាងភាសាបាលីមានឧត្តមភាព " ដោយឃើញមានអត្ថបទជាភាសាសំស្ក្រឹត តាំងពីសម័យបុរាណបែបនេះហើយ បានជាគេយល់ថាសំស្ក្រឹត ជាម្តាយអក្សរសិល្ប៍ និងភាសាខ្មែរ ។

២ - សំស្ក្រឹតជាម្តាយអក្សរសិល្ប៍ និងភាសាខ្មែរមែនរឺ?

-ពុំអាចយល់ស្របបានទេព្រោះ

-អត្ថបទខ្មែរមានកំនើតតាំងពីហ្វូណនមក

-ភាសា និងសំស្រ្កឹតស្ថិតនៅក្នុងអំបូរផ្សេងៗគ្នា

-អក្សរសិល្ប៍ខ្មែរពុំអាចចំលងតាមឥណ្ឌាទេ ទោះបីមានប្រភពពីឥណ្ឌាក៏ដោយ ដូចជារឿងរាមកេរ្តិ៍ពុំចំលងតាម រាមាយណៈទេ តែយករាមាយណៈមកកាឡៃ ដូចជាធ្វើឱ្យព្រះរាមមកជាមនុស្សទេវិញ ពុំនៅជាទេវតាព្រះវិស្ណុដូចឥណ្ឌាឡើយ ។

៣ - ពិភាក្សា :

តាមពិតជាយោបល់លោក J. Taupin មិនទាន់សមរម្យនៅ ឡើយព្រោះ

-ភាសាសំស្រ្កឹត និងភាសាខ្មែរមានអំបូរផ្សេងគ្នា " មើលប្រធានទី ១៣"

-អក្សរសិល្ប៍ខ្មែរ ទោះបីមានប្រភពចេញពីឥណ្ឌាក៏ខ្មែរកាឡៃមកជាខ្មែរទៅហើយដែរ ។

-នេះបង្ហាញពីសមត្ថភាពរបស់ខ្មែរ ដែលអាចយកធាតុបរទេសមកធ្វើឱ្យមានខេមរភាព និងសង្គមភាព ។

## ជំពូក៣

### សិល្បៈ

ក. ស្ថាបត្យកម្ម Arechitecture

ចែកជា ១២រចនាបថ "Style"

១. រចនាបថ សំបូរ

២. រចនាបថ ព្រៃក្មេង សម័យចេនឡា

៣. រចនាបថ កំពង់ព្រះ

៤. រចនាបថ គូលេន

៥. រចនាបថ ព្រះគោ

៦. រចនាបថ បាខែង

៧. រចនាបថ កោះកេរ

៨. រចនាបថ បន្ទាយស្រី សម័យអង្គរ

៩. រចនាបថ ឃ្លាំង

១០. រចនាបថ បាពួន

១១. រចនាបថ អង្គរវត្ត

១២. រចនាបថ បាយ័ន

ខ. ចម្លាក់ "Sculpture"

គ. ភ្លេង

១- ប្រភេទភ្លេង

- ភ្លេង ពិណពាទ្យ
- ភ្លេង ខ្មែរ
- ភ្លេង មហោរី
- ភ្លេងអារក្ស
- ភ្លេង ក្លងធ្លាក់
- ភ្លេង ស្គរយោល
- ភ្លេង គងស្គរ

២- ឧបករណ៍ភ្លេង

- ទ្រ : ទ្រខ្មែរ ទ្រអ៊ូ ទ្រសោ ទ្រឆេ
- ស្គរ មុខពីរ

- គងតូច គងធំ
- រនាត ខ្លុយ ឆៃយ៉ាំ សាដៀវ

ឃ. របាំ

១- របាំប្រពៃណី :

- របាំ ភាវង់
- របាំ ត្រុដិ
- របាំ ក្ងោក
- របាំ គោះអង្រែ
- របាំ យីកេ
- របាំ ឆៃយ៉ាំ
- របាំ ស្នែងទន្សោង

ល្ខោន : ល្ខោននិយាយ ល្ខោនបាសាក់ ល្ខោនខោល ណាំងស្បែក

២- របាំរន្ត្រី

-របាំថ្វាយព្រះពរ
-ទេពមនោរម្យ
-នារីជាជួរ
-របាំមេអំបៅចេរិត ចៅដួង។

## ប្រធានទី ១៥ មូលដ្ឋាននៃ អភិវឌ្ឍន៍សិល្បៈខ្មែរ

**គោលគំនិត** សិល្បៈខ្មែរជាផែកផាងវប្បធម៌ជាតិ ដែលបានបញ្ចេញរាងបង្អួតបរទេស ខ្លាំងជាងគេព្រោះសំនង់ប្រាសាទរបស់បុព្វបុរសខ្មែរ មានលក្ខណៈសំបើមល្អឆើតគួរឱ្យចាប់អារម្មណ៍តែម្តង។ តើអ្វីជាមូលដ្ឋានទ្រទ្រង់អភិវឌ្ឍន៍សិល្បៈខ្មែរ ?

### ១. មូលដ្ឋានភូមិសាស្ត្រ

ប្រទេសខ្មែរស្ថិតនៅលើជ្រោយឥណ្ឌូចិនតាំងពីសម័យដើមមក។ ទីតាំងនេះតំរូវឱ្យមានទំនាក់ទំនងនឹងមហាអំនាចធំ ។ព្រោះ បើគិតតាមផ្លូវសមុទ្រប្រទេសយើងនៅកណ្តាល ម្ល៉ោះហើយបេសកជនខាងនយោបាយក្តី ខាងសាសនាក្តី ត្រូវឈប់សុំចតនៅកំពង់ផែ អូ កែវ។ ទីតាំងផ្លូវទំនាក់ទំនងបរទេស ជាពិសេសមហាអំនាច ចិន និងឥណ្ឌាធ្វើឱ្យខ្មែរក្លាយទៅជាមជ្ឈដ្ឋានបើកចំហទទួល អរិយធម៌បរទេស គឺជាទីដែលចរន្តគំនិតចំរុះគ្នា។ មូលដ្ឋានភូមិសាស្ត្រធ្វើឱ្យខ្មែរមានទំនាក់ទំនងជាមួយបរទេសគ្រប់ជាតិសាសន៍ ហើយទំនាក់ទំនងនេះជាកត្តានៃការអភិវឌ្ឍន៍ខាងសិល្បៈផងដែរ។

### ២. មូលដ្ឋានប្រវត្តិសាស្ត្រ :

ខ្មែរបានទទួលមនុស្សមកពីក្រៅ កាត់ជាមួយពូជជនជាតិដើមរលាយទៅជាខ្មែរសព្វថ្ងៃនេះ។ រឿងហ៊ុន ទៀន មកពីឥណ្ឌាមករៀបការជាមួយ លីវ យី រឿងព្រះថោង មកការជាមួយនាង នាគ សុទ្ធតែជាភស្តុតាង បញ្ជាក់ឱ្យឃើញថាមានធាតុបរទេសចូលមកពីក្រៅមកផ្សំជាមួយធាតុខាងក្នុង។

មូលដ្ឋានភូមិសាស្ត្រ និងប្រវត្តិសាស្ត្រជំរុញឱ្យខ្មែរមានទំនាក់ទំនងជាមួយបរទេស ហើយសិល្បៈក៏មានលក្ខណៈជាសិល្បៈ ចំរុះឥទ្ធិពលបរទេស។ សម័យហ្វូណនខ្មែរ មានទំនាក់ទំនងជាមួយឥណ្ឌា និង ចិន តាមផ្លូវទូត រឺសាសនា សម័យចេនឡា មានទំនាក់ទំនងជាមួយគ្នា។ ជ័យវរ្ម័នទី ២ ដែលជាស្តេចបង្រួបបង្រួមខ្មែរឱ្យមានឯកភាពជាតិ នៅសតវត្សទី ៩ ទ្រង់យាងមកពីជ្វានេះឯង។ ទំនាក់ទំនងជាមួយចាម ជួនជាមិត្ត ជួនជាសត្រូវជាមួយសៀម យួន បាននាំមកនូវឥទ្ធិពលចំរុះ ក្នុងគ្រប់មែកធាងអរិយធម៌។

## ៣. មូលដ្ឋានសាសនា :

សាសនាមានឥទ្ធិពលខ្លាំងក្នុងសង្គមខ្មែរ។ សិល្បៈច្រើនធ្វើតាមមូលដ្ឋាននេះ ដូចជាប្រាសាទ ក្បាច់ចម្លាក់ រូបបដិមា សុទ្ធតែទាក់ទងនឹងសាសនា។ ទោះបីក្រយ៉ាងណាក៏ខ្មែរនៅតែបន្តធ្វើពលិកម្មបូជាសាសនាដែរ ដូចជាផ្ទះនៅខ្លួនឯងធ្វើពីឈើប្រក់ស្លឹក តែព្រះវិហាររឺញសុទ្ធតែធ្វើពីថ្មធំៗ។ អស្ចារ្យប្រាសាទសុទ្ធតែសម្បើមៗម្ល៉ោះហើយស្នាដៃសិល្បៈជាប់ទៅនឹងសាសនានេះឯង។

អ្នកខ្លះបានអះអាងថា សិល្បៈខ្មែរជាសិល្បៈសាសនា។ ត្រង់នេះមានការពិតច្រើនតែសិល្បៈខ្មែរមានលក្ខណៈមនុស្សនិយមផងដែរពុំមែនសាសនាសុទ្ធសាធទេ។

តាមប្រវត្តិសាស្ត្រ សាសនាពីរបានចូលមកជាមួយគ្នាក្នុងសង្គមខ្មែរ គឺសាសនាព្រាហ្មណ៍ និងពុទ្ធសាសនា សាសនាទាំងពីររលាយចូលក្នុងជំនឿខ្មែរដែលមានរួចមកហើយក្នុងមូលធម៌ខ្មែរ-មន។ សាសនាទាំងពីររួមរស់ជាមួយគ្នាយ៉ាងសុខសាន្ត គ្រាន់តែមានការប្រែប្រួលបន្តិចបន្តួច លើកលែងតែក្នុងរាជ្យជ័យវរ្ម័នទី ៨ ដែលមានជំលោះសាសនាម្តង។

សាសនាមានឥទ្ធិពលខ្លាំងទៅលើសិល្បៈខ្មែរ។ គេខិតខំធ្វើអ្វីៗឱ្យមានលក្ខណៈសំបើមដើម្បីគោរពបូជាតាមជំនឿរបស់គេ។

ដូចនេះមូលដ្ឋានភូមិសាស្ត្រ ប្រវត្តិសាស្ត្រនិងសាសនាជាកត្តាធ្វើឱ្យមានការអភិវឌ្ឍន៍សិល្បៈខ្មែរ។ អភិវឌ្ឍន៍នេះ ពុំមែនស្ថិត នៅលើមូលដ្ឋានបរទេសទេ តែផ្ទុយទៅវិញស្ថិតនៅលើទេពកោសល្យខ្មែរ ដែលចេះទទួលយកធាតុបរទេសគ្រប់បែបមកច្នៃសំរបសំរួលតាមទស្សនៈជាតិរបស់ខ្លួន។ ទេពកោសល្យខាងសមានកម្មនេះហើយ ជាកត្តាធ្វើឱ្យមានការរីកចំរើន។

៙០៙

## ប្រធានទី ១៦

### ទស្សនៈអ្នកប្រាជ្ញបរទេសចំពោះសិល្បៈខ្មែរ

**គោលគំនិត**

យើងសង្កេតឃើញថា អ្នកប្រាជ្ញបរទេសដែលបានសិក្សាពីសិល្បៈខ្មែរ មកវិនិច្ឆ័យមិនដូចគ្នាទេ :

១- អ្នកខ្លះយល់ឃើញថា សិល្បៈខ្មែរដូចគ្នា និងសិល្បៈឥណ្ឌា។ អះអាងបែបនេះគឺ គេសំអាងទៅលើប្រាសាទខ្មែរបុរាណដែលមានទាក់ទងនឹងឥណ្ឌាច្រើន។ គេហ៊ានដល់ទៅនិយាយថា បើចង់ស្គាល់សិល្បៈឥណ្ឌា គឺស្គាល់សិល្បៈឥណ្ឌាតែម្តង។ គេថារាងរៅខុសគ្នា ខ្លះមែន ប៉ុន្តែក្បាច់រចនាចំលាក់គឺដូចគ្នានឹងឥណ្ឌាបេះបិត តាមពិតសិល្បៈខ្មែរមានទទួលឥទ្ធិពលឥណ្ឌាពិតមែន។

២- អ្នកខ្លះយល់ថា សិល្បៈខ្មែរគឺជារបស់ខ្មែរសុទ្ធសាធគ្មានចំលងពីឥណ្ឌា ឬជាតំណាងមួយឡើយ។ ខ្មែរជាជនជាតិមួយមាន អរិយធម៌ខ្ពង់ខ្ពស់ ម៉្លោះហើយស្នាដៃសិល្បៈក៏មានច្រើនសំបើមព្រមទាំងល្អប្លែក ធ្វើឱ្យបរទេសចាប់អារម្មណ៍យ៉ាងខ្លាំង។ គំនិតនេះ ពុំជាក់ច្បាស់មែនទែននៅឡើយទេ ព្រោះសិល្បៈក្នុងពិភពលោកនេះ តែងទាក់ទងគ្នា ចំលងគ្នាទៅវិញទៅមកតាមទំនាក់ទំនងវប្បធម៌ អរិយធម៌។

៣-អ្នកខ្លះយល់ថា សិល្បៈខ្មែរជាលទ្ធផលនៃការបូកបញ្ចូលគ្នារវាងខ្មែរនិងឥណ្ឌា។ មតិនេះមានការសមរម្យច្រើនព្រោះវប្បធម៌ខ្មែរ និងឥណ្ឌាជាប់ទាក់ ទងគ្នារលាយចូលគ្នាខ្លះ កែច្នៃគ្នាទៅវិញទៅមកខ្លះ។ តាមប្រវត្តិសាស្ត្រខ្មែរធ្លាប់ទទួលឥទ្ធិពលអរិយធម៌ ឥណ្ឌា ដូចនេះសិល្បៈក៏តែងតែមានឥទ្ធិពលនេះជាដរាប។

ប៉ុន្តែខ្មែរមានសិល្បៈផ្ទាល់របស់ខ្លួនច្បាស់លាស់ទៅហើយ ពុំមែនយកសិល្បៈឥណ្ឌាមកទាំងស្រុងទេ គឺពិតជាយកមកការច្នៃឱ្យស្របតាមទស្សនៈខ្មែរ ម្ល៉ោះហើយចេញជាលទ្ធផលមួយប្លែក ពីលក្ខណៈដើម គឺមានវិវត្តន៍ពីបរទេសមកខ្មែរ ។

ប៉ុន្តែការអះអាងប៉ុននេះ មិនទាន់គ្រប់គ្រាន់នៅឡើយទេ ព្រោះខ្មែរមានទំនាក់ទំនងជាមួយជនជាតិជិតខាងជាច្រើនទៀត ដូចនេះសិល្បៈខ្មែរច្បាស់ជាមានឥទ្ធិពលជាតិទាំងនោះ មាន ចិន ជ្វា ឥណ្ឌូនេស៊ីជាដើម ។

ឥទ្ធិពលបរទេសក្នុងសិល្បៈខ្មែរពុំមែនធ្វើឱ្យខូចតំលៃទេ ព្រោះជាការធម្មតាទៅហើយ គ្រប់មែកធាងអរិយធម៌ក្នុងលោកតែងទាក់ទងគ្នា ។ តែតំលៃស្ថិតនៅត្រង់សមត្ថភាពចេះការច្នៃធាតុបរទេសឱ្យស្របតាមលក្ខណៈជាតិ ផ្សំផ្សំនឹងធាតុចាស់របស់ខ្លួនឱ្យចេញជាស្នាដៃមួយថ្មីឡើង ។ សមត្ថភាពបែបនេះជាតំលៃ ព្រោះជាកត្តានៃការចំរើនលូតលាស់ ។ ផ្ទុយទៅវិញបើខ្មែរជាជនជាតិល្ងង់គ្មានវប្បធម៌ផ្ទាល់របស់ខ្លួននោះ ខ្មែរពិតជាមិនអាចកាច្នៃធាតុបរទេសបានឡើយ គឺមានតែការចំលងតាមគេទាំងដុលតែម្តងជាពុំខានឡើយ ។

៙០៙

## ប្រធានទី ១៧

### ស្ថាបត្យកម្ម "Architecture"

ខ្មែរជាជនជាតិមានទេពកោសល្យក្នុងវិស័យសិល្បៈ។ ស្នាដៃជាច្រើនអាចជាភស្តុតាងបញ្ជាក់គំនិតនេះជាពិសេសស្ថាបត្យកម្ម និងចំលាក់។ តែគេមិនដឹងថាវិស័យក្រៅពីនេះមានការរីកចំរើនលូតលាស់យ៉ាងណាដែរទេ។ តើស្នាដៃណាខ្លះជាសំណល់ដែលអាចបញ្ជាក់ថាខ្មែរមានទេពកោសល្យខាងសិល្បៈបាន? គួរឱ្យស្តាយណាស់ព្រោះស្នាដៃជាច្រើនបានរលាយបាត់ទៅហើយ។

អ្វីធ្វើពីឈើមិនអាចទប់ទល់ នឹងកំលាំងធម្មជាតិនៅសេសសល់មកដល់សព្វថ្ងៃទេ គឺមានតែសំណង់ពីថ្ម ម្លោះហើយស្នាដៃ សិល្បៈដែលអាចសិក្សាជាក់លាក់បានមានតែស្ថាបត្យកម្ម និងរូបបដិមាសាសនាខ្មែរតែប៉ុណ្ណោះ។

ស្ថាបត្យកម្មមានលក្ខណៈជានិមិត្តរូប ដែលគេអាចបំផុសឱ្យឃើញទស្សនៈខ្មែរ។ គេពុំសូវមានគំនិតកសាងដើម្បីទទួល បរិស័ទទេ តែគេខំធ្វើសំភារៈនិយកម្មលំនៅអាទិទេពតាមមនោគតិរបស់គេ គឺភ្នំពិសិដ្ឋនេះឯង។ ម្យ៉ាងទៀតខ្មែរបានបង្ហាញការប៉ិនប្រសប់របស់ខ្លួនខាងសំនង់រូបបដិមា ក្នុងលំហអាកាស។ គេតំរៀបឥដ្ឋ ឬថ្មភក់ហើយគេរំលេចរូបរាង និងក្បាច់ជាបដិមា។ ប្លង់ប្រាសាទហាក់ដូចជាដដែល។ គឺយកលំនាំតាមមនោគតិសាសនា ដែលជាហេតុនាំឱ្យអ្នកខ្លះថាជា "សិល្បៈពិសិដ្ឋ"។

មូលធាតុស្ថាបត្យកម្មខ្មែរគឺជាប្រាសាទរាងបួនជ្រុងស្មើ យកទិសទាំងបួនជាអ័ក្ស "Axe" ហើយបែរមុខទៅខាងកើត "លើកលែងតែ អង្គរវត្ត " នៅលើខឿនច្រើនជាន់។ កំពែងជុំវិញមានទ្វារនៅចំអ័ក្សទាំងបួន ដែលមិនសូវមានក្បាច់រំលេចរចនាប៉ុន្មានបំពេញទីតាំងប្រាសាទ។ ជាន់លើបំផុតជាឋានៈអាទិទេព បរិស័ទមិនអាចចូលបានទេគឺមានសិទ្ធិចូលត្រឹមទីលានដើម្បីបំពេញពិធីគោរពបូជាសាសនា

ជុំវិញប្រាសាទ និងទស្សនាក្បាច់រំលេចរចនា ពីខាងក្រៅដែលប្រកាសជោគជ័យរបស់អាទិទេព។

ចាប់ពីសតវត្សទី៧មក សំនង់ពីឈើត្រូវផ្អាក ហើយគេប្តូរគ្រឿងសំនង់គឺយកឥដ្ឋបូកបាយអរប្រកបដោយក្បាច់រចនា។ ចុងសតវត្សទី ៩ គេមិនប្រើប្រាស់ "Gres" ទេ លើកន្លែងមុខមាត់ខ្លះ គ្រឹះធ្វើពីថ្មបាយក្រៀម។ មានវិវត្តន៍មួយត្រង់ពីដើមមានត្រឹមប្រាង្គមួយ សម័យនេះគេសាងប្រាសាទដោយមានប្រាង្គច្រើនរៀបជាបីជួរ រឺប្រាង្គប្រាំមួយ នៅចំកណ្តាលបួនទៀតនៅជ្រុងទាំងបួនលើខឿន។ ខ្មែរបានបង្កើតបន្ថែមនូវប្រាសាទភ្នំ។ តាមតិចនិចជាប្រាសាទសង់លើខឿនច្រើនជាន់ជារាងសាជីមានជណ្តើរបួនត្រង់អ័ក្ស មានប្រាង្គមួយ រឺប្រាំ។

ប្រាសាទអង្គរវត្ត ជាប្រាសាទភ្នំល្អផ្តាច់ គឺជាលទ្ធិផលនៃវិវត្តន៍ដែលឡើងដល់កំពូល។ ប្រាសាទបាយ័នរក្សាគោលការណ៍ចាស់ គឺមានខឿនត្រួតត្រាគ្នាជាជាន់មានថែមប្រកបដោយក្បាច់ចម្លាក់ តែបានបង្កើតគោលការណ៍ថ្មី គឺធ្វើប្រាង្គ-មានមុខ បួនធំ។ ប្រាង្គ មុខមនុស្សបួន បែរទៅរកគ្រប់ទិស នេះជានវកកម្មរបស់ខ្មែរសម័យបាយ័ននេះឯង។ ប្រាសាទនាគព័ន្ធ មានស្រះជាដើមអាចទុកជាម៉ាកែតបង្រួមពីភ្នំហេមពាន្ត។ ពីមុខទ្វារនិមួយៗ របស់អង្គរធំ និងព្រះខាន់បង្ហាញពីការកួរសមុទ្រទឹកដោះ ដើម្បីរកទឹកអម្រឹត។ រួមសេចក្តីមកសិល្បៈខ្មែរបានចំរើនលូតលាស់យ៉ាងខ្លាំងក្នុងសម័យបុរាណ។ ពិតមែនតែសំនង់ឈើបានរលាយអស់តាមកំលាំងធម្មជាតិក៏ដោយ ក៏នៅតែមានសំនង់ថ្មជាច្រើនគួរយកមកបញ្ជាក់បាន។ ប្រាសាទបាក់បែកអស់ជាច្រើន អាចធ្វើឱ្យមានការពិបាកដល់អ្នកសិក្សាមែនហើយ តែសំនល់សំនង់មកនេះបានផ្តល់ភស្តុតាងច្បាស់ពីស្ថាបត្យកម្ម និងក្បាច់ចម្លាក់ដ៏ល្អរបស់ប្រាសាទ។ ម្យ៉ាងទៀតសំនង់សុទ្ធតែជានិមិត្តរូបបកស្រាយគំនិត សាសនាជាហេតុនាំឱ្យគេហៅថា សិល្បៈសាសនា។ តាមពិតគំនិតសាសនាឥណ្ឌា ត្រូវខ្មែរស្រាយចេញជារូបពិតហើយមានប្រយោជន៍ថែមទៀតដើម្បីពង្រីកសេដ្ឋកិច្ច។

ប្រធានទី ១៨

# វិវត្តន៍ស្ថាបត្យកម្ម

## ក. វិវត្តន៍សំភារៈសំណង់

- សំបូរ
- ព្រៃក្មេង

១.រចនាបថ - កំពង់ព្រះ

- គូលេន
- ប្រាសាទធ្វើពីឥដ្ឋ
- គ្រឹះនិងកំពែងខាងក្រៅធ្វើពីថ្មបាយក្រៀម
- សរសរពេជ្រ ផ្តែរ ច្រើនធ្វើពីថ្មភក់ "Gres"

២. រចនាបថ ព្រះគោ .

-ប្រាសាទធ្វើពីឥដ្ឋតែមានសំណាក ប្រើថ្មភក់ "ប្រាសាបាគង"

៣. រចនាបថ បាខែង

- ប្រាសាទធ្វើពីថ្មភក់ទាំអស់

៤. រចនាបថ កោះកេរ

- ប្រាសាទធ្វើពីថ្មភក់

៥. រចនាបថ បន្ទាយស្រី

- មានការត្រឡប់ទៅប្រើឥដ្ឋវិញ

៦. រចនាបថ ឃ្លាំង

- ឈប់ប្រើឥដ្ឋត្រឡប់មកប្រើថ្មភក់ទាំងអស់វិញ

បាពួន

៧. រចនាបថ អង្គរវត្ត

-ប្រើថ្មភក់

៨. រចនាបថ បាយ័ន

-ច្របូកច្របល់ កន្លែងខ្លះធ្វើពីបាយក្រៀម ខ្លះធ្វើពីឥដ្ឋ ខ្លះធ្វើពីថ្មភក់

## ៩. វិវត្តន៍ប្លង់ប្រាសាទ

- សំបូរ

១. រចនាបថ -ព្រៃក្មេង

- កំពង់ព្រះ

ប្រាសាទតូចៗសង់រកេតរកូតគ្មានរបៀបរៀបរយ ដាច់ៗគ្នា

២. រចនាបថ គូលែន

ប្រាសាទតូចៗ ដាច់ៗពីគ្នាតែច្រើនសង់លើភ្នំ។

៣. រចនាបថព្រះគោ

បានបង្កើតប្រាសាទភ្នំជាលើកដំបូងគឺប្រាសាទបាគង។ ប្រាសាទភ្នំជាអ្វី?

ប្រាសាទភ្នំ ជាតំនាងភ្នំព្រះសុមេរុ ដែលជាលំនៅអាទិទេព។ លទ្ធិទេវរាជ ជាពិធីមួយសំរាប់អភិសេកស្តេចឱ្យមានឋានៈជាទេវរាជ គឺស្តេចអាទិទេពតែម្តង ពុំមែនគ្រាន់តែជាតំនាងអាទិទេពទេ។ ពិធីនេះដំបូងឡើងព្រះបាទជ័យវរ្ម័នទី ២ រៀបចំធ្វើនៅលើភ្នំគូលែន។ ដល់ក្រោយគេមានគំនិតសង់ប្រាសាទលើខឿនជាជាន់ៗ ខ្ពស់ឡើងមានរាងសាជី" ដូចភ្នំ" ដើម្បីតម្កល់លិង្គទេវរាជ ប្រាសាទបែបនេះ គេហៅថាប្រាសាទភ្នំ។

៤. រចនាបថ បាខែង

ប្លង់ប្រាសាទសង់ត្រឹមត្រូវតាមក្បួនខ្នាតក្នុងទស្សនៈសាសនាព្រាហ្មណ៍ ដោយតំរូវប្រាសាទនេះ ជាភ្នំព្រះសុមេរុ។

៥. រចនាបថ កោះកេរ

ប្រាសាទភ្នំវិវត្តន៍បន្តទៅទៀត

៦. រចនាបថ បន្ទាយស្រី

កំនើតថ្មី គឺមានបង្កើតថែវ " បន្ទប់វែងនៅជាន់ទី ១ និងទី ២ "

៧. រចនាបថ ឃ្លាំង

ថែវវិវត្តន៍បន្តទៅទៀតៈ

រចនាបថ បន្ទាយស្រីចាប់ផ្តើមធ្វើថែវគ្មានដំបូល ដល់រចនាបថ ឃ្លាំងចេញជាថែវមែនទែនមានដំបូល

៨. រចនាបថ បាពួន

លើសពីឃ្លាំងត្រង់ថែវ ពីរជាន់មានដំបូលហើយថែវនីមួយៗមានគោបុរៈគ្រប់ទិស។

៩. រចនាបថ អង្គរ

ថែវមានដល់ទៅបីជាន់ យកថែវធ្វើជាជាន់ថ្នាក់តែម្តង

១០. រចនាបថ បាយ័ន

គេឈប់សង់ប្រាសាទភ្នំ ហើយត្រឡប់មកសង់ប្រាសាទផ្ទាល់វិញព្រោះព្រះបាទជ័យវរ្ម័នទី ៧ បានប្តូរលទ្ធិទេវរាជ ដោយយក លទ្ធិពុទ្ធរាជ មកជំនួសវិញ។

ប្រធានទី ១៩

## ភ្លេង និងរបាំប្រជាប្រិយខ្មែរ

ក្នុងវិស័យសិល្បៈ គេស្គាល់ខ្មែរតាមរយៈប្រាសាទអង្គរវត្ត។ វិស័យមួយទៀតគឺ របាំ និងភ្លេងបុរាណក៏មានសារៈសំខាន់ ណាស់ដែរ។ តើខ្មែរមានភ្លេង និងរបាំអ្វីខ្លះ?

ប្រវត្តិភ្លេងខ្មែរបានបង្ហាញថា ភ្លេងនេះមានកំនើតតំនាលគ្នានឹងកំនើតអរិយធម៌ខ្មែរ ដែលស្ថិតនៅលើមូលធម៌ខ្មែរ-មន រួមជាមួយនិងឥទ្ធិពលឥណ្ឌា។ ការបង្ហាញឧបករណ៍ភ្លេងមានចំនាស់ជាងគេ គឺចំលាក់សតវត្សទី ៦ ទី ៧។

គេច្រើនយកវង្សភ្លេងនោះទៅប្រគុំកំដរអ្នករាំ ឬ មួយយកទៅនាំមុខក្បួនដង្ហែរអ្វីមួយ។ អ្នកភ្លេងមានលក្ខន្តិកៈពិសេស របស់គេ ហើយគេច្រើនចាត់ទុកជាវត្ថុប្តូរ (Objet d'échanges) និងជាអំណោយសំណាក់ធំៗ។ របាំនិងភ្លេងជាប់ជាមួយគ្នាជានិច្ច។

សព្វថ្ងៃ ក្នុងពិធីបុណ្យទំនៀមទំលាប់ជាតិ គេច្រើននិយមប្រើភ្លេងបុរាណតាមប្រភេទបុណ្យ។ គេច្រើនចាត់ទុកភ្លេងជា ដង្វាយ សំរាប់ប្រគុំដើម្បីបន់ស្រន់អាទិទេព អង្គណាមួយ ដែលគេត្រូវការជំនួយអាទិទេពអង្គនោះ។

ភ្លេងខ្មែរបុរាណមានច្រើនប្រភេទ ដែលមានមុខងារផ្សេងៗគ្នា។ ភ្លេងពិណពាទ្យជាភ្លេងសំរាប់របាំរាជ និងជាភ្លេងសំរាប់វត្ត។ ឧបករណ៍ភ្លេងពិណពាទ្យមានរនាតពីរ គងធំពីរ សំភោមួយ ឆឹងមួយ និងស្រលៃមួយ។ ភ្លេងនេះតែងមានប្រគុំជាដរាបក្នុងពិធីបុណ្យ សាសនា។ គួរកត់សំគាល់ថា ភ្លេងពិណពាទ្យខ្មែរមាន

លក្ខណៈប្រហាក់ប្រហែលនិងភ្លេងផ្ទាម្យ៉ាង ដែលគ្រាន់តែមានខ្លុយជាឧបករណ៍មួយបន្ថែមពីលើភ្លេងពិណពាទ្យខ្មែរតែប៉ុណ្ណោះ។

ក្នុងខេត្តសៀមរាប និងតាកែវអ្នកស្រុកចូលចិត្តភ្លេងមួយបែបដែលមាន ទ្រអ៊ូ ទ្រឆេ ចាប៉ី ជាឧបករណ៍។ ជួនកាលមាន សាដៀវបន្ថែមមកទៀត។ សាដៀវជាឧបករណ៍មួយ មានចំនាស់ក្នុងចំនោមឧបករណ៍ចាស់ៗទាំងឡាយ មានអ្នក ច្រៀងម្នាក់ អ្នកវាយស្គរអារ៉ាក់ពីរនាក់ ដែលបន្លឺសំលេងឆ្លាស់គ្នា និងអ្នកច្រៀង។ ឧបករណ៍ទាំងនេះ រួមមកបានជាភ្លេងខ្មែរ "ភ្លេងការ"

ខ្មែរមានអំណោយពីធម្មជាតិ ពិសេសគឺប៉ិនខាងតែងកំនាព្យ ហើយគេតែងយកកំនាព្យនោះទៅច្រៀង។ អ្នកចំរៀងពីរនាក់ ច្រៀងឆ្លងឆ្លើយគ្នាជាកំនាព្យ ហើយពុំមែនចោទសួរគ្នាតែពីស្នេហាទេ គឺមានច្រៀងតំអូញពីទុក្ខព្រួយ និងពីធម្មជាតិផងថែមទៀត។

ភ្លេងសំខាន់មួយបែបទៀតគឺ ចំរៀងខ្វាក់ (Les chants K'aveugles) ចំរៀងនេះច្រើនប្រព្រឹត្តទៅនៅពេលបុណ្យ អ្នកចំរៀងខ្វាក់ អង្គុយក្រោមម្លប់ដើមឈើណាមួយ ឬនៅក្នុងវត្តច្រៀងពីដំនើរជីវិតរបស់ព្រះពុទ្ធ ឬរឿងព្រេងណាមួយដែលអ្នកស្រុក និយមរាប់អាន។

មានភ្លេងមួយប្រភេទទៀត ដែលមិនសូវនិយមនៅស្រុកស្រែទេ គឺភ្លេងមហោរីដែលមានរនាត និងឧបករណ៍មានខ្សែផ្សេងៗ ទៀតជាគ្រឿងសំរាប់រាំ ដូចជានៅពេលរៀបអាពាហ៍ពិពាហ៍ ពេលកាត់សក់កូនកំលោះ កូនក្រមុំ មានមនុស្សម្នាក់កាន់កន្ត្រៃរាំផង ច្រៀងផងតាមចង្វាក់ភ្លេង។ អាស្រ័យហេតុនេះហើយបានជាគេជួបប្រទះជាញឹកញាប់នៅក្នុងភូមិ ស្រុកនូវរបាំបុរាណជាច្រើន។

របាំប្រជាប្រិយច្រើនតែមានលក្ខណៈប្លែកៗ ទៅតាមស្រុក ភូមិនីមួយៗ។ របាំម្យ៉ាងដែលពុំសូវឃើញមានតែខ្មែរស្គាល់គ្រប់គ្នា គឺរបាំគោព្រៃ។ របាំនេះសំដែងដោយជនជាតិដើមមួយក្រុម នៅតាមភ្នំក្រវាញ។ សព្វថ្ងៃនេះ ពុំសូវឃើញមានសំដែងទេ។

មានរបាំពីរទៀត ដែលមានលក្ខណៈប្រជាប្រិយផង សាសនាផង គឺឆៃយ៉ាំ និងល្ខោនស្រមោល។

ឆៃយ៉ាំគេនិយមនៅពេលហែរបុណ្យ។ មុនពេលចូលវត្ត គេហែរជុំវិញវត្តបីជុំសិន ហើយមានឆៃយ៉ាំនៅខាងក្បាលក្បួនដង្ហែ។

ល្ខោនស្រមោលមិនសូវមានទេ ល្ខោននេះសំដែងដោយរូបធ្វើពីស្បែកកាត់ ដែលមានអ្នករាំជាអ្នកកាន់ ហើយគេមើលឃើញស្រមោលស្បែកចាំងលើវាំងននស។ គេច្រើនសំដែងរឿងរាមាយណៈ ដែលមានអ្នករៀបការដំនើររឿងម្នាក់ និងអ្នកចំរៀងច្រើនរូប ព្រមទាំងមានភ្លេងកំដរផង។

សេចក្តីអធិប្បាយរួចមកហើយនេះ បានបង្ហាញគំហើញទូទៅពីប្រភេទផ្សេងៗនៃភ្លេងនិងរបាំខ្មែរ។ នៅមានបេតិកភណ្ឌសិល្បៈ ប្រភេទនេះច្រើនទៀត ដូចជារបាំរាជទ្រព្យ ភ្លេងខ្មោច ល្ខោនបាសាក់ ។ល។ របាំនិងភ្លេងខ្មែរជាមែកធាងវប្បធម៌ខ្ពង់ខ្ពស់មួយ តែអ្នកបញ្ចឹមប្រទេសពុំសូវស្គាល់ទេ គឺច្រើនតែស្គាល់ភ្លេងឥណ្ឌា ចិន ឥណ្ឌូនេស៊ី។ តាមពិតទៅ ភ្លេងខ្មែរក្តី របាំក្តី សុទ្ធតែមានលក្ខណៈល្អប្រពៃ ប្រកបដោយសិល្បៈភាព សមជាជនជាតិមានអរិយធម៌ខ្ពង់ខ្ពស់។

**ប្រធានបទទី ២០**

## មុខងារសិល្បៈក្នុងជីវិតសង្គម

សិល្បៈជារស្មីតថភាពក្នុងញាណមនុស្ស សំដែងចេញតាមទំរង់រូប ។ សិល្បៈបញ្ចាំងលោកខាងក្រៅជុំវិញខ្លួន ដើម្បីឱ្យមនុស្ស ស្គាល់លោកនេះ គឺជាមធ្យោបាយស័ក្តិសិទ្ធក្នុងវិស័យអប់រំ នយោបាយ សីលធម៌ និងសិល្បរស់ ។

សភាពប្លែកៗនៃបាតុភូត និងព្រឹត្តិការណ៍តថភាពព្រមទាំងសភាពប្លែកៗនៃមធ្យោបាយបញ្ចាំងរស្មីចូលទៅក្នុងស្នាដៃសិល្បៈ តំរូវឱ្យទាំងសិល្បៈប្លែកៗក្នុងជីវភាពដូចជាអក្សរសិល្ប៍ ល្ខោន ភ្លេង កុន ស្ថាបត្យកម្ម ។ល។

សារៈជាខ្លឹមសិល្បៈគឺខុសពីស្យង់ ត្រង់សិល្បៈបញ្ចាំងតថភាពពុំមែនជាបញ្ញត្តិទេ តែជាទំរង់រូបបី ។ សិល្បៈករប្រើទិដ្ឋភាពផ្ទាល់ខ្លួន បាតុភូតធម្មជាតិរូបបី និងជីវភាពសង្គម ។ សិល្បៈលេចរូបរាងចេញជាមួយនិងសង្គមនុស្សតាមដំណើរការងារ ។ ដំបូងសិល្បៈ ជាប់នឹងការងារហើយសព្វថ្ងៃសិល្បៈនៅតែមានទំនាក់ទំនងនិងសកម្មភាពរូបបីនៅឡើយ ។ សិល្បៈនេះពិតជាជំនួយយ៉ាងស្មោះត្រង់ដល់មនុស្សក្នុងកិច្ចការ និងក្នុងជីវភាព ។ សិល្បៈបានជួយមនុស្សក្នុងការប្រយុទ្ធជាមួយធម្មជាតិ បានផ្តល់ឱ្យមនុស្សនូវការសប្បាយបានរុញឱ្យមនុស្សបំពេញកិច្ចការខ្លួន ។

ក្នុងដំណើរការងារសញ្ចេតនា និងតំរូវសិល្បរសបានលូតលាស់ក្នុងចិត្តមនុស្ស ។ កិច្ចការសំខាន់ គឺសិល្បៈបានរាវរកសោភ័ណ្ឌ ក្នុងតថភាពហើយបញ្ចាំងក្រោមទំរង់សិល្បរស និង អ្នកបំពេញចិត្ត ព្រមទាំងអប់រំតាមសិល្បវិធី ។

ក្នុងសង្គមវណ្ណៈ សិល្បៈមានលក្ខណៈវណ្ណៈនិយមបក្សពួកនិយម ។ គ្មានសិល្បៈសុទ្ធសាធ ឬសិល្បៈដើមសិល្បៈទេ ។ សិល្បៈជាអាវុធសំខាន់ក្នុងការប្រយុទ្ធ

វណ្ណៈ។ ហេតុដូចនេះហើយ វណ្ណៈនីមួយៗតែងតែប្រើសិល្បៈ ដើម្បីផ្សាយគំនិតនយោបាយ សីលធម៌មនោគមវិជ្ជារបស់ខ្លួន។

សិល្បៈជាមធ្យោបាយបំរើផ្ទៃគ្រឹះវណ្ណៈ ដូចជាសិល្បៈគហិបតីសព្វថ្ងៃបំរើកំលាំងចក្រពត្តិប្រតិកិរិយា។ សិល្បៈជាល្បិចសំរាប់បំបត់ហតករចេញពីការប្រយុទ្ធដើម្បីសេរីភាពប្រឆាំងនឹងគុណចរិយា ព្រមទាំងបំបាត់ប្រជារាស្ត្រដ៏ទៃចំពោះកំលាំងសន្តិភាព និង ចំរើន។ សិល្បៈគហបតី ការពារប្រយោជន៍គហបតី។

វណ្ណៈមួយបង្កើតសិល្បៈមួយផ្ទាល់តាមប្រយោជន៍ខ្លួន។ ប៉ុន្តែសិល្បៈជាច្រើនដែរ ដែលអាចរស់ជាសកល គឺមកពីសិល្បៈនោះបានបង្ហាញជំរៅលក្ខណៈមនុស្សដែលជាលក្ខណៈសកលផង គ្រប់សម័យកាលផង ហើយជាសិល្បៈដែលអាចឱ្យគេយល់ពីខ្លឹមសារសង្គមសម័យក្នុងកាលមួយបាន ដូចជាចំលាក់របស់សិល្បៈករក្រិចជាដើម។ ទាំងនេះជាភស្តុតាងបញ្ជាក់ឱ្យឃើញថា សិល្បៈដែលមិនចេះស្លាប់គឺសិល្បៈ ដែលបំរើមនុស្សឆ្ពោះទៅរកការរីកចំរើន។

៩០៣

ប្រធានទី ២១

## ខ្លឹមសីលធម៌មុខងារក្នុងជីវិតសង្គម

សីលធម៌ជាសំនុំច្បាប់ចរិយាមនុស្សក្នុងសង្គម ដែលបង្ហាញលក្ខណៈបញ្ញតិកម្ម តម្រូវនិងកំហុស កុសល និងអកុសល កិត្តិយស សេរីគ្មានកិត្តិយស ។

ច្បាប់សីលធម៌មិនមែនចែងក្នុងច្បាប់រដ្ឋ តែជាច្បាប់ទ្រទ្រង់ដោយកំលាំងមតិសាធារណៈដោយទំនៀមទំលាប់ និងការអប់រំ ដោយកំលាំងសំទុះចិត្តរបស់មនុស្ស ។ សីលធម៌កំណត់ អាកប្បកិរិយាមនុស្សចំពោះប្រជារាស្ត្រនៃប្រទេសដ៏ទៃចំពោះគ្រួសារ និងមនុស្សដ៏ទៃទៀត ។

សីលធម៌លេចចេញរូបរាងសង្គមមនុស្ស ។ សង្គមតែងតែមានតំរូវដែលសំដែងក្នុងច្បាប់សីលធម៌ចំពោះសមាជិកសង្គម ។ ច្បាប់សីលធម៌វិវត្តន៍ជាមួយគ្នានិវត្តន៍ជាមួយគ្នា ក្រោមឥទ្ធិពលទំរង់ទំរាយ រឺទំនាក់ទំនងផលិតកម្មក្នុងសង្គមជំនាន់ដើមច្បាប់មានសីលធម៌ មានលក្ខណៈដូចគ្នាទាំងអស់សំរាប់សមាជិកទាំងអស់ ។ កំនើតវណ្ណៈបានតំរូវសីលធម៌ទៅតាមប្រយោជន៍វណ្ណៈ ។

សីលធម៌បានជះឥទ្ធិពលទៅលើគ្រប់ទិដ្ឋភាព ជីវិតសង្គមព្រមទាំងមានទំនាក់ទំនងយ៉ាងជិតស្និត និងនយោបាយ ហើយជាឧបករណ៍ការពារគ្រឹះសេដ្ឋកិច្ចផងថែមទៀត ដូចនេះហើយបានជាគេតែងសង្កេតឃើញជោគជ័យនយោបាយសន្តិភាពរបស់រដ្ឋពឹងផ្អែកធំទៅលើការគាំទ្រតាមផ្លូវសីលធម៌ ពីសំណាក់ប្រជារាស្ត្រពីសំណាក់មនុស្សជាតិ ប្រដាប់ដោយគំនិតជឿនលឿន ។

សម័យសព្វថ្ងៃនេះ មានសីលធម៌ពីផ្ទុយគ្នាក្នុងសង្គម សីលធម៌បែបអ្នកមាន និងសីលធម៌បែបអ្នកក្រ ។ តើសីលធម៌ទាំង ពីរមានខ្លឹម និងមុខងារបំរើសង្គមប្លែកគ្នាយ៉ាងណាខ្លះ?

សីលធមិបែបអ្នកមានដែលជាគ្រឹះ នៃសង្គមមូលធននិយមសីលធមិសាសនាគឺមានគោលដៅជាមួយគ្នានេះឯង។ មុខងារសំខាន់គឺការពារសម្បត្តិឯកជន និងការចំរាញ់យកផលពីមនុស្សគ្នានេះឯងគឺបង្វែពលករចេញពីការប្រយុទ្ធរុញចូលក្នុងភាពរវើរវាយនៃជីវិតលើឋានសួគ៌ ដែលចាំទទួលមនុស្សក្រោយពេលស្លាប់ ដែលផ្តល់រង្វាន់ដល់ជនណាពូកែអត់ទ្រាំ និងចុះញ៉មនិងឥទ្ធិពលខ្លួន។

សីលធមិបែបអ្នកមាន ដាក់ផលប្រយោជន៏អត្តភាពខ្ពស់ជាងពិភពលោកទៅទៀត។ បុគ្គលនិងនិយមបន្ទាច់ជាជំរៅមូលភាពសីលធមិគហបតី។ មនុស្សជាចចកចំពោះមនុស្ស " ម្នាក់ៗសំខាន់សំរាប់ខ្លួនឯង អាទិទេពសំរាប់ទាំងអស់គ្នា " នេះជាទ្រឹស្តីសីលធមិគហបតី។ ចំនែកសីលធមិរបស់អ្នកក្រវិញដោយដោះស្រាយបញ្ហាក់ករណីកិច្ចបញ្ញាញាណ និងកិត្តិយសដោយយកប្រយោជន៏សង្គមជាគ្រឹះ។

មូលភាពសីលធមិបែបអ្នកក្រ ដាក់លក្ខខ័ណ្ឌឱ្យមនុស្សដូចជាការស្មោះត្រង់ការគួរសមអធ្យាស្រ័យចំពោះមនុស្សផងគ្នា ដើម្បីធ្វើឱ្យសង្គមមានរបៀបរៀបរយមានយុត្តិធមិឡើង។

៚

" លោក ប៉ា ស្កាល់ បាននិយាយថា: សីលវិជ្ជាពិតពេបជ្រាយឱ្យសីលវិជ្ជា " តើលោកយល់ដូចម្តេច?

## សេចក្តីអធិប្បាយ

រូបមន្តនេះសាំញ៉ាំបន្តិច តែលោក ប៉ា ស្កាល់ ប្រយ័ត្នប្រយែងក្នុងការកំនត់ន័យណាស់។ សីលវិជ្ជាពិតគឺ ការវិនិច្ឆ័យនិយាយ មួយបែបទៀត គឺសញ្ចេតនាគ្មាន "ធរណីមាត្រ"ពោលគឺពេបជ្រាយសីលវិជ្ជាបំពេញត្រឹមតម្រង់ច្បាប់។ លោក ប៉ា ស្កាល់ បានអះអាងក្នុងន័យដូចគ្នាថា " វោហាពិតពេបជ្រាយវោហា" រឺថាមួយបែបទៀត : វោហាកាយ ចេញពីកំលាំងលំដាប់ពេបជ្រាយតាមបញ្ញត្តិកម្មសីលធម៌នេះបានដែរ រឺទេ?

គំហើញដំបូង អាភៀនរបស់ ប៉ា ស្កាល់ គឺជាប្រតិមតិប្រកបដោយគ្រោះថ្នាក់ពីព្រោះបញ្ញត្តិច្បាប់ហាក់ដូចជា ខ្លឹមសីលធម៌តាមធម្មជាតិ រឺជាសច្ចភាពទៅហើយ។ សីលវិជ្ជា ជាប្រព័ន្ធតំរូវបង្ខំនិងហាមឃាត់ គឺគ្មានអ្វីក្រៅពីសំនុំក្បួនច្បាប់ធ្វើឱ្យមានរបៀប រៀបរយក្នុងភាពអានាធិបតេយ្យរបស់យើង។ ធម្មតាភាពរបស់ជនជាតិបុរាណប្រើ គឺជាបញ្ញត្តិ សាសនាផង បង្ខំ រឺតំរូវសីវិលផង។ ញាណទំនើបមានទំនោរញែកវិស័យពីនេះឱ្យដាច់ពីគ្នា។ ពលរដ្ឋគ្រីស្តនិយមខំប្រឹងគោរពបទបញ្ជាដូចអ្នកកាន់សាសនាគ្រីស្ត និងដូចពលរដ្ឋត្រង់ខំលំអោនតាមបទបញ្ញត្តិរបស់រដ្ឋ។

តែទោះបីក្នុងវិស័យមួយណាក៏ដោយ ក៏គេជួបជានិច្ចនឹងប្រព័ន្ធច្បាប់ដែលតំរែតំរង់ចរិយាមនុស្ស។ សីលវិជ្ជា ពុំមែនគ្រាន់តែជាសំនុំបញ្ញត្តិ ដែលធ្វើឱ្យមនុស្សអាចរស់នៅជាក្រុមបានរឺទេ? ពីព្រោះសីលវិជ្ជាមានលក្ខណៈសង្គមមុនអ្វីទាំងអស់

ដោយហេតុថា សីលវិជ្ជាគឺជាការសំដែងនៃ " ញាណសហគមន៍ " ដែលបញ្ចេញតាម សំនុំច្បាប់នេះឯង។ បើតាមលោក ឌូខេម (Durkheim) វិញ សីលវិជ្ជាតថភាពដូចគ្នានិងក្បួនតម្រាគួរសម ឬភាសានេះឯង។ ក្បួនច្បាប់នេះមានប្រភពក្នុងអារម្មណ៍កំរើករបស់បុគ្គលដូចគ្នានិងការប្រើភាសា ដើម្បីបញ្ជាក់គំនិតយោបល់ខ្លួន និងដើម្បីយល់គំនិតយោបល់គេ មនុស្សត្រូវការគោរពក្បួនច្បាប់ភាសាដែលចែងទុកក្នុង វេយ្យាករណ៍ ឬវចនានុក្រម រីឯក្នុងសីលវិជ្ជាវិញគេត្រូវសំរបសំរួលចរិយាគេ តាមច្បាប់ក្រៅខ្លួនរឺអំណាចដែលសង្គមលក្ខណៈគួសឱ្យ។

គេធ្លាប់កត់សំគាល់ថា គេចាត់ទុកជាវីរជននៃសីលជីវិតមនុស្សនូវជនណាហ៊ានចេញមុខប្រឆាំងជាសកម្មនឹងច្បាប់រួមរបស់សង្គម ហើយត្រង់នេះឯងដែលលោក ប៉ា ស្កាល់ ថាពេបជ្រាយសីលវិជ្ជា។ ប៉ុន្តែក្នុងករណីនេះញាណប៉ះប្រឆាំងទាត់ចោលច្បាប់ គឺដើម្បីលំអោនតាមច្បាប់មួយទៀតដោយលំងាប់។

ម្យ៉ាងទៀត បើយើងទាត់ចោលសីលវិជ្ជាដែលមានប្រភពចេញពីសង្គម ហើយស្របជាមួយលោក កាន្ត ត្រង់ស្វ័យភាពរបស់ញាណសីលច្បាប់ដែលស្ថិតក្នុងខ្លួនសុទ្ធសាធ និងគោរពដោយសេរី ក៏បញ្ជាក់តាមលំនាំច្បាប់ដែរ។ ចំពោះលោក កាន្ត ច្បាប់នេះ គឺជាសុភាសិតសកល សមហេតុសមផលដែលអាចលប់បំបាត់ការទទូចមិនទំនង និងទំនាស់របស់សភាវគតិ និងលំងាប់។

តែលោក កាន្ត យល់ថា ការគោរពច្បាប់វិចារណក្នុងសីលវិជ្ជា មិនទាន់គ្រប់គ្រាន់ទេ។ សីលភាពផ្សេងពីការសំរបនៃចរិយាទៅតាម " រូបធាតុ " នៃច្បាប់ពោលគឺគោរពតាមបញ្ញត្តិជាសំនេរ។ ចំពោះលោក កាន្ត សារៈសំខាន់គឺចេតនា។ ឧបមាថា ឈ្មួញពីរនាក់ដែលថ្លឹងទំនិញខ្លួន តាមទំរង់ត្រឹមត្រូវតែម្នាក់ថ្លឹងត្រឹមត្រូវដោយខ្លាចការត្រួតពិនិត្យ ម្នាក់ទៀតថ្លឹងត្រឹមត្រូវដោយគោរពតាមករណីយកិច្ច។ គឺឈ្មួញទី ២ ដែលមានចេតនា និងគោរពសីលច្បាប់នេះឯង ជាអ្នកប្រព្រឹត្តិដោយសីលភាព។ ដូចនេះលោកកាន្ត យល់ស្របថា ការគោរពបញ្ញត្តិសីលច្បាប់ពុំទាន់

គ្រប់គ្រាន់ទេ គឺត្រូវគោរពដោយស្មោះ ដោយចេតនា ក្នុងគំនិត និងសច្ចៈភាព។ ត្រង់នេះយើងសង្កេតឃើញថា ការចាំបាច់នៃ "ចេតនា" ចាប់ផ្ដើមអំនាចលំញែក និងជួនកាលជំលោះរវាងគំនិត សីលវិជ្ជា និងសំនេរច្បាប់។ តើសញ្ចេតនាដ៏ល្អប្រសើររបស់យើងគ្មានបំនងធ្វើឱ្យច្បាប់ក្នុងខ្លួនចាកចេញមកក្រៅទេឬ? នេះជាសំដីលោក កាន្ត។ គឺក្នុងករណី "ទំនាស់ករណីយកិច្ច" នេះហើយដែលយើងមើលឃើញសីលធម៌ពីរកំពុងពេបជ្រាយសីលធម៌។ តើយើងដាក់កំហុសអ្នកអត់ឃ្លាននៅទីក្រុងកាល់ គុតាដែលលួចគេដើម្បីចិញ្ចឹមកូនដែរឬទេ? ពិតមែនតែចរិយាបែបនេះប្រកបដោយគ្រោះ ក៏ប៉ុន្តែក្នុងកាលៈទេសៈខ្លះ ស្របនិងសីលធម៌ទៅវិញ។

ដោយហេតុថា សីលធម៌ពីរពេបជ្រាយសីលធម៌នេះហើយ ទើបសីលធម៌វឌ្ឍនៈភាពអាចបង្ហាញមុខក្នុងប្រវត្តិសាស្ត្រ។ ក្នុងរូបមន្តដ៏ល្បីល្បាញមួយរបស់លោក សាំង អូគូស្តាំង "ស្រឡាញ់និងធ្វើអ្វីដែលអ្នកចង់បាន"។ ក្នុងន័យនេះ លោក ប៊ែរ សុន ផ្ទុយសីលធម៌ពិតដែលចាប់កំណើតក្នុងញាណវីរៈជន ឬសន្តបុគ្គលទៅនឹងសីលធម៌ពិតអភិរក្សស្របតាមច្បាប់ប្រចាំថ្ងៃ។ គឺការពញាក់របស់វីរៈជននិងសន្តបុគ្គលនេះហើយ ដែលពេបជ្រាយនិងកាច់បំបាក់របងនៃសីលធម៌ដ៏ចង្អៀតបិទជិតត្រឹមវង្វង់ប្រយោជន៍ក្រុម ហើយទីបំផុតបានផ្សាយតំលៃថ្មី។ សីលវិជ្ជាបទ គឺជាច្បាប់ និងការបង្ខិតបង្ខំតាមទំលាប់។

សីលវិជ្ជាពិត គឺសីលសំទុះចេញពីភពភ្លឺស្វាង ចាប់ផ្ដើមការបង្កើតថ្មីគឺជាសំទុះដែលដាស់ទឹកចិត្តសប្បុរសនៅក្នុងការគំរាមកំហែង ឱ្យចាកចេញពីគំនាបច្បាប់។

សំទុះដែលជាចលនារបស់ចិត្តនេះអាចរំដោះសីលធម៌ពីលក្ខណៈមានពុតបាន។ គំនិតពិចារណាបែបនេះ មានការរិះគន់ក្នុងសម័យយើងសព្វថ្ងៃ។ ការពេបជ្រាយសីលធម៌នេះ យើងអាចធ្លាក់ចុះទៅក្រោមសីលវិជ្ជា ដែលយើងចង់នៅឱ្យខ្ពស់ជាង។ ពេបជ្រាយសីលវិជ្ជា ជួនកាលក៏គ្រាន់តែជាការបំពេញបំណងលំងាប់អត្តទត្ថភាព។

ដូចជាចោរនិយាយទិតៀនអំពីចំនែកទ្រព្យសម្បត្តិ ជនក្បត់រិះគន់នយោបាយស្រុកឯង ស្រ្តីផិតក្បត់ទិតៀនសីលធម៌គ្រួសារគហបតី។ តាមពិតគេមិនអាចទទួលបានព្រោះគេពុំអាចធ្វើឱ្យមាន " សកលភាព " បានទេ បើគិតតាមទ្រឹស្តីលោកកាន្ត។

សីលធម៌ពិតនៃចិត្តល្អ ចំពោះវីរៈជនតែងផ្តល់គ្រោះថ្នាក់សំរាប់មនុស្សធម្មតាដែលជាប់ក្នុងអន្ទាក់អត្តទត្ថភាព និងលំងាប់។ ច្បាប់គ្រាន់តែជាមធ្យោបាយពុំមែនជាគោលដៅទេ។ ដូចនេះហើយបានជាអ្នកមានសីលធម៌សុខចិត្តកុហកគេកាលណាមធ្យោបាយ ស្រោចស្រង់ជីវិតមនុស្ស មានតែមួយគត់ដូចជាអ្នកបើកបររថយន្ត សុខចិត្តមិនគោរពច្បាប់ចរាចរណ៍ ដើម្បីចៀសឱ្យផុតពីគ្រោះថ្នាក់ដែលអាចកើតឡើងដល់ថ្មើរជើងធ្វេសប្រហែសម្នាក់។ លោក ប៉ា ស្កាល់យល់ច្បាស់ជាងគេក្នុងការរិះគន់ សីលវិជ្ជានេះ ព្រោះការគោរពច្បាប់សីលធម៌ ទាំងងងឹតងងល់ទៅជាគ្មានន័យទៅវិញ កាលណាច្បាប់នេះអនុវត្តទៅហើយក៏នាំឱ្យខូចគោលដៅរបស់មនុស្ស។ ប៉ុន្តែមិនត្រូវយកការណ៍ពិសេសនេះជាច្បាប់ទូទៅសំរាប់ទាត់បាល់វិន័យនោះទេ។

៚

ប្រធានទី ២៣

## ខ្លឹមសារ និងមុខងារក្នុងការអភិវឌ្ឍន៍សង្គម

ស្យង់ជាសំនុំពុទ្ធិមនុស្ស ពីធម្មជាតិសង្គម និងពីគំនិត។ ស្យង់បញ្ចាំងពិភពលោក តាមបញ្ញត្តិ តាមប្រភេទ តាមច្បាប់ ដែលតំរូវភាពអាចផ្ទៀងផ្ទាត់បានក្នុងប្រវត្តិបត្តិ ស្យង់សហការតាងសំនុំស្យង់រូបី ដែលសិក្សាវិស័យជាអំណោយនៃលោកសំភារៈ។ ក្នុងស្យង់ផ្សេងៗទាំងនោះ គួរញែកស្យង់សង្គម ប្រវត្តិវិទ្យា សេដ្ឋកិច្ចនយោបាយ ទស្សនវិជ្ជា សិល្បៈវិទ្យា។ល។ ពីស្យង់ធម្មជាតិ (មេកានិច គណិតវិទ្យា រូបវិទ្យា គីមី ជីវវិទ្យា។ល។)

ស្យង់កើតពី ប្រតិបត្តិហើយរីកដុះដាលលើគ្រឹះនេះ។ តំរូវផលិតកម្មសំភារៈជាម៉ូទ័រសំខាន់នៃអភិវឌ្ឍន៍ស្យង់។ ក្នុងសង្គមជំនាន់ដើម ក្នុងរបកមធ្យោបាយសំរាប់រស់ មនុស្សបានប៉ះនឹងកំលាំងធម្មជាតិ ហើយបានទទួលពុទ្ធិជាលើកទី ១ តែជាពុទ្ធិសើរៗ។ ពុទ្ធិនេះមានលក្ខណៈជាពុទ្ធិពិសោធន៍ពុំទាន់មានលក្ខណៈជាស្យង់នៅឡើយទេ។ ស្យង់ដែលជាទំរង់ពិសេសនៃញាណសង្គមកើតឡើងនៅពេលក្រោយក្នុងសង្គមទាសករ គឺនៅពេលដែលកើតមានលំញែករវាងហត្ថកម្ម និងបញ្ញាកម្ម ហើយនៅជាមួយគ្នានោះមានជនពិសេសមួយក្រុមដែលគេចាត់ថាអ្នកប្រាជ្ញដែលគិតតែរាវរកស្យង់។

គឺមកពីវណ្ណៈទំនាស់ស្ថិតនៅលើគោលជំហរខុសគ្នា បញ្ហាសង្គមចោទឡើង និងគោលបំនងផ្សេងៗពីគ្នា។ តាមមធ្យោបាយ ប្រព័ន្ធគំនិតវណ្ណៈមួយតែងសំដែងវិនិច្ឆ័យការពារផលប្រយោជន៍ខិតខំធ្វើឱ្យសំរេចបំនង និងដោះស្រាយបញ្ហាដែលចោទមកចំខ្លួន។ ដូចនេះមនោគមវិជ្ជាគហបតីការពារប្រយោជន៍គហបតីខិតខំស្រាយបញ្ហាក់ឱ្យឃើញតំលៃសម្បត្តិឯកជន ដែលគេចាត់ទុកថាជាមនោគម

មូលជននិយមទៅវិញ ពួកអ្នកគ្មានធនធានបានបង្កើតមនោគមវិជ្ជារបស់ខ្លួនប្រឆាំងនឹងមូលធននិយម គឺមនោសង្គមនិយមនេះឯង ។

ដូចនេះក្នុងសង្គមមានវណ្ណៈ គេមិនអាចបង្រួមមនោគមឱ្យនៅតែមួយបានទេ ។ ជាចាំបាច់គឺត្រូវតែមានមនោគមអ្នកត្រូវគេត្រួត ម៉្លោះហើយបានជាមានការប្រយុទ្ធមនោគមយ៉ាងសាហាវក្នុងសង្គមមានវណ្ណៈ ពោលគឺទំនាស់ផ្ទៃក្នុងចោទឡើងជាដរាប ក្នុងសង្គមដែលមនុស្សមានជីវភាពលើសខ្វះគ្នាខ្លាំងពេកដូចជាខ្លះរកបាយស៊ីគ្មាន ខ្លះទៀតលុយចាយមិនអស់ នេះជាដើម ។

ដោយហេតុថាមនោគមវិជ្ជាមានលក្ខណៈវណ្ណៈជានិច្ច បែបនេះគេអាចចោទសួរថា តើមនោគមវិជ្ជាអាចមិនប្ដូររូបរាងតថភាពតាមប្រយោជន៍វណ្ណៈដែរឬទេ ?

ដរាបណាវណ្ណៈមួយមានមុខងារជឿនលឿនក្នុងប្រវត្តិសង្គម ដរាបណាផលប្រយោជន៍របស់ខ្លួនស្របនឹងទិសដៅអភិវឌ្ឍន៍តថភាពវត្ថុក្នុងវិស័យ ដរាបនោះមនោគមវិជ្ជារបស់វណ្ណៈមានតថភាព ប៉ុន្តែកាលណាវណ្ណៈនោះបានបញ្ចាក់មុខងារជឿនលឿន ហើយកាលណាផលប្រយោជន៍រត់ច្រាសទិសដៅប្រវត្តិសាស្ត្រពេលនោះមនោគមវិជ្ជាបាត់បង់ការពិតរួចចាប់ផ្តើមប្ដូរទង់តថភាពទៅតាមផលប្រយោជន៍វណ្ណៈ ។ ដូចជានៅពេលពួកគហបតីប្រយុទ្ធប្រឆាំងនិងពួកសក្ដិភូមិ មនោគមវិជ្ជារបស់គេឆ្លុះបញ្ចាំងពិភពតាមទំនាក់ទំនងពិត ។ តែនៅពេលគេឡើងកាន់អំនាចពេញលេញ ពេលដែលគេអស់មុខងារជឿនលឿនហើយក្លាយជាហ្វ្រាំងអភិវឌ្ឍន៍សង្គមមនោគមវិជ្ជាគហបតីបានបាត់សម្ថភាពឆ្លុះបញ្ចាំងនូវតថភាពជាក់ស្តែង ។

សេចក្តីអធិប្បាយមកនេះបានបង្ហាញឱ្យឃើញថា ភាវៈសង្គមវកម្មភាពផលិត...សកម្មមនសិការសង្គមតែងមនសិការមានស្វ័យភាពទាក់ទងក្នុងការអភិវឌ្ឍន៍របស់ខ្លួនផងដែរ ។ តើមនសិការសំដែងចេញយ៉ាងណា ?

ស្វ័យភាពទាក់ទងអភិវឌ្ឍន៍ មនសិការសង្គមស្ថិតនៅក្នុងកំលាំងដែលខ្លួនអាច រឺមួយទៅក្រោយ រឺមួយទៅមុខអភិវឌ្ឍន៍ភាវៈសង្គម រឺមួយមនសិការសង្គម

គោរពមូលភាពបន្ត ហើយមិននៅអកម្មចំពោះមុខភាវៈតែបញ្ចេញអំពើយ៉ាងសកម្ម លើភាវៈ ។

ការដែលមនសិការសង្គមតាមមិនទាន់ភាវៈសង្គម មកពីតាមទំនងច្បាប់ធម្មជាតិភាវៈផ្លាស់ប្តូរទំរង់មុន រួចបានមនសិការប្តូរជាបន្ត ។ ការយឺតយូរបណ្តាលមកពីគំនិតចាស់ផងដែរ។ វណ្ណៈកាន់អំនាចតែងប្រើគ្រប់មធ្យោបាយដែលខ្លួនមានដើម្បីផ្សំមនោគមខ្លួនអោយចាក់រឹសគល់គ្រប់សមាជិកសង្គម។ ឧបករណ៍ផ្សាយមនោគមដូចជាកាសែត កុន វិទ្យុ ទូរទស្សន៍ ។ល ។ ត្រូវពួកគហិបតីចក្រពត្តិយកមកប្រើ ដើម្បីបំពុលមនសិការពលករ និងបន្ថយគំនិតជឿនលឿន ។ អាស្រ័យដូចនេះ បានជាគេឃើញនៅពេលដែលរបបថ្មីមួយជំនួសរបបចាស់ មនសិការមនុស្សជាច្រើនស្ថិតនៅក្នុងមនោគមចាស់អស់យ៉ាងយូរ ។ សព្វថ្ងៃនេះ មនសិការមនុស្សអាចទៅមុខមុនអភិវឌ្ឍន៍ភាវៈក្នុងលក្ខខ័ណ្ឌខ្លះ។ ដោយបានធ្វើវិភាគច្បាប់សង្គមដោយមានកំណត់ និយមន័យទំនោរទូទៅនៃដំណើរប្រវត្តិសាស្ត្រ អ្នកប្រាជ្ញអាចប្រមើលមើល ហើយគ្រោងអនាគតសេចក្តីថា បង្កើតទ្រឹស្តីដែលទាយទុកពីអនាគត និងបង្ហាញមនុស្សនូវផ្លូវដែលអាចអោយទៅដល់ទិសដៅ ។

បាតុភូតមួយមានសារៈសំខាន់ក្នុងសម័យភាពទាក់ទងមនសិការសង្គមគឺភាពបន្តក្នុងអភិវឌ្ឍមនោគមវិជ្ជា ។ វណ្ណៈថ្មី បង្កើតមនោគមថ្មី ដោយបេះយកមនោគមចាស់យកមកប្រើ ពុំមែនទាត់ចោលទាំងស្រុងទេ ។

ភាពបន្តក្នុងអភិវឌ្ឍន៍គំនិតមានសារៈសំខាន់ក្នុងជីវិតសង្គម ។ បើមនុស្សបដិសេធសមិទ្ធិវប្បធម៌ចាស់ នោះគេត្រូវចាប់សារថ្មីទាំងអស់រកច្បាប់ឡើងវិញ បង្កើតម៉ាស៊ីននិងមេកានិចដែលគេស្គាល់តាំងពីយូរណាស់មកហើយ។ ដោយសារបាតុភូតបន្តនេះឯង ដែលគេមិនចំណាយពេលទៅរកអ្វីដែលគេរកឃើញរួចហើយនោះទេ។ ទាញយកលទ្ធផលដ៏ធំធេងរបស់បុព្វរស មនុស្សអាចបន្តកិច្ចការទាំងនោះ ពង្រីកសមិទ្ធិ និងលើកអោយបានខ្ពស់មួយកំរិតជាងមុន ។

សង្គមនីមួយៗមានអាកប្បកិរិយាផ្សេងៗគ្នា ចំពោះមុខមរកតមនោគមចាស់។ ពួកប្រតិកិយាចំលងយកគំនិតប្រតិកិយា មកប្រើលំអោនតាមលក្ខខ័ណ្ឌថ្មីនៃប្រវត្តិសាស្ត្រ និងទៅតាមផលប្រយោជន៍ផ្ទាល់របស់គេ ។ ដូចជាគំនិតវិទូចក្រពត្តិតែងប្រើប្រព័ន្ធគំនិត និងសាសនាដែលជាគំនិតអាចិកំបាំង ដើម្បីបំពេញតាមផ្លូវសីលធមិដល់ពលករ។

មនោគមស្មោះត្រង់ ត្រូវយកមរកតមនោគមចាស់មកស្រាយតាមន័យវិជ្ជមានដែលអាចបំរើវឌ្ឍនៈភាពមនុស្សជាតិបាន។

៙០៙

# ផ្នែកទី ៣
# សង្គមធម៌

## ប្រធានទី ២៤

## មនសិការសង្គមជារឿងភាវៈសង្គម

ទំនាក់ទំនងសំភារៈសេដ្ឋកិច្ចរវាងមនុស្សជាគ្រឹះនៃវិវត្តន៍សង្គម។ តែដើម្បីយល់វិវត្តន៍នេះ ការស្គាល់ត្រឹមតែកត្តាសេដ្ឋកិច្ច មិនគ្រប់គ្រាន់ទេ ព្រោះលើសពីសកម្មភាពបង្កើតផលមនុស្ស សង្គមមានជីវិតសីលធម៌ផងថែមទៀត។ មនុស្សរស់តាមខ្សែគំនិត នយោបាយនិងមូលភាពសីលធម៌ មានទ្រឹស្តីស្បង់ មានមតិលើសិល្បៈ។ គំនិតទាំងអស់សុទ្ធតែមានលក្ខណៈសង្គមតាមកំនើត និង តាមន័យហើយស្ថិតក្នុងវិស័យមនសិការសង្គម ។

មនសិការសង្គមមានសារៈសំខាន់ក្នុងការអភិវឌ្ឍន៍ប្រវត្តិសាស្ត្រ ហេតុដូចនេះហើយបានជាដើម្បីបានយល់ពីគំនិតសង្គមពេញលេញ គេត្រូវកំនត់ន័យអោយច្បាស់ជាមុនសិន ថាតើមនសិការសង្គមជាអ្វី? មានប្រភពមកពីណា? មានមុខងារយ៉ាងណាខ្លះក្នុងជីវិតសង្គម ?

មនសិការសង្គមជាសំនុំគំនិត ទ្រឹស្តីមតិដែលចាំងចេញពីភាវៈសង្គមមនុស្ស។ ដោយហេតុថា ភាវៈសង្គមមានទំរង់ប្លែកៗជាច្រើន និងសាំញ៉ាំទៀតផងមនសិការសង្គមក៏មានទំរង់លក្ខណៈដូចគ្នានេះដែរ ។

គំនិតនយោបាយនិងយុត្តិសាស្ត្រ សីលវិជ្ជា សិល្បៈ ស្បង់ ទស្សនៈវិជ្ជា សាសនាជាទំរង់មនសិការសង្គម ។ ទំរង់នេះមាន លក្ខណៈពិសេសរបស់ខ្លួន និងឆ្លុះបញ្ចាំងអោយឃើញទិដ្ឋភាពផ្សេងៗនៃភាវៈសង្គម។ ទំរង់នេះមានលក្ខណៈពិសេសរបស់ខ្លួននិង ឆ្លុះបញ្ចាំងអោយឃើញនូវទិដ្ឋភាពផ្សេងៗនៃភាវៈសង្គម ។

ទ្រឹស្តីមនោនិយមពុំមានអំនាច (capacite) ក្នុងដំណោះស្រាយបញ្ហានៃមុខងារគំនិតនៃមនសិការសង្គមក្នុងជីវិតសង្គមបានទេ ។ អ្នកមនោនិយមយល់ថា

គំនិតកំនត់ដំនើរអភិវឌ្ឍន៍សង្គម ។ យោបល់នេះពុំស្របតាមតថភាពឡើយ ។

តាមពិតមនសិការសង្គមរបស់មនុស្សគឺជាលទ្ធផលនៃភាវៈសង្គម ។ គឺជាភាវៈសង្គមក្នុងសកម្មភាពសំភារៈបង្កើតផល របស់មនុស្សឯនោះវិញទេ ដែលត្រូវរុករកប្រភពគំនិតនិងទ្រឹស្តី ។

សាវតាមនុស្សជាតិបង្ហាញថា កាលណាភាវៈរបស់មនុស្សប្តូរទំរង់មនសិការសង្គមក៏ប្តូរជាមួយគ្នាដែរ ។ គំនិតចាស់រលាយ ខ្យល់គំនិតថ្មីកើតឡើងភ្លាមស្របតាមលក្ខខ័ណ្ឌថ្មី តាមតំរូវការថ្មីរបស់សង្គម ។

ក្នុងសង្គមមានវណ្ណៈ មនសិការសង្គមក្រោមទំរង់បែបណាក៏ដោយក៏នៅតែមានលក្ខណៈវណ្ណៈ។ សំនុំគំនិតនយោបាយយុត្តិសាស្ត្រសីលធម៌ សិល្បៈរបស់វណ្ណៈណាមួយ បង្កបង្កើតមនោគមវិជ្ជាវណ្ណៈនោះ។ តើហេតុអ្វីបានជាវណ្ណៈមួយបង្កើតមនោគមវិជ្ជាមួយផ្ទាល់របស់ខ្លួន? គឺមកពីវណ្ណៈទំនាស់ស្ថិតនៅលើគោលជំហរខុសគ្នា បញ្ហាសង្គមចោទឡើង និងគោលបំណងផ្សេងពីគ្នា រឺតាមមធ្យោបាយប្រព័ន្ធគំនិត វណ្ណៈមួយតែងសំដែងវិនិច្ឆ័យការពារផលប្រយោជន៍ ខិតខំធ្វើអោយសំរេចបំនង និងដោះស្រាយបញ្ហាដែលចោទមកចំខ្លួន។ ដូចនេះមនោគមវិជ្ជាគហបតីការពារប្រយោជន៍គហបតី ខិតខំស្រាយបញ្ហាក់អោយឃើញតំលៃសម្បត្តិឯកជនដែលគេចាត់ទុកថាជាមនោគមមូលធននិយម។ ផ្ទុយទៅវិញពួកអ្នកគ្មានធននិយម បានបង្កើតមនោគមវិជ្ជារបស់ខ្លួនប្រឆាំងនឹងមនោគមមូលធននិយម គឺមនោគមសង្គមនិយមនេះឯង ។

ដូចនេះក្នុងសង្គមមានវណ្ណៈ គេមិនអាចបង្រួមមនោគមអោយនៅតែមួយបានទេ ។ ជាចាំបាច់ គឺត្រូវតែមានមនោគមអ្នកត្រូវគេត្រួតម៉្លោះហើយបានជាមានការប្រយុទ្ធមនោគមយ៉ាងសាហាវក្នុងសង្គមមានវណ្ណៈ ពោលគឺទំនាស់ផ្ទៃក្នុងចោទឡើងជាដរាបក្នុងសង្គម ដែលមនុស្សមានជីវភាពលើសខ្វះគ្នាខ្លាំងពេកដូចជាខ្លះរកបាយស៊ីគ្មាន ខ្លះទៀតលុយចាយមិនអស់នេះជាដើម។

ដោយហេតុថា មនោគមវិជ្ជាមានលក្ខណៈវណ្ណៈជានិច្ចបែបនេះគេអាច

ចោទសួរថា តើមនោគមវិជ្ជាមិនអាចប្តូររូបរាងតថភាពតាមប្រយោជន៍វណ្ណៈដែររឺទេ?

ដរាបណាវណ្ណៈមួយមានមុខងារជឿនលឿនក្នុងប្រវត្តិសង្គម ដរាបណាផលប្រយោជន៍របស់ខ្លួន ស្របនឹងទិសដៅអភិវឌ្ឍន៍តថភាពវត្ថុវិស័យ ដរាបនោះមនោគមវិជ្ជារបស់វណ្ណៈមានតថភាព ប៉ុន្តែកាលណាវណ្ណៈនោះបានបញ្ចប់មុខងារជឿនលឿន ហើយកាលណាផលប្រយោជន៍រត់ច្រាសទិសដៅប្រវត្តិសាស្ត្រពេលនោះមនោគមវិជ្ជាបាត់បង់ការពិតរួចចាប់ផ្តើមទំរង់តថភាពទៅតាមផលប្រយោជន៍វណ្ណៈ។ ដូចជានៅពេលពួកគហបតីប្រយុទ្ធប្រឆាំងនិងពួកសក្តិភូមិ មនោគមវិជ្ជារបស់គេឆ្លុះបញ្ចាំងពីភពតាមទំនាក់ទំនងពិត។ តែដល់ពេលគេឡើងហ្វ្រាំងអភិវឌ្ឍន៍សង្គម មនោគមវិជ្ជាគហបតីបានបាត់បង់សមភាពឆ្លុះបញ្ចាំងនូវតថភាពជាក់ស្តែង។

សេចក្តីអធិប្បាយមកនេះ បានបង្ហាញឱ្យឃើញថា ភាវៈសង្គមសកម្មភាពផលិតបានកំនត់មនសិការសង្គម។ តែមនសិការមានស្វ័យភាពទាក់ទងក្នុងការអភិវឌ្ឍន៍របស់ខ្លួនផងដែរ។ តើមនសិការសំដែងចេញយ៉ាងណា?

ស្វ័យភាពទាក់ទងអភិវឌ្ឍន៍ មនសិការសង្គមស្ថិតនៅក្នុងកំលាំងដែលខ្លួនអាច រឺមួយនៅក្រោយរឺមួយទៅមុខអភិវឌ្ឍន៍ភាវៈ សង្គមរឺមួយមនសិការសង្គមគោរពមូលភាពបន្ត ហើយមិននៅអកម្មចំពោះមុខភាវៈតែបញ្ចេញអំនាចយ៉ាងសកម្មលើភាវៈ។

ការដែលមនសិការសង្គមតាមមិនទាន់ភាវៈសង្គម មកពីតាមទំនងច្បាប់ធម្មជាតិជាភាវៈផ្លាស់ប្តូរទំរង់មុន រួចបានមនសិការ រកប្តូរជាបន្ត។ ការយឺតយូរនេះបណ្តាលមកពីគំនិតចាស់ផងដែរ។ វណ្ណៈកាន់អំនាចតែងប្រើគ្រប់មធ្យោបាយដែលខ្លួនមានដើម្បីផ្សាំមនោគមខ្លួន ឱ្យចាក់រឹសគល់ក្នុងគ្រប់សមាជិកសង្គម។

ឧបករណ៍ផ្សាយមនោគមដូចជា កាសែត កុន វិទ្យុ ទូរទស្សន៍ ។ល។ ត្រូវពួកគហបតីចក្រពត្តិយកមកប្រើ ដើម្បីបំពុលមនសិការពលករ និងបន្ថយគំនិតជឿនលឿន។ អាស្រ័យហេតុនេះបានជាគេឃើញ នៅពេលដែលរបបថ្មីមួយជំនួសរបបចាស់មនសិការមនុស្សជាច្រើនស្ថិតនៅក្នុងមនោគមចាស់អស់ពេលយ៉ាងយូរ។

សព្វថ្ងៃនេះ មនសិការមនុស្សអាចទៅមកមុនអភិវឌ្ឍន៍ភាវៈក្នុងលក្ខខ័ណ្ឌខ្លះ។ ដោយបានធ្វើវិភាគច្បាប់សង្គម ដោយបានកំនត់និយមន័យទំនោរទូទៅនៃដំណើរប្រវត្តិសាស្ត្រ អ្នកប្រាជ្ញអាចប្រមើមើល ហើយគ្រោងអនាគតសេចក្ដីថាបង្កើតទ្រឹស្ដីដែលទាយទុកពីអនាគត និងបង្ហាញមនុស្សនូវផ្លូវដែលអាចឱ្យទៅដល់ទិសដៅ ។

បាតុភូតមួយ មានសារៈសំខាន់ក្នុងស្វ័យភាពទាក់ទងមនសិការសង្គមគឺភាពបន្តក្នុងអភិវឌ្ឍន៍មនោគមវិជ្ជា។ វណ្ណៈថ្មីបង្កើត មនោគមថ្មីដោយបេះយកមនោគមចាស់យកមកប្រើពុំមែនទាត់ចោលទាំងស្រុងទេ។

ភាពបន្តក្នុងអភិវឌ្ឍន៍គំនិតមានសារៈសំខាន់ក្នុងជីវិតសង្គម។ បើមនុស្សបដិសេធសមិទ្ធិវប្បធម៌ចាស់នោះ គេត្រូវចាប់សារជាថ្មីទាំងអស់រកច្បាប់ឡើងវិញបង្កើតម៉ាស៊ីននិងមេកានិច ដែលគេស្គាល់តាំងពីយូរណាស់មកហើយ។ ដោយសារបាតុភូតបន្តនោះឯង ដែលគេមិនចំនាយពេលទៅរកអ្វីដែលគេរកឃើញរួចហើយនោះទេ។ ទាញយកលទ្ធផលដ៏ធំធេងរបស់បុព្វបុរស មនុស្សអាចបន្តកិច្ចការទាំងនោះពង្រីកសមិទ្ធិ និងលើកឱ្យបានខ្ពស់មួយកំរិតជាងមុន។

សង្គមនិមួយៗមានអាកប្បកិរិយាផ្សេងៗគ្នា ចំពោះមុខមរតកមនោគមចាស់។ ពួកប្រតិកិរិយាចំលងយកគំនិតប្រតិកិរិយាមកប្រើលំអោនតាមលក្ខខ័ណ្ឌថ្មីនៃប្រវត្តិសាស្ត្រ និងទៅតាមផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ។ ដូចជាគំនិតវិទូចក្រពត្តិតែងប្រើប្រព័ន្ធគំនិត និងសាសនា ដែលជាគំនិតអាថិកំបាំងដើម្បីបំពេរតាមផ្លូវសីលធម៌ដល់ពលករ។ មនោគមស្មោះត្រង់ត្រូវយកមរតកមនោគមចាស់មកស្រាយតាមន័យវិជ្ជមាន ដែលអាចបំរើវឌ្ឍនៈភាពមនុស្សជាតិបាន។

**ប្រធានទី ២៥**

# នយោបាយ និងសេដ្ឋកិច្ច

ទំនាក់ទំនងនយោបាយ គឺទំនាក់ទំនងរវាងវណ្ណៈមនុស្ស ការប្រយុទ្ធរបស់វណ្ណៈដើម្បីដណ្តើមយកអំណាច និងដើម្បីត្រួតត្រា សង្គមមនុស្ស។ ម្យ៉ាងទៀត ទំនាក់ទំនងរវាងរដ្ឋនិងជាតិក៏នៅក្នុងនយោបាយដែរ។ នយោបាយមានកំនើតជាមួយគ្នានិងកំនើតវណ្ណៈមនុស្ស និងការប្រយុទ្ធ រវាងវណ្ណៈ និងរដ្ឋ។ នយោបាយសំដែងក្នុងសកម្មភាពរដ្ឋ និងគ្រោងទិសដៅនៃសកម្មភាពនេះ។

នយោបាយកើតឡើងដោយរចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គម ហើយជះឥទ្ធិពលខ្លួនទៅលើសេដ្ឋកិច្ចវិញយ៉ាងសំបើម ព្រមទាំងទៅលើសំណើរអភិវឌ្ឍន៍សង្គមទាំងមូល។ អភិវឌ្ឍន៍សេដ្ឋកិច្ចរៀបចំបំលែងរបៀបរបបសង្គម តែបំលែងនេះជាលទ្ធផលនៃសកម្មភាពគំនិតរបស់ប្រជារាស្ត្រដែលគូសទិសដៅនយោបាយ។

គំនិតនយោបាយជាប់និងនយោបាយ។ ប្រសិនបើនយោបាយជាទំនាក់ទំនងរវាងវណ្ណៈមនុស្ស រវាងជាតិគំនិតនយោបាយបង្ហាញនិងប្រមូលភស្តុតាងទំនាក់ទំនងនេះ។

គំនិតនយោបាយជាបញ្ញត្តិកម្ម ដែលវណ្ណៈមួយបានមកពីការប្រយុទ្ធ និងបដិវត្តន៍ទំនាក់ទំនងរវាងជាតិ និងរដ្ឋលទ្ធិសង្គម និង នយោបាយបញ្ហាសង្គ្រាម និងសន្តិភាព។ បញ្ញត្តិកម្មនេះសំដែងក្នុងប្រយុទ្ធផ្ទាល់ នៃវណ្ណៈក្នុងសកម្មភាពរបស់រដ្ឋនៃគណបក្ស និង ស្ថាប័នដទៃទៀត ព្រមទាំងអង្គការនយោបាយ។

គំនិតនយោបាយរកឃើញសំនួរខ្លួនក្នុងបង្គុំរដ្ឋក្នុងកម្មវិធី និងសេចក្តីថ្លែងការណ៍គណបក្ស និងអង្គការនយោបាយដទៃទៀត ក្នុងកិច្ចការជាទ្រឹស្តី ពិសេស និងឯកសារផ្សេងៗ។

ក្នុងសង្គមមានវណ្ណៈ ទំនាស់លក្ខណៈគំនិតនយោបាយលំអោនតាមប្រយោជន៍វណ្ណៈ ។ វណ្ណៈគហបតីខិតខំពង្រឹងជំហរត្រួតត្រារបស់ខ្លួនតាមមធ្យោបាយគំនិតរបស់ពួកគហបតី ។ វណ្ណៈដែលគេត្រូវចំរាញ់យកផលលើខ្លួនខំពន្យល់ក្នុងគំនិតនយោបាយឱ្យឃើញថា មានការចាំបាច់មួយគឺត្រូវរំលំលទ្ធិជិះជាន់និងបង្កើតជាសង្គមថ្មីគ្មានការជិះជាន់ ។ មនោគមវិជ្ជាពួកនេះ គឺមនោគមវិជ្ជាបដិវត្តន៍ មនោគមវិជ្ជា ដែលមានទំនោរទាត់ចោលអ្វីដែលចាស់ និងបង្កើតអ្វីជាថ្មី ។

មនោគមនយោបាយផ្ទុយគ្នាពីរកំពុងឈរមុខតទល់គ្នាសព្វថ្ងៃនេះដែរ មនោគមគហបតី និងមនោគមកម្មករ ។

នយោបាយនិងគំនិតនយោបាយតែងនៅជិតមូលដ្ឋានសេដ្ឋកិច្ច ។ តាមសកម្មភាពរបស់រដ្ឋ របស់គណបក្ស និងអង្គការនយោបាយគំនិតនយោបាយធ្វើតាមមូលដ្ឋាននេះ ។ម្យ៉ាងទៀតនយោបាយនិងគំនិតនយោបាយមានឥទ្ធិពលយ៉ាងសកម្មទៅលើអភិវឌ្ឍន៍នៃទំរង់ញាណសង្គមដ៏ទៃទៀត ដូចជាច្បាប់សីលវិជ្ជា សិល្បៈសាសនា ទស្សនៈវិជ្ជា និង ស្បង់ ។

៩០៣

## ប្រធានទី ២៦

### បញ្ហានយោបាយ

បុគ្គលមិនគ្រាន់តែជាអ្នកសមាជិកគ្រួសារទេ តែជាសមាជិករបស់រដ្ឋ របស់ជាតិ របស់មាតុភូមិថែមទៀត ។ ស័ព្ទទាំងបីនេះពុំមានន័យដូចគ្នាទេ រដ្ឋសំគាល់"សហគមមានច្បាប់" គឺជាសំនុំបុគ្គល ស្ថិតនៅក្រោមបញ្ញត្តិច្បាប់អំនាចនយោបាយមួយ ។ វីថាមួយបែបទៀត គឺរដ្ឋជាអំនាចនយោបាយនេះឯង ។ រដ្ឋគឺជារដ្ឋាភិបាល និងសំនុំរចនាសម្ព័ន្ធ ដែលរដ្ឋសំដែងអំនាចខ្លួនក្នុងនោះ ។ ជាតិគឺជាសហគម ធម្មជាតិដែលសមាជិកម្នាក់ៗ ទទួលស្គាល់រៀងៗខ្លួនដូចជាខ្មែរកម្ពុជាក្រោម ទោះបីទឹកដីនេះស្ថិតនៅក្រោមអំនាចរដ្ឋយួនក៏ដោយ ក៏ជនជាតិខ្មែរនៅតែទទួលស្គាល់ថាខ្លួនជាខ្មែរ ។ កាលណាសមាជិកសហគមជាតិពុំទទួលស្គាល់តម្រូវការ ផ្សេងៗលើខ្លួនផ្ទាល់ដែលជាសេចក្តីសំរេចរបស់រដ្ឋាភិបាលខ្លួននោះគេចាត់ទុកថាជាតិពុំទទួលស្គាល់រដ្ឋ ។ ចលនាបដិវត្តន៍ ជាឧបករណ៏មួយសំដែងឱ្យឃើញនូវទំនាស់រវាងជាតិនិងរដ្ឋ ។ ចំនែកមាតុភូមិវិញ " គឺជាឈ្មោះសញ្ចេតនារបស់ជាតិ" គំនិតមាតុភូមិសំគាល់( សហគមវេទនា) (Communauté affective ) ។ តាមជំរៅមាតុភូមិជាជាតិនេះឯង ក្នុងងារជាវត្ថុដែលចិត្តនៅជាប់ជំពាក់នៅគោរពពីសំណាក់បុគ្គល ។ ក្នុងការគ្រប់គ្រងសង្គមរដ្ឋាភិបាលតែងប្រើល្បិចផ្សេងៗ ជាឧបាយដើម្បីឱ្យជាតិរស់ ជាតិបានចំរើនក្នុងចំនោមជាតិដ៏ទៃ ។ តើលទ្ធិនយោបាយដែលរដ្ឋធ្លាប់បានអនុវត្តមកហើយនោះ មានទំរង់និងមានបញ្ហាយ៉ាងណាខ្លះ?

ក្នុងដំណោះស្រាយបញ្ហានេះគេបានសំរបសំរួលដោយ ញែកលទ្ធិនយាបាយជា បី គឺលទ្ធិផ្តាច់ការ លទ្ធិអនាធិបតេយ្យ និង លទ្ធិប្រជាធិបតេយ្យ ។

លទ្ធិផ្តាច់ការជាប្រព័ន្ធដែលរដ្ឋមានអំនាចផ្តាច់មុខ ។ បុគ្គលគ្មានតំលៃខ្លួនឯងទេ គឺគ្រាន់តែជាអ្នកគោរព ។ អំណាចក្នុងលទ្ធិនេះពុំមែនជាអំនាចបានមកពី

រាស្ត្រទេ តែជាអំណាចបានមកពីប្រភពមួយខ្ពស់។ រីមួយអធិរាជ ជាអាទិទេពរបស់ខ្លួនឯង រីមួយអធិរាជ ជាតំណាងអាទិទេពនៅលើដី។ ដូចនេះ អំណាចពុំមែនបានមកពីរាស្ត្រទេ ម្ល៉ោះហើយអធិរាជគ្មានទំនួលខុសត្រូវចំពោះមុខរាស្ត្រឡើយ គឺទទួលខុសត្រូវចំពោះអាទិទេពទៅវិញ។

លទ្ធិអនាធិបតេយ្យមានទំរង់លក្ខណៈផ្ទុយពីលទ្ធិផ្តាច់ការ។ អ្នកអនាធិបតេយ្យមើលឃើញអកុសលក្នុងរដ្ឋហើយឃើញតំលៃ ដ៏ឧត្តុងឧត្តមក្នុងបុគ្គល។ រដ្ឋត្រូវតែដាក់ទោស ព្រោះរដ្ឋបំបាត់សេរីភាព ហើយគឺជាថ្នូរយ៉ាងធំមួយសំរាប់កប់ការសំដែងតវ៉ា នៃជីវិតបុគ្គល។ រដ្ឋមិនគ្រាន់តែជាយក្សអរូបីដែលបំផ្លាញសេរីភាពបុគ្គលរស់រូបីតែប៉ុណ្ណោះទេគឺជាឧបសគ្គធំមួយនៃការរីកលូតលាស់របស់តំលៃពិតជាសកលថែមទៀត ព្រោះរដ្ឋបានផ្តាច់សាមគ្គីភាពសកល (រដ្ឋមួយស្ថិតនៅប្រឈមមុខទល់និងរដ្ឋមួយ) ដែលជាកត្តាបង្កើតសង្គ្រាម និងទុក្ខវេទនាគ្រប់បែបយ៉ាង។ គួរកត់សំគាល់ថា អ្នកអនាធិបតេយ្យនិយមពុំមែនសុទ្ធតែជាអ្នកសីលធម៌និយមប្រឆាំងនិងសង្គមទេ តែផ្ទុយទៅវិញ ពួកនេះមានជំនឿថាបុគ្គលអាចរស់រីកលូតលាស់ តែក្នុងទំនាក់ទំនងជីវភាពសហគម។ រដ្ឋ និង អំនាចខ្លួនគ្រាន់តែជារូបភាពកំប្លែងស្ងួតនៃសង្គមធម្មជាតិ។ អ្នកអនាធិបតេយ្យនិយមទាមទារឱ្យមានបដិវត្តន៍រំលំរដ្ឋ ចៅក្រម ប៉ូលីស ទ័ព បោលហើយត្រូវបង្កើតសមាគម មនុស្សសេរីមកជំនួសវិញ។

ទ្រឹស្តីអនាធិបតេយ្យនិយមមិនត្រូវទាត់ចោលដោយគ្មានការពិនិត្យឱ្យបានត្រឹមត្រូវទេ។ ជាការពិតណាស់ទៅហើយ ដែលថារដ្ឋក្នុងកំឡុងប្រវត្តិសាស្ត្រនេះតែងមានទំរង់ផ្តាច់ការជិះជាន់ ដែលអាចបំផ្លាញសំរស់ ជីវិតមនុស្ស ព្រោះរដ្ឋតាំងអំនាចវណ្ណៈ អ្នកត្រួតក្នុងសង្គមមួយ ម្ល៉ោះហើយច្បាប់រដ្ឋគ្មានអ្វីក្រៅពីជាឧបករណ៍សំរាប់ពង្រឹងការចំរាញ់យកផលពីវណ្ណៈមួយដោយវណ្ណៈមួយនោះទេ។ ប៉ុន្តែគេមិនស្របតាមពួកអនាធិបតេយ្យនិយមដល់ចុងបំផុតនៃការយល់សប្តិរបស់គាត់ឡើយ។

យើងអាចទទួលស្គាល់ជាមួយអ្នកអនាធិបតេយ្យនិយមថា មនុស្សជាតំលៃតែមួយគត់ គឺតំលៃក្នុងខ្លួន តែត្រូវយល់បន្ថែមមកទៀតថា រដ្ឋដែលជាអបរិយកម្មសំដែងជាស្ថាប័នរដ្ឋបាល គឺជាមធ្យោបាយចាំបាច់ ដើម្បីធ្វើឱ្យបំនងបុគ្គលិកបានសំរេច។ យើងស្រលាញ់សេរីភាព ដូចនេះ យើងពិតជាត្រូវការកំលាំងមានអំនាច សំរាប់ការពារវាក្នុងពេលណាវាទទួលការឈ្លានពានពីអ្នកដ៏ទៃ ។ គំនិតនេះចែងយ៉ាងច្បាស់លាស់ក្នុង " កិច្ចការសង្គម " (Contratsocial) របស់លោក រូស្សូ (Rousseau) ដែលគេចាត់ទុកថាជាគោល គំនិតលទ្ធិប្រជាធិបតេយ្យ។ រដ្ឋក្នុងលទ្ធិប្រជាធិបតេយ្យគ្មានបំនងអ្វីក្រៅពីធ្វើអ្វីឱ្យសំរេចនិងធានាសេរីភាព សមភាពដែលបុគ្គលមានសិទ្ធិ និងទទួលតាមច្បាប់ធម្មជាតិ។

ក្នុងគំនិតប្រជាធិបតេយ្យរដ្ឋពុំមានជាអតិសេដ្ឋទេ : " អធិរាជជាផ្នែកពិសេសមួយរបស់រដ្ឋមិនអាចរកអ្វីប្រយោជន៍រួមទេ "។ ច្បាប់ពុំបានបំបាត់សេរីភាពទេ ព្រោះច្បាប់មានប្រភពពីឆន្ទៈរបស់បុគ្គលទាំងអស់ " ។

ប៉ុន្តែឆន្ទៈរបស់បុគ្គលអាចខ្វែងគ្នា តើឆន្ទៈនេះអាចសំដែងក្នុងច្បាប់រួមដូចមានកើត?

ត្រង់នេះគឺស្ថិតនៅលើកិច្ចសន្យា ព្រោះសហគមដែលយើងជាសមាជិកបានសំរេចថាត្រូវគោរពមតិភាគច្រើន។ ពិតមែនហើយ បុគ្គលម្នាក់អាចមានឆន្ទៈមួយផ្ទុយពីស្របឆន្ទៈទូទៅ តែឆន្ទៈរួមពុំមែនបុទ្ធនុភាពខាងក្រៅខ្លួនយើងទេ គឺថាគ្មានអ្វីក្រៅពីខ្លួនយើងទេ គឺថាគ្មានអ្វីក្រៅពីច្បាប់នៃវិចាណៈដែលសមាជិកក្រុមទទួលស្គាល់រួម។

តែគំនិតប្រជាធិបតេយ្យបានផ្សព្វផ្សាយ ហើយបានទទួលការរិះគន់ជាច្រើន។ សតវត្សទី ២០ ជាពេលមួយដែលលទ្ធិប្រជាធិបតេយ្យកំពុងមានវិបត្តិ។ វិបត្តិទាំងនេះមានលក្ខណៈទូទៅ និងជាវិបត្តិគំនិតផ្ទាល់ខ្លួន។

ការចំរើនលូតលាស់ផ្នែកឧស្សាហកម្ម និងតិចនិចក្នុងលោកទំនើបបង្កើត

បញ្ហាថ្មីៗ ដែលលទ្ធិប្រជាធិបតេយ្យហាក់ដូចជាខ្វះ សមត្ថភាពដោះស្រាយ ។

ក្នុងសម័យដែលវិធីស្សង់ផ្សាយពាសពេញទៅហើយនោះការជ្រើសរើសអ្នកកាន់អំនាចរដ្ឋ គឺពិតជាធ្វើឡើងតាមវិធីបោះឆ្នោតជាសកល សមត្ថភាពនយោបាយត្រូវដាក់រដ្ឋាភិបាលក្រោមអំនាចមតិសាធារណៈ គឺមតិមហាជនដែលមិនដឹងកិច្ចការរដ្ឋទាល់តែសោះ។ ប្រជាធិបតេយ្យគឺគ្មានអ្វីក្រៅពី " អំណាចផ្តាច់មុខរបស់ជនគ្មានសមត្ថភាពឡើយ " ។

ម្យ៉ាងទៀតសេរីភាពបុគ្គល ការប្រកួតប្រជែងសេដ្ឋកិច្ចភិបាលបង្កើតឱ្យមានការកេៀបសង្កត់ និងការចំរាញ់ពីពួកអ្នកខ្លាំង ទៅលើពួកអ្នកខ្សោយ ។

ដោយវិធីបោះឆ្នោត ជាផ្លូវបើកចំហឱ្យក្រុមអ្នកមានទៅកាន់អំនាច ព្រោះជាអ្នកមានមធ្យោបាយ គេក៏ប្តូរវិធីជ្រើសរើសអ្នកកាន់កាប់វាសនារដ្ឋ។ តាមពួកតិចនិចនិយមអំនាចត្រូវប្រគល់ឱ្យមនុស្សមួយក្រុម ដែលជាអ្នកមានសមត្ថភាពមានពុទ្ធិពីស្សង់នយោបាយ។ ចាប់ពីគ.ស ១៨១៩ លោក សាំង ស៊ីម៉ុង (Sant Simon) ប្រកាសថា " រដ្ឋត្រូវដឹកនាំដោយក្រុមអ្នកមានសមត្ថភាពជា អតិបរមា " ។ អ្នកនយោបាយពិតត្រូវជាវិស្វករ ដែលអាចធ្វើវិភាគស្ថានភាព ១ និងរកថ្នាំមកព្យាបាលវិញបាន។ លោក កុង (Auguste Causte) ក៏មានយោបល់ស្របតាមលោក សាំង ស៊ីម៉ុង (Sant Simon) ជាគ្រូរបស់គាត់ដែរ។ គាត់បានទិតៀនអាថិកំបាំងសេរីភាពរបស់ញាណដែលគាត់ចាត់ទុកថា " ជំងឺនៃលោកខាងលិច " ចេញពីលទ្ធិប្រូតេស្តង់ (Issue du protos tantisme) ។ ក្នុងសង្គមវិជ្ជមាន (Societé positivete) របស់លោកក្នុងអំនាចនិតិបញ្ញត្តិត្រូវស្ថិតក្នុង"អំនាចគំនិត " ដែលមានអ្នកប្រាជ្ញសមាជិក ហើយត្រូវមានអំនាចនិតិប្រតិបត្តិខ្លាំង ទទួលខុសត្រូវដោយអ្នកតិចនិចនៅក្រោមបង្គាប់ខ្លួនថែមទៀត។

ប៉ុន្តែគេនៅតែសង្កេតឃើញថា រដ្ឋាភិបាលអ្នកតិចនិចជាន់ខ្ពស់តាមការស្រមៃឃើញរបស់លោក ស៊ី ម៉ុង និងលោក តុង នេះជារដ្ឋាភិបាលរបស់ក្រុមអ្នក

មានដដែល សេចក្តីថារបបនេះគឺជាឧបករណ៍សំរាប់ត្រួតរបស់វណ្ណៈសេដ្ឋកិច្ចខ្ពស់ ។

ដូចនេះលទ្ធិប្រជាធិបតេយ្យមានគ្រោះថ្នាក់ ព្រោះលទ្ធិនេះគ្រាន់តែជាឧបករណ៍បោកប្រាស់របស់គហបតី សំរាប់កាន់កាប់ ឧត្តមភាពតែប៉ុណ្ណោះ ។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី សព្វថ្ងៃនេះ លទ្ធិប្រជាធិបតេយ្យ មានឧត្តមភាពក្នុងឆាកនយោបាយ ។ វិធីបោះឆ្នោតជាសកលជាវិធីមួយកំពង់ពេញនិយម ។ ដើម្បីនោះស្រាយមានប្រសិទ្ធិភាពជាក់ស្តែងក្នុងការអនុវត្តន៍លទ្ធិនេះ គឺការអប់រំប្រជារាស្ត្រក្នុងការអភិវឌ្ឍន៍ចំនេះវប្បធម៌ដែលបណ្តុះគំនិតរិះគិត (Lésprit critique) ។ មធ្យោបាយនេះអាចធ្វើឱ្យបុគ្គលក្លាយខ្លួនបន្តិចម្តងៗ ទៅជាអ្នកមានកិត្តិយស ក្នុងលទ្ធិប្រជាធិបតេយ្យបាន ។

៚៛

ប្រធានទី ២៧

## នយោបាយខ្មែរ

### គោលគំនិត

ដើម្បីសំរួលដល់ការសិក្សា ប្រវត្តិវិទូបានចែក ប្រវត្តិសាស្ត្រខ្មែរជាសម័យកាលដូចតទៅ :

១. សម័យបុរេប្រវត្តិ :
មុនគ្រិស្តសតវត្ស ( មូលធមិខ្មែរ-មន)

២. សម័យនគរភ្នំ :
ពីសតវត្សទី ១ ដល់ពាក់កណ្តាលសតវត្សទី ៦

៣. សម័យចេនឡា :
ពីពាក់កណ្តាលសតវត្សទី ៦ ទៅសតវត្សទី ៩

៤. សម័យអង្គរ :
ពីសតវត្សទី ៩ ដល់ពាក់កណ្តាលសតវត្សទី ១៥

៥. សម័យក្រោយអង្គរ :
ពីពាក់កណ្តាលពីសតវត្សទី ១៥មក

៦. សម័យបច្ចុប្បន្ន :

### នយោបាយខ្មែរ

**១. សម័យបុរេប្រវត្តិ :**

មុនគ.ស ខ្មែរមានរដ្ឋពេញលក្ខណៈរួចទៅហើយ ព្រោះពេលដែលហ៊ុន ទៀន មកដល់នៅស.វ ទី ១ គេឃើញខ្មែរ លើកកងទ័ពទៅទប់ទល់ដែលដឹកនាំដោយក្សត្រី លីវ យី ។ នេះជាភស្តុតាងមួយបញ្ជាក់ឱ្យឃើញថា ខ្មែរមានរដ្ឋមានស្តេច មានទ័ព មានល្បិចការពារស្រុកទេសទៅហើយ សេចក្តីថា ជារដ្ឋពេញ

លក្ខណៈពុំមែនដូចអ្នកខ្លះស្មានថា រដ្ឋហ្វូណន ទើបមានកំនើតពីស.វ ទី១ ដែលជារដ្ឋរបស់ឥណ្ឌានោះទេ។ ដូចនេះយើងអាចសន្និដ្ឋានថា ខ្មែរជារដ្ឋមួយមានស្ថាប័នចេះធ្វើនយោបាយ តាំងពីបុរេប្រវត្តិមក តែទំរង់នយោបាយយ៉ាងណា នោះពុំមានឯកសារច្បាស់លាស់ទេ។

**២. សម័យនគរភ្នំ :**

សម័យនេះ រដ្ឋខ្មែរមានទំរង់ទំរាយច្បាស់លាស់មានឯកសារជាក់លាក់ហើយ។ អ្នកប្រាជ្ញខ្លះយល់ថា រដ្ឋនគរភ្នំជារដ្ឋ ឥណ្ឌា។ គឺថានយោបាយសម័យនគរភ្នំជានយោបាយឥណ្ឌា។ បានជាគេថាបែបនេះព្រោះឯកសារ បញ្ជាក់ថាស្តេចនគរភ្នំច្រើនមានកំនើតពីឥណ្ឌា កិច្ចការរដ្ឋបាលបានចាត់ចែងតាមគំនិតអ្នកដឹកនាំ។

តែយើងពុំអាចយល់ស្របតាមមតិនេះបានទេព្រោះ ហ៊ុន ទៀន មកដល់យើងឃើញក្សត្រី លីវ យី លើកទ័ពទៅទប់ទល់ សេចក្តីថា ខ្មែរជារដ្ឋមួយមានអធិបតេយ្យភាពរួចទៅហើយ។ ដល់ពួកឥណ្ឌា ជាពួកអ្នកចំណូលថ្មី មកកាន់កិច្ចការធំៗក្នុងប្រទេសនេះ ទំរង់នយោបាយក៏ផ្លាស់ប្តូរ សំរបសំរួលផ្សំផ្សំធាតុថ្មី ជាមួយនិងធាតុចាស់។

សម័យនោះខ្មែរបានគ្រប់គ្រងប្រទេសតាមរបបប្រជាធិបតេយ្យផ្តាច់ការ។ បានជាយើងហ៊ានថាដូច្នេះ ព្រោះអំនាចមិនមែន បានមកពីរាស្ត្រទេ គឺបានមកពីអាទិទេព។ ស្តេចជាតំនាងអាទិទេពនៅលើដីយើងនេះ។

នយោបាយក្រៅប្រទេសវិញ ខ្មែរមានទំនាក់ទំនងផ្លូវទូត ជាមួយមហាអំនាច ចិន ឥណ្ឌា ចាម។ រដ្ឋនគរភ្នំ ជារដ្ឋចក្រពត្តិ ដែលមានរដ្ឋតូចៗចំណុះជាច្រើនដែលហៅថាសាមន្តរដ្ឋ ដូចជាចិន លាវ ជាដើម អំណាចកណ្តាលនៅលើនគរភ្នំនេះឯង។

**៣. សម័យចេនឡា :**

អំនាចកណ្តាលចុះខ្សោយ ម្លោះហើយមានការរើបំរាស់សាមន្តរដ្ឋ

ចេនឡា ដែលជាសាមន្តរដ្ឋភ្នំនោះ បានបះបោរ ហើយវាយលុក ទទ្រានយកនគរភ្នំបាន។

ចេនឡាមានការបែកបាក់គ្នាក្រោយពីពេលទទ្រានយកហ្វូណនបាន ហើយក៏ធ្លាក់ចូលក្នុងអំនាចរាជវង្សសៃលេន្ទ្រ។

**៤. សម័យអង្គរ :**

របបគ្រប់គ្រងមានឈ្មោះហៅថា រាជាធិបតេយ្យ សម្បូរណ៍ផ្តាច់ការ (Monarchie absolue) ។ អំនាចទាំងអស់ នៅលើស្តេច។ សម័យនគរភ្នំស្តេចជាតំនាងអាទិទេពសម័យអង្គរ ស្តេចជាអទិទេពតែម្តង ពុំមែនជាតំនាងទេ។ ម្ល៉ោះហើយអំនាច ស្តេចគ្មានព្រំដែន។

នយោបាយក្រៅប្រទេសវិញមានការរីកចំរើនដល់កំពូល។ ដំបូងបានរំដោះខ្លួនចេញផុតពីអំណាចជ្វា ក្រោយមកខ្មែរបាន អនុវត្តនយោបាយចក្រពត្តិ ពង្រីកអំនាចទៅលើប្រទេសជិតខាង ជួនកាលវាយយករដ្ឋទាំងនេះមកដាក់ជាចំនុះខ្លួន ជួនបញ្ជូនរាជវង្សឱ្យទៅសោយរាជ្យនៅរដ្ឋចំនុះនោះឯង។ បានធ្វើសង្គ្រាមគ្មានឈប់ឈរវាយ ចាម យួន មន។

ទំនាក់ទំនងផ្លូវទូតវិញ ខ្មែរបានដាក់ទូតជាមួយមហាអំនាច ជាពិសេសគឺចិន។

អំនាចចក្រពត្តិខ្មែរ សម័យអង្គរមានឈ្មោះល្បីល្បាញយ៉ាងខ្លាំង គឺសម័យនោះដែលអរិយធម៌ខ្មែរឡើងដល់កំពូល។

**៥. សម័យក្រោយអង្គរ :**

ពីពាក់កណ្តាលសតវត្សទី ១៨ រហូតដល់សតវត្សទី ២០ រាជាធិបតេយ្យខ្មែរ បានប្តូរទំរង់ទម្រាយខ្លះ គេហៅថា រាជាធិបតេយ្យជ្រើសរើស (Monarchie Elective) គឺមានក្រុមប្រឹក្សាសំរាប់រើសមនុស្សឱ្យសោយរាជ្យ។

នយោបាយក្នុងប្រទេសមានវិបត្តិជានិច្ច គឺមានចំបាំងក្នុងស្រុក ដើម្បី

ដណ្តើមអំណាចៈ

-សតវត្សទី ១៥ ចំបាំងសុរិយោទ័យ ស្រីរាជា ធម្មរាជា

-សតវត្សទី ១៦ ចំបាំងស្រីសុគន្ធបទ ស្តេចកន អង្គច័ន្ទ

-សតវត្សទី១៧ ជ័យធ្វើជារៀបការជាមួយកូនស្រីស្តេចយួន វិបត្តិផ្ទៃក្នុងកាន់តែមានច្រើនឡើងៗ។ អន្តរាគមន៍បរទេសមានញឹកញាប់ អំនាចខ្មែរចុះទន់ខ្សោយមែនទែន។

-សតវត្សទី ១៩ " ១៨៦៣ " ចាប់ពីគ.ស ១៨៦៣ មកខ្មែរស្ថិតនៅក្រោមអនានិគមបារាំងសេស។

-១៩៥៣ ទើបបានឯករាជ្យមកវិញ

នយោបាយក្រៅប្រទេសវិញ ខ្មែរពុំសូវមានមុខមាត់លើឆាកអន្តរជាតិទេ ព្រោះសម័យនេះមានវិបត្តិនយោបាយក្នុងប្រទេស ម្ល៉ោះហើយខ្មែរចុះខ្សោយ។ ឆ្លៀតឱកាសនោះសៀម យួន បានអនុវត្តនយោបាយចក្រពត្តិវាយទន្រ្ទានយកដីខ្មែរបន្តិចម្តងៗ ដូចសព្វថ្ងៃនេះ។

## ៦. សម័យបច្ចុប្បន្ន :

គឺសម័យសាធារណៈរដ្ឋ។ សាធារណៈរដ្ឋខ្មែរបានប្រកាសនៅថ្ងៃទី ៩ តុលា ១៩៧០។

របបរាជាធិបតេយ្យ បានយករចនាសម្ពន្ធសង្គមទំនើបកំពុងនិយមក្នុងលោកមកអនុវត្តក្នុងសង្គមខ្មែរ គឺរដ្ឋជាអ្នកធានាផ្តល់ឱ្យរាស្ត្រនូវសេរីភាព សមត្ថភាព កាតរភាព វឌ្ឍនភាព សុភមង្គល។ របបថ្មីបានយកលទ្ធិប្រជាធិបតេយ្យជាលទ្ធិរបស់រដ្ឋ ពោលគឺអំនាចចេញមកពីរាស្ត្រ។

សេចក្តីអធិប្បាយមកនេះ បានបង្ហាញឱ្យឃើញវិវត្តន៍នយោបាយខ្មែរដែលមានចលនាស្របនឹងវិវត្តន៍នយោបាយអន្តរជាតិ គឺចេញរបបផ្តាច់ការមករបបប្រជាធិបតេយ្យនេះឯង។ លទ្ធិប្រជាធិបតេយ្យអាចមាន ប្រសិទ្ធិភាពទៅបាន

លុះត្រាតែពលរដ្ឋមានការអប់រំ យល់ច្បាស់ពី សិទ្ធសេរីភាព ហើយនឹងមានគ្រោះថ្នាក់ទៅវិញកាលណាគេយកលទ្ធិនេះអនុវត្តន៍ក្នុងសង្គមដែលមនុស្សនៅល្ងង់ ។

៩១៩

## ប្រធានទី ២៨

### មុខងារមជ្ឈដ្ឋានភូមិសាស្ត្រក្នុងវិវត្តន៍សង្គម

ធាតុអាកាស និងដី ទន្លេ និងសមុទ្រ ស្ថានភាពទឹកដី ។ល ។ ពោលគឺធម្មជាតិ ជុំវិញសង្គមនេះឯង ដែលគេចាត់ទុកជាមជ្ឈដ្ឋាន ភូមិសាស្ត្រ ។

មជ្ឈដ្ឋានភូមិសាស្ត្រជាលក្ខខ័ណ្ឌចាំបាច់នៃអំពើបង្កើតផលរបស់មនុស្ស ។ អន្តរសកម្ម និងធម្មជាតិគ្មានការប្រយុទ្ធនឹងធម្មជាតិ ការងារ និងសកម្មភាព បង្កើតផលពុំអាចកើតឡើងបានទេ ។

មជ្ឈដ្ឋានភូមិសាស្ត្រឥទ្ធិពលពីរយ៉ាងគឺទៅលើសង្គម ។ លក្ខខ័ណ្ឌធម្មជាតិល្អៗ(សំបូរភោគទ្រព្យ ធនធានធម្មជាតិ )ជួយរុញល្បឿនដំណើរវិវត្តន៍សង្គម ។ ផ្ទុយទៅវិញ លក្ខខ័ណ្ឌធម្មជាតិមិនល្អផ្អាកល្បឿនវិវត្តន៍សង្គម ដូចជាការកង្វះរ៉ែបានទប់ដំណើរអភិវឌ្ឍន៍ឧស្សាហកម្មជាឧទាហរណ៍ ។

ដោយអភិវឌ្ឍន៍សង្គមទទួលឥទ្ធិពលយ៉ាងខ្លាំងពីមជ្ឈដ្ឋានភូមិសាស្ត្រ អ្នកតំនាងទំនោរភូមិសាស្ត្រ សង្គមវិទ្យាឱ្យតំលៃខ្លាំង ទៅលើមុខងារមជ្ឈដ្ឋាន ភូមិសាស្ត្រ ហើយចាត់ទុកថា អភិវឌ្ឍន៍សង្គមជាអនុគមន៍មជ្ឈដ្ឋានក្នុងសំនុំខ្លួនរឺជាធាតុផ្សេងៗ ដូចជាធាតុអាកាស ផ្លូវទឹក ។ល ។ ក្នុងវិស័យនេះ ចក្រពត្តិនិយម ទំនោរភូមិសាស្ត្រដែល ជាទ្រឹស្តីមិនសូវស្របនឹងស្បង់ប៉ុន្មានទេនោះក្លាយទៅជាទ្រឹស្តីសំរាប់វិនិច្ឆ័យនយោបាយឈ្លានពាន ។ ប្រទេសអាឡឺម៉ង់សម័យហ៊ីត្លែ (Allemagne Hitlcrienne) អ្នកតំនាងទំនោរភូមិសាស្ត្របង្កើតរូបមន្តទាមទារ "អាកាសជីវិត" (Espacé Vital) ដើម្បីអាឡឺម៉ង់ គឺជាតំណាងទ្រឹស្តី (A'rgumentation Thérique) នៃទំនោរ ហ្វាស៊ីស (Faxisme) ដែលដាក់ពិភពលោកឱ្យស្ថិតក្នុងសភាពស្លូឈាម ។

តាមទស្សនៈវិស័យស្បង់វិញ ទំនោរភូមិសាស្ត្រពុំទាន់មានលក្ខណៈត្រឹមត្រូវដាច់ណាត់ទេ ព្រោះពុំអាចឆ្លើយនឹងសំនួរថា : តើ វិវត្តន៍សង្គមគោរពប្រាក់បំនាច់កម្មករត្រូវស្ថិតនៅក្រោមនីយតករធម្មជាតិបែបនេះដែរ។ បើប្រាក់បំណាច់ទាបពេក គេឃើញ មានបេក្ខជនតិចបំផុតដែល រៀបចំសុំខ្លួនទៅបំពេញមុខរបរនោះ ដូចនេះត្រូវដំឡើងប្រាក់បំណាច់ ដល់ប្រាក់បំណាច់ឡើងខ្លាំងកម្មករសុំធ្វើការច្រើន។ ចំនួនច្រើននេះអាចធ្វើឱ្យមានការប្រកួតប្រជែងពេលនោះប្រាក់បំណាច់ អាចចុះមកវិញ។

មុខងាររបស់រដ្ឋមានតែមួយគត់ នៅក្នុងទ្រឹស្តីសេរីនិយមសេដ្ឋកិច្ចគឺការពារសម្បត្តិឯកជន។ គេគិតថាសម្បត្តិឯកជនជាការ ធានាភាពរុងរឿងចំពោះសមាជិកទាំងអស់នៃសមាគម។ ម្ចាស់ចំការ ម្ចាស់រោងចក្រ ម្ចាស់ជំនួញជាអ្នក គិតពីប្រយោជន៍ខ្លួន ទីមួយគឺខំធ្វើឱ្យសហគ្រាសរបស់ខ្លួនដើរ ហើយកាន់តែមានភាពប្រសើរឡើងទៀត ដោយស្ថាប័នមរកតអនុញ្ញាតិឱ្យផ្ទេរទ្រព្យសម្បត្តិទៅឱ្យកូនចៅ។ សម្បត្តិឯកជនពុំមែនគ្រាន់តែមានប្រយោជន៍សង្គមតែប៉ុណ្ណោះទេ តែមានភាពត្រឹមត្រូវតាមសីលវិជ្ជាទៅទៀត ព្រោះថា ជាការត្រឹមត្រូវណាស់ បើមនុស្សម្នាក់ៗអាចទទួលបានយកផ្លែផ្កា និងការសន្សំរបស់ខ្លួន សម្បត្តិគឺបន្លាយធម្មជាតិរបស់មនុស្ស (La propriété est un proiongement naturel de la personne)

សេដ្ឋកិច្ចសេរីនិយម ដែលទទួលជោគជ័យនៅសតវត្សទី ១៩ ហាក់ដូចជាទស្សនៈវិជ្ជានៃមូលធននិយមឧស្សាហកម្ម។ គឺជាមនុស្សពិសេសៗ ដែលមានរោងចក្រ មានចំការ មានសហគ្រាសជំនួញ។ ក្នុងប្រព័ន្ធសេដ្ឋកិច្ចនេះ គេញែកចេញជាវណ្ណៈសង្គមច្រើន។ វណ្ណៈគឺជាមុខងារ របស់យើងដែលបានបំពេញក្នុងប្រព័ន្ធសេដ្ឋកិច្ច។ វណ្ណៈបីសំខាន់ៗ គឺវណ្ណៈមូលធននិយម ដែលជាអ្នកផ្តល់មធ្យោបាយបង្កើតផលវណ្ណៈសិប្បករ (La classe des artisans) ដែលអាចមានមធ្យោបាយ

បង្កើតផលផ្សេងពីនេះ ហើយជាអ្នកផលិតខ្លួនឯងនិងវណ្ណៈកម្មករដែលមានត្រឹមតែកំលាំងសំរាប់ជួលឱ្យពួកមូលធនដើម្បីយកកំរៃចិញ្ចឹមជីវិត ។

ក្នុងវណ្ណៈទាំងបីនេះមានបញ្ហាចោទឡើងជានិច្ច ព្រោះអ្នកសុទិដ្ឋិសេរីនិយមមិនរក្សាពាក្យសន្យាខ្លួន ។ សង្គមឧស្សាហកម្មនៅប្រទេសអង់គ្លេសក្នុងស.វ ទី ១៩ អាច បញ្ជាក់ឱ្យយល់បាន ។ កម្មករធ្វើការមួយថ្ងៃ ១៥ម៉ោងដើម្បីប្រាក់បន្តិចបន្តួច ក្មេងអាយុ ៨ ឆ្នាំ ហើយជួនកាលក្មេងជាងនេះទៅទៀតចូលបំពេញកិច្ចការយ៉ាងសកម្មក្នុងសហគ្រាស ។ ការស្លាប់មានចំនួនច្រើនគួរអោយស្លុត ។ កម្មករមិនអាចសន្សំសម្បត្តិផ្ទាល់ខ្លួនបានឡើយ ចំនែកម្ចាស់មូលធនវិញអាចមិនធ្វើការបាន ។ សេរីភាពដែលពួកសេរីនិយមយកមកនិយាយនេះ ជាគំនិតរូបីសុទ្ធសាធ ។ ពិតមែនតែអ្នកជួលនិងអ្នកស៊ីឈ្នួលពិគ្រោះគ្នាដោយសេរីពីប្រាក់ឈ្នួល តែអ្នកស៊ីឈ្នួលដែលមានការគំរាមកំហែងពីការអត់ការធ្វើ ហើយគ្មានមធ្យោបាយរង់ចាំ ក៏បង្ខិតបង្ខំចិត្តទទួលយកប្រាក់ឈ្នួលដែលអ្នកជួលស្នើរមកឱ្យ ។

ទាំងនេះហើយដែលនាំឱ្យលោកម៉ាក់ (Marx) ចោទប្រកាន់មូលធនសេរីនិយម ។ លោកម៉ាក់ បានពិនិត្យតាមទស្សនៈវិស័យស្បង់ ។ គាត់ស្នើរឱ្យធ្វើវិភាគរចនាសម្ព័ន្ធមូលធនសេរីនិយម ។ លទ្ធផលនៃវិភាគបង្ហាញថា មូលធននិយមរំលាយខ្លួនឯងដោយសារទំនាស់ផ្ទៃក្នុង ។

គោលការណ៍ច្បងនៃមូលធននិយមគឺ : សភាពកម្មករត្រូវគិតថ្លៃដូចជាទំនិញ ។ តើទំនិញមានតំលៃយ៉ាងដូចម្ដេច? តំលៃ អាស្រ័យទៅលើបរិមាណកិច្ចការដែលបំពេញដើម្បីផលិត ។ សកម្មភាពកម្មករត្រូវគិតថ្លៃតាមតំលៃទំនិញ ។ សេចក្ដីថាគេផ្ដល់ឱ្យកម្មករនូវប្រាក់ល្មមជួសជុលកំលាំងឡើងវិញ ដើម្បីធ្វើការថ្ងៃស្អែក ។ ដើម្បីឱ្យកម្មករអាចធ្វើការបានត្រូវផ្ដល់ស្បៀងអាហារ សំលៀកបំពាក់ ។ ម្ចាស់សហគ្រាសចេញប្រាក់ថ្លៃកំលាំងក៏ដូចជាការចេញប្រាក់ទិញប្រេងដែរ ។ តាមមូលហេតុណាបាននៅឡើយទេ ។ ហេតុអ្វីបានជាប្រទេសពីរជិតខាងគ្នាដូចជា

ឆេកូស្លូវ៉ាគី (Tehécoslovaquie) និងអូទ្រីស (Autriche) ដែលលូតលាស់ក្នុងលក្ខខ័ណ្ឌភូមិសាស្ត្រប្រហាក់ប្រហែលគ្នាៈ មានរបៀបចំសង្គមមិនស្មើគ្នា ប្រទេសឆេកូស្លូវ៉ាគី របៀបចំតាមបែបសង្គមនិយម ឯប្រទេសអូទ្រីសវិញ របៀបចំតាមបែបមូលធននិយមទៅវិញ នេះជាភស្តុតាងបញ្ជាក់ឱ្យឃើញថា មជ្ឈដ្ឋានភូមិសាស្ត្រមិនអាចកំណត់អភិវឌ្ឍន៍សង្គមបានឡើយ។ រួមសេចក្តីមកមជ្ឈដ្ឋានភូមិសាស្ត្រពុំមែនជាមូលហេតុកំណត់អភិវឌ្ឍន៍សង្គមទេ ទុកណាជាលក្ខខ័ណ្ឌចាំបាច់នៃជីវិតសង្គមក៏ដោយ គឺគ្រាន់តែបង្កើតល្បឿន វិការលូតលាស់សង្គមតែប៉ុណ្ណោះ។

៚០៙

ប្រធានទី ២៩

## បញ្ហាសេដ្ឋកិច្ច និងសង្គមកិច្ច

បញ្ហាសេដ្ឋកិច្ចគឺជាចំណោទក្នុងការរៀបចំសេដ្ឋកិច្ចសង្គមក្នុងផលិតកម្ម ក្នុងចំនែកផល ក្នុងទ្រព្យសម្បត្តិ។ តើបញ្ហាទាំងនេះ ចោទឡើងយ៉ាងណាខ្លះ?

ចំពោះអ្នកសេរីនិយម ការពិបាកផ្នែកសេដ្ឋកិច្ច និងសង្គម មានប្រភពពីអន្តរាគមន៍រដ្ឋដែលចូលមកកំរិតតំលៃប្រាក់បំណាច់ និងបណ្តូរជំនួញ ។ គួរតែបណ្តោយអោយចលនាសេដ្ឋកិច្ចធម្មជាតិប្រព្រឹត្តទៅដោយសេរី សេដ្ឋកិច្ចមានទំនោររៀបចំខ្លួនឯង ដើម្បីកុសលចំពោះទាំងអស់គ្នា ។ អ្នកសុទិដ្ឋិនិយមសេរីមានជំនឿទៅលើភាពរុងរឿងសេដ្ឋកិច្ច ។

លោក Adam smith បានពិនិត្យពីតំលៃទំនិញ ។ តំលៃធម្មជាតិ ( Prix naturel ) នៃវត្ថុមួយគឺតំលៃដើមបូករួមនិងចំនេញ ។ តំលៃផ្សារ ( le prix du marcne ) នៃវត្ថុមួយលំអោនតាមច្បាប់ផ្តល់ និងការសុំ ( depena de la lot d'offre et de la demade ) បើផលណាមួយមិនសូវសំបូរ ការសុំមានចំនួនច្រើនជាងវត្ថុផ្តល់អោយ ហើយតំលៃផ្សារឡើងខ្ពស់ជាងតំលៃធម្មជាតិ ។ បើផលសំបូរគឺផ្ទុយពីនេះទៅវិញ តំលៃផ្សារចុះដល់ក្រោមតំលៃធម្មជាតិ ។ តំលៃខ្ពស់ធ្វើឱ្យអ្នកបង្កើតផលសប្បាយចិត្ត ចាប់អារម្មណ៍ខ្លាំងទៅលើផលខ្លួនខំបង្កើតអោយបានចំនួនច្រើន ។ ដល់ចំនួនសំបូរតំលៃចុះមកវិញ ។ តំលៃទាបពេកធ្វើឱ្យអ្នកផ្តល់ផលមិនសប្បាយចិត្ត ផលិតកម្មចុះថយ ហើយតំលៃផ្សារនឹងឡើងទៅវិញនៅពេលផលផ្តល់មកតិច ។ ដូចនេះតំលៃផ្សារទោទៅជិតតំលៃធម្មជាតិជានិច្ច ។ ច្បាប់ផ្តល់និងច្បាប់សុំ ( Loi de L' offre de la demande) សំរាប់ជានីយតករ ហើយចំនួនទំនិញនីមួយៗ ដែលដាក់លក់នៅផ្សារត្រូវស៊ីគ្នាទៅនឹងសេចក្តីត្រូវការ ។

កិច្ចការកម្មករជាទំនិញពិសេសដែលផលិតជាថ្មីនូវតំលៃ ហើយជាតំលៃខ្ពស់ជាងតំលៃទំនិញ តែទោះបីយ៉ាងណាក៏ដោយ ក៏ប្រព័ន្ធមូលធននិយមបង្កើតឱ្យមានទំនាស់ខានពុំបាន ។

ម្ចាស់សហគ្រាសប្រើគ្រប់មធ្យោបាយ ដើម្បីលក់ផលិតផលរបស់គេឱ្យបានថ្លៃខ្ពស់តាមអាច ហើយផ្តល់ប្រាក់ឈ្នួលតាមអាចកម្មករ ។ ដើម្បីឱ្យចំនេញបានច្រើន ។ ពេលនោះកម្មករពុំអាចរស់កើត សូម្បីតែវត្ថុដែលខ្លួនបង្កើតផ្ទាល់ដៃក៏ពុំអាចទិញយកមកប្រើបានឡើយ ។ ពេលនោះវត្ថុតាងលក់ពុំសូវដាច់ទេ ព្រោះអំនាចទិញត្រូវចុះ ម្ចាស់សហគ្រាសត្រូវបណ្តេញកម្មករមួយផ្នែកចោល ព្រោះពុំសូវមានកិច្ចការធ្វើ ដោយសារតែផលិតផលនៅតាំងស្ទេញ ។ អ្នកដែលត្រូវគេបណ្តេញកាន់តែខ្វះលុយសំរាប់ទិញទៀត ។ អំនាចទិញកាន់តែចុះវិបត្តិក៏កើតឡើងជាវិបត្តិសេដ្ឋកិច្ច និងវិបត្តិសង្គមកិច្ច ។

ឧបត្ថម្ភគំនិត គឺរកមធ្យោបាយធ្វើទំនិញមានអ្នកទិញជានិច្ចកាល ។ សំភារៈច្បាំងជាទំនិញពិសេស ដែលរដ្ឋត្រូវធានារ៉ាប់រងអំណាចទិញ ហើយមិនត្រូវលក់វិញទេ ។ ដូចនេះ សង្គ្រាមជាការចាំបាច់ដើម្បីបើកសារថ្មី ហើយកំហូចខាតក្នុងពេលសង្គ្រាមបង្កើតឱ្យមានតំរូវការផលិតផលក្រោយពេលសង្គ្រាម ។

អាស្រ័យហេតុនេះហើយបានជាលោក Jaurés និយាយថាលទ្ធិមូលធននិយមគេចមិនផុតពីសង្គ្រាម ។

ប្រធានទី ៣០

# សេដ្ឋកិច្ចខ្មែរ

## គោលគំនិត

សេដ្ឋកិច្ចស្ថិតនៅលើគ្រឹះសំខាន់ គឺ កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ។ គ្រឹះទាំងបីពុំមានល្បឿនស្មើគ្នាក្នុងគ្រប់ប្រទេស ។ ប្រទេសខ្លះទឹក ដី ធាតុអាកាសគាំទ្រឱ្យកសិកម្មមានឧត្តមភាពជាងគេ ប្រទេសខ្លះទៀតធនធានធម្មជាតិគាំទ្រឱ្យឧស្សាហកម្មរីកលូតលាស់ ។ ប្រទេសខ្លះទៀតជាប្រទេសពាណិជ្ជកម្ម ។ តើ ប្រទេសខ្មែរតាំងពីបុរេប្រវត្តិមកបានរៀបចំសេដ្ឋកិច្ចខ្លួនយ៉ាងណាខ្លះ?

## សម័យបុរេប្រវត្តិ

ប្រទេសខ្មែរដែលស្ថិតក្នុងមូលធមិអរិយធម៌ខ្មែរមន បានរៀបចំប្រទេសខ្លួនជារដ្ឋមួយពេញលក្ខណៈ ។ គ្រឹះសេដ្ឋកិច្ចក្នុងសម័យនោះ គឺកសិកម្ម ។ ពិតមែនតែពុំមានឯកសារច្បាស់លាស់បញ្ជាក់ពីប្រវត្តិសាស្ត្របុរេប្រវត្តិ ពោលគឺមុនគ្រឹះស្តសតវត្សក៏យើងហ៊ានសន្និដ្ឋាន បែបនេះដែរ ព្រោះអ្នកស្រាវជ្រាវ ប្រវត្តិសាស្ត្របានរកឃើញកណ្តៀវធ្វើពីថ្មរំលីង ក៏មានធ្វើពីឆ្អឹងសត្វ ក៏មានធ្វើពីលង្ហិន ក៏មាននៅត្រង់ស្ថានីយ៍សំរោងសែន អន្លង់ផ្តៅ និងម្លូព្រៃ ។ ឧបករណ៍ទាំងនេះបញ្ជាក់ឱ្យឃើញថាក្នុងវិស័យកសិកម្ម ដំណាំស្រូវមានឧត្តមភាពជាងគេ ។ គេដឹងថាអ្នកស្រុកមានតំបន់បញ្ចូលទឹកក្នុងស្រែ ចេះប្រើគោ ក្របី ចេះធ្វើប្រដាប់ធ្វើស្រែ ។ល ។

ក្រៅពីកសិកម្ម អ្នកស្រាវជ្រាវប្រវត្តិសាស្ត្របានឱ្យដឹងថាខ្មែរ ចេះស្លលោហៈធាតុ តែគេពុំដឹងថាវិស័យឧស្សាហកម្មមានការរីកចំរើនលូតលាស់ដល់ថ្នាក់ណាទេ ។ វិស័យពាណិជ្ជកម្មក៏មានការចំរើនណាស់ដែរ គេថាអ្នកស្រុកនេះជាអ្នកស្ទាត់ជំនាញខាងនាវាចរ ។

## សម័យបុរេអង្គរ

គ្រឹះសេដ្ឋកិច្ចសម័យនគរភ្នំគឺ កសិករ និងពាណិជ្ជកម្ម។ កសិកម្មមានការចំរើនរីកលូតលាស់យ៉ាងខ្លាំង។ កត្តាច្បងនៃការ លូតលាស់នេះក្រៅពីស្ថានភាពភូមិសាស្ត្រនិងលក្ខណៈទឹកដីមានជីជាតិល្អ គឺកត្តាមនុស្សបន្ថែមមកទៀត។ អ្នកនគរភ្នំមានតិចនិចខាងនយោបាយទឹក។ គេជីកព្រែកខ្វាត់ខ្វែងសំរាប់បង្ហូរទឹកជំនន់ទន្លេមេគង្គចេញចោលផង សំរាប់លាងភក់ល្បប់ឱ្យស្អាតផង សំរាប់ជាផ្លូវគមនាគមន៍អនុញ្ញាតិសំពៅទូកឆ្លងកាត់ពីសមុទ្រចិនទៅឈូងសមុទ្រសៀមផង។ បណ្តាញព្រែកជីកនេះនៅមានស្នាមសេសសល់ដល់ សព្វថ្ងៃនៅម្តុំភាគខាងលិចកម្ពុជាក្រោម។

វិស័យពាណិជ្ជកម្មវិញក៏មានការរីកចំរើនលូតលាស់ណាស់ដែរ។ អ្នកស្រាវជ្រាវបានរកឃើញកំពង់ផែ អូ កែវ កម្ពុជាក្រោម ដែលគេចាត់ទុកថា ជាកំពង់ផែអន្តរជាតិមួយ។ កំនាយនៅតំបន់នោះបានរកឃើញវត្ថុផ្សេងៗ មកពីប្រទេសក្រៅឆ្ងាយៗ ដូចជាឥណ្ឌា អ៊ីរ៉ង់ រ៉ូម៉ាំងជាដើម។ នេះជាភស្តុតាងមួយបញ្ជាក់ឱ្យឃើញថាសម័យនគរភ្នំ វិស័យពាណិជ្ជកម្មមានការចំរើនលូតលាស់ជាអតិបរមាទាំងក្នុងប្រទេសទាំងក្រៅប្រទេស។ ឯកសារចិនបានឱ្យដឹងថា អ្នកស្រុកនគរភ្នំស្ទាត់ជំនាញខាងធ្វើសំពៅសមុទ្រ ហើយបញ្ជាក់ថែម ទៀតថា នគរភ្នំជាទីកើតមាសប្រាក់ទង់ដែង គ្រឿងក្រអូប។ល។ អ្នកស្រុកប៉ិនប្រសប់ក្នុងរបរជំនាញសូន្យរូប ត្បាញបរបាញ់ហើយ ចេះស្លកែវទៀតផង។ ដូចនេះយើងឃើញថា សេដ្ឋកិច្ចខ្មែរសម័យនគរភ្នំលូតលាស់ណាស់។ នេះជាសក្ខីភាពមួយនៃភាពរុងរឿងក្នុងសម័យបុរេអង្គរ។

**សម័យអង្គរ**

**ក- វិស័យកសិកម្ម** : មានការចំរើនលូតលាស់ខ្លាំងណាស់។ ការចំរើននេះកើតឡើងដោយកត្តាជាច្រើនៈ

-បណ្តាញព្រែកជីកៈ នយោបាយទឹក ជាមរតកអតីតកាលពីដូនតាមក។

-សម័យអង្គរៈ ខ្មែរកាន់តែមាន តិចនិចប្រសើរក្នុងវិស័យនយោបាយទឹកនេះឯង។ គេជីកព្រែកខ្វាត់ខ្វែងទីក្រុងអង្គរដើម្បីចែកចាយទឹក គេជីកបារាយណ៍ធំៗដើម្បីសន្សំទឹកទុកប្រើនៅរដូវប្រាំង តិចនិចបញ្ចូលទឹកក្នុងស្រែកាន់តែប្រសើរ។

ដូចនេះឃើញថា ខ្មែរសម័យអង្គរបានបោះមួយជំហានទៅមុខទៀតក្នុងផ្នែកកសិកម្ម ព្រោះថាពីដើមកសិកម្មខ្មែរពឹងផ្អែកទៅលើទឹកភ្លៀង។ ដល់ខ្យល់រដូវ មានការប្រែប្រួលភ្លៀងធ្លាក់មិនទៀងទាត់ កសិកម្មអាចរងគ្រោះថ្នាក់។ តិចនិចថ្មីអាចជៀសផុតពីគ្រោះថ្នាក់នេះ។

កត្តាមនុស្ស : ខ្មែរអ្នកប៉ិនប្រសប់ស្រលាញ់ការងារ ជាជនជាតិឧស្សាហ៍ចង់តែធ្វើឱ្យចំរើនលូតលាស់គ្រប់វិស័យ។

កត្តាមនុស្សដែលជាជាតិឆ្លាតប៉ិនប្រសប់នេះផ្សំជាមួយទឹកដីមានជីជាតិល្អស្រាប់អាចជាកំលាំងមួយធ្វើឱ្យកសិកម្មលូតលាស់ ជាអតិបរិមា។ លោក ជីវ តាក្វួន អ្នកកត់ត្រាប្រវត្តិសាស្ត្រជាតិចិនបានឱ្យដឹងថាសម័យអង្គរខ្មែរអាចធ្វើស្រែបានដល់ទៅ ៣ រឺ ៤ ដង ក្នុងមួយឆ្នាំ។ លោក Henri Siterlin អ្នកឯកទេសជាតិស្វ៊ីសបានគណនាឃើញថា ផលិតផលកសិកម្មតំបន់អង្គរអាចចិញ្ចឹមប្រជាជនបានចំនួន ៨០០. ០០០នាក់ ហើយនៅសល់ ៨០% ទៀតសំរាប់នាំចេញទៅតំបន់ក្រៅ។ ការរីកចំរើនលូតលាស់សេដ្ឋកិច្ចនេះហើយ ដែលធ្វើឱ្យអរិយធម៌អង្គរបានឡើងដល់កំពូលមានឈ្មោះល្បីល្បាញពេញសកលលោក ។

**ខ- ឧស្សាហកម្ម :**

គ្មានឯកសារច្បាស់លាស់បញ្ជាក់ពីបច្ចេកទេស បង្កើតប្រដាប់ប្រើប្រាស់នៅសម័យអង្គរទេ។ តែគេសន្និដ្ឋានបានថាពិតជាមាន ឧស្សាហកម្មមួយបែប ព្រោះសំណល់គ្រឿងប្រើប្រាស់ជាច្រើនអាចយកមកធ្វើជាភស្តុតាងបញ្ជាក់បាន។

**គ- ពាណិជ្ជកម្ម :**

វិស័យពាណិជ្ជកម្មក៏មានការចំរើនលូតលាស់ណាស់ដែរ ទាំងក្នុងប្រទេស

ទាំងក្រៅប្រទេស។ គេដឹងថា ខ្មែរសម័យអង្គរបាននាំចេញទៅក្រៅប្រទេសនូវរបស់ដែលបានពីធម្មជាតិ ដូចជា ក្រវាញ កុយហេស ក្លុកជ័យ សត្វ។ល។ ទំនិញនាំចូល ទំនងជាកំនាត់សំពត់ សំណ ស្ពាន់ធ័រ គ ផង។

ទំនាក់ទំនងពាណិជ្ជកម្មនេះ បានធ្វើឱ្យអរិយធម៌ជាតិប៉ះទង្គិច និងអរិយធម៌បរទេស ហើយទំនាក់ទំនងនេះធ្វើឱ្យអរិយធម៌ កាន់តែចំរើន លូតលាស់ថែមទៀត។

**សម័យក្រោយអង្គរ**

គ្រឹះសេដ្ឋកិច្ចនៅតែជាកសិកម្មដដែល ជាពិសេសដំណាំស្រូវ។ តែបារាំងដែលបានមកតតាំងអនានិគមរបស់ខ្លួនលើប្រទេសខ្មែរ បានដាំកៅស៊ូដែលជាដំនាំថ្មីទ្រទ្រង់សេដ្ឋកិច្ចធម្មជាតិ។

សេចក្តីអធិប្បាយរួចមកហើយនេះ បង្ហាញថាគ្រឹះសេដ្ឋកិច្ចខ្មែរ គឺកសិកម្ម។ ដូចនេះក្នុងការរៀបចំកសាងជាតិ កសិកម្មជាវិស័យដែលត្រូវយកចិត្តទុកដាក់ខានមិនបាន។

៩០៤

ប្រធានទី ៣១

## សង្គមកិច្ចខ្មែរ

គោលគំនិតសង្គមកិច្ចជាវិស័យមួយ ក្នុងសង្គមដែលមានមុខងាររៀបចំសង្គមឱ្យបានចំរើនលូតលាស់។ វិធីរៀបចំសង្គមនេះជាប់ទាក់ទងទៅនឹងវិធីទាំងពីរ គឺ នយោបាយ និងសេដ្ឋកិច្ច គេតែងសង្កេតឃើញថាដរាបណានយោបាយមានវិបត្តិ សេដ្ឋកិច្ចក៏មានវិបត្តិ ហើយសង្គមកិច្ចក៏គេចមិនផុតពីវិបត្តិឡើយ។ ផ្ទុយទៅវិញ នយោបាយ អាចស្ថិតនៅរឹងប៉ឹងបានក៏ដោយសារគ្រឹះសេដ្ឋកិច្ច។

បើសេដ្ឋកិច្ចរលំ នយោបាយក៏បាត់បង់ឯករាជ្យភាពរបស់ខ្លួន វិបត្តិសង្គម-កិច្ច ពិតជាចេញរូបរាងឡើងពុំខាន។ វិបត្តិសង្គមកិច្ច ក៏ជាកត្តាមួយផ្អាកដំនើរសេដ្ឋកិច្ច និងនយោបាយបានដែរ។

ដូចនេះវិធីរៀបចំសង្គមទាំងបីនេះជាប់ទាក់ទងគ្នាជិតស្និតណាស់។ ក្នុងកិច្ចការកសាងជាតិអ្នកដឹកនាំតែងចាប់អារម្មណ៍លើវិធីទាំងបីនេះ។ តើខ្មែរបានរៀបចំសង្គមកិច្ចតាមវិធីណាខ្លះតាំងពីសម័យបុរាណមក?

ឯកសារប្រវត្តិសាស្ត្របានបង្ហាញឱ្យឃើញថា ដូនតាយើងពិតជាយល់ច្បាស់នូវសារៈសំខាន់នៃសង្គមកិច្ច។គេតែងឃើញមាន ការកសាងផ្លូវ ស្ពាន សាលាសំណាក់ ផ្ទះពេទ្យ ទំនប់ទឹក បារាយ ប្រឡាយទឹក ដែលសុទ្ធតែជាមធ្យោបាយពង្រីកសង្គមកិច្ចជាតិ។

ដូចនេះស្របនិងវិស័យនយោបាយ និងសេដ្ឋកិច្ច វិស័យសង្គមកិច្ចក៏ត្រូវខ្មែរស្គាល់តំលៃព្រមទាំងរៀបចំយ៉ាងមាំទាំ។ ការស្រលាញ់រាប់អានគ្នា ការជួយគ្នាទៅវិញទៅមកក្នុងសង្គមខ្មែរជាភស្តុតាងមួយបញ្ជាក់ឱ្យឃើញភាពរឹងប៉ឹងផ្នែកសង្គមកិច្ចនេះឯង។

# ផ្នែកទី ៤

## ប្រធានទី ៣២

### តំលៃពិសេសនៃអរិយធម៌

សេចក្តីអធិប្បាយរួចមកហើយនេះ នាំឱ្យយើងឃើញថាខ្មែរជាជនជាតិមួយមានវ័យចំនាស់ជាងគេរស់នៅលើជ្រោយឥណ្ឌូចិននេះតាំងពីសម័យបុរាណកាល បានបង្កបង្កើតអរិយធមិ មួយដែលពិតជាអរិយធមិ ផ្ទាល់ខ្លួនលើទឹកដីនេះពីមុនមកដល់នៃជនជាតិបរទេស មាន ឥណ្ឌា ចិន បារាំងសែសជាដើម ទំនាក់ទំនងបរទេសបានធ្វើឱ្យអរិយធមិនេះប៉ះទង្គិច ជាមួយអរិយធមិផ្សេងៗទៀត ហើយរលាយចូលគ្នាខ្លះ ការលៃគ្នាទៅវិញទៅមកខ្លះ សំរបសំរួលតាមមូលធមិជាតិជាហេតុធ្វើឱ្យអរិយធមិមានវិវត្តន៍ចំរើនលូតលាស់មួយក៏រិតថែមទៀត។ ឥទ្ធិពលបរទេសក្នុងអរិយធមិជាតិពុំមែននាំឱ្យខូចតំលៃជាតិទេ ព្រោះជាការធម្មតាទំនាក់ទំនងអន្តរជាតិ តែងតែធ្វើឱ្យមានកំចីគ្នាទៅវិញទៅមកដូចនេះឯង តែតំលៃពិតស្ថិតនៅត្រង់ចេះយកខ្លឹមសារបរទេសមកទំពារឱ្យល្អិតចាក់ចូលក្នុងអរិយធមិជាតិនេះទៅវិញ។ លក្ខណៈនេះពិតជាមានក្នុងអរិយធមិខ្មែរ។

ភាសាក្តី អក្សរក្តី អក្សរសិល្ប៍ក្តី សិល្បៈក្តី ទំនៀមទំលាប់ក្តី ទស្សនៈវិជ្ជាក្តីសុទ្ធតែមានលក្ខណៈពិសេសរបស់ខ្លួន ពុំមែនចំលងតាម បរទេសដូចអ្នកខ្លះស្មាននោះឡើយ។

អាស្រ័យហេតុនេះហើយបានជាអរិយធមិខ្មែរក្លាយទៅជាអរិយធមិខ្ពង់ខ្ពស់ដែលអ្នកសិក្សាបស្ចិមប្រទេសចាប់អារម្មណ៍យ៉ាងខ្លាំង ដោយចំនាយពេលនិងប្រាក់កាសជាច្រើនដើម្បីធ្វើការស្រាវជ្រាវសិក្សាវប្បធមិ អរិយធមិខ្មែរមននេះឯង។

ការស្គាល់អរិយធម៌ជាតិមិនច្បាស់អាចធ្វើឱ្យខ្មែរបាត់បង់មោទនៈភាពវិញ។ ធ្វើបែបនេះពុំមែននាំមកនូវតំលៃជាតិទេ តែបានបង្ខូចតំលៃជាតិទៅវិញ។

ដូចនេះការស្គាល់អរិយធម៌ជាតិជាកត្តាចាំបាច់មួយ ដើម្បីពង្រឹងស្មារតីជាតិដែលជាអាវុធសំខាន់មួយ សំរាប់ទប់ទល់និងបំណាង សំលាប់អរិយធម៌ខ្មែរពីសំណាក់បរទេសជិតខាងយើងនេះ។

**ដំណឹង**

នឹងមានចេញផ្សាយនៅពេលខាងមុខ

**សំនួរ-ចំលើយ និង**

**អត្ថាធិប្បាយ ទស្សនះវិជ្ជា**

រៀបសំរួលជាភាសាខ្មែរដោយ :

**ហួត សេចស្ករ**











មានលក់ដុំនិងរាយនៅសៀវភៅពុម្ពគ្រប់ប្រភេទ

តូបលេខ **15-43** ផ្សារអូឫស្សី

(ឡៅតឿប៉ែកខាងកើត)

ទំនាក់ទំនងទូរស័ព្ទលេខ: **012 75 96 79 / 098 75 96 79**